00362732

E1/60.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**
**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**
**សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩**
**សវនាការលើកទី៥៦**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
លោក លឹម ស៊ុយហុង
កញ្ញា ណាតាចា វិចស៊ែល រីសឺ
*(Ms. Natacha Wexels-Riser)*
កញ្ញា អៃដា កេសាវ៉ាហ្ស៊ី
*(Mss. Aida KESHARVASI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អានីស អះមេដ *(Mr. Anees AHMED)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំពែល *(Mr.Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្កេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារេស

*(Marie-Paule CANIZARES)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

កញ្ញា ទី ស្រ៊ីនណា

លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ*(Mr. Alain Werner)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

*(Ms. Fabienne Trusse-Naprous)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

### លោក ឈុន ផល

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........................................................ទំព័រ ១០
សួរដោយ លោក តាន់ សេណារ៉ុង ផ្តើមពី ..........................................................ទំព័រ ៣៥
សួរដោយ លោក អានីស អះមេដ ផ្តើមពី ..........................................................ទំព័រ ៣៧
សួរដោយ លោក ហុងគីមសួន ផ្តើមពី ..........................................................ទំព័រ ៤២
សួរដោយ លោក ការ សាវុត្ថ ផ្តើមពី ..........................................................ទំព័រ ៤៨
សួរដោយ លោកស្រី ម៉ារីប៉ូល កានីហ្សារេស ផ្តើមពី ......................................ទំព័រ ៥១

### លោក សោម ម៉េត

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ........................................................ទំព័រ ៥៥
សួរដោយ ចៅក្រម យ៉ា សុខន ផ្តើមពី ..........................................................ទំព័រ ៥៧
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ..............................................ទំព័រ ៧៥

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អានីស អះមេដ | អង់គ្លេស |
| លោកស្រី ម៉ារីប៉ូល កានីហ្សារេស | បារាំង |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ឈុន ផល | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក សោម ម៉េត | ខ្មែរ |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |
| ចៅក្រម យ៉ា សុខន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០១:៥១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះសាលាដំបូង ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មសាក្សីជាបន្ត ។ មុននឹងដំណើរការអញ្ជើញសាក្សីចូលសវនាការ សូមអញ្ជើញក្រឡាបញ្ជីសវនាការឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលត្រូវកោះហៅឲ្យចូលរួមនៅក្នុងដំណើរការសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ ចំណែកឯសាក្សី KW-23 និង KW-15 មានវត្តមាន រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីទាំងពីររូបនេះមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬភាគីរដ្ឋប្បវេណីនោះទេ ។ សាក្សីទាំងពីររូបបានស្បថរួចហើយ ។

**ប្រធានអង្គជំនុំ៖**

មុននឹងដំណើរការស្តាប់សក្ខីកម្មសាក្សីតាមកាលវិភាគដែលបានគ្រោងទុក អង្គជំនុំជម្រះសូមធ្វើការជម្រាបជូនដល់ភាគី និងសាធារណជនឲ្យបានជ្រាបអំពី មានការប្រែប្រួលនូវកម្មវិធីសវនាការសម្រាប់ចាប់ពីថ្ងៃច័ន្ទ ទី១០ រហូតដល់ថ្ងៃពុធ ទី១២ ខែសីហា ឆ្នាំ២០០៩ ដោយមានការប្រែប្រួលកាលវិភាគសវនាការ ។ អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីទាំងអស់ឲ្យបានជ្រាបថា នៅព្រឹកថ្ងៃច័ន្ទ ទី១០ ខែសីហា ឆ្នាំ២០០៩នេះ អង្គជំនុំជម្រះនឹងស្តាប់ចម្លើយសាក្សីឈ្មោះ ឈុន ផល ដែលកំណត់រយៈពេលកន្លះថ្ងៃ ។ នៅរសៀលថ្ងៃច័ន្ទ ទី១០ និងព្រឹកថ្ងៃអង្គារ ទី១១ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីKW-15 ។ នៅល្ងាចថ្ងៃអង្គារ៍ទី១១ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះនឹងអានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ ស៊ីធីម ឯកសារD28/8 ។ កំណត់ហេតុនៃការតទល់មុខគ្នា ឯកសារ D54 ត្រង់ចំណុចដែលពាក់ព័ន្ធនឹងចម្លើយរបស់សាក្សី ម៉ក់ ស៊ីធីម ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តយ តេង ឯកសារ D28/12 ឯកសារ D50/3 ។ កំណត់ហេតុនិងការចុះស៊ើបអង្កេតដល់ទីកន្លែងកើតហេតុ ឯកសារ D48/1 ត្រង់ចំណុចដែលពាក់ព័ន្ធនឹងចម្លើយរបស់ តយ តេង ។ កំណត់ហេតុនៃការតទល់មុខគ្នា ឯកសារ D52 ត្រង់ចំណុចដែលពាក់ព័ន្ធនឹងចម្លើយរបស់ តយ តេង ។ កំណត់

ហេតុនៃការស្តាប់ចម្លើយសាក្សី សោម សំអុល D78/6 ។ សង្ខេបនូវចម្លើយសាក្សី ជ័យ សុភា ឯកសារ D82/1 ។ កំណត់ហេតុនៃការចុះស៊ើបអង្កេតដល់កន្លែងកើតហេតុ ឯកសារ D48/1 ត្រង់ចំណុចដែលពាក់ព័ន្ធនឹងសក្ខីកម្ម មាស ប៉េងគ្រី កំណត់ហេតុតទល់មុខគ្នាឯកសារ D52 ត្រង់ចំណុចដែលពាក់ព័ន្ធនឹង មាស ប៉េងគ្រី ។

[០៩:០៥:៤៦]

អង្គជំនុំជម្រះនឹងស្នើសុំឲ្យភាគីផ្តល់យោបល់លើកំណត់ហេតុនៃការស្តាប់សក្ខីកម្មសាក្សី មាស ប៉េងគ្រី ដែលបានអានដោយក្រឡាបញ្ជី ដែលបានធ្វើរួចហើយកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ។ ក្នុងករណីដែលអង្គជំនុំជម្រះមិនអាចបញ្ចប់នូវការអានកំណត់ហេតុទាំងអស់ខាងលើ ផ្នែកដែលនៅសល់ត្រូវយកទៅអាននៅល្ងាចថ្ងៃពុធ ទី១២ ខែសីហា ឆ្នាំ២០០៩ ។ នៅព្រឹកថ្ងៃពុធ ទី១២ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះនឹងស្តាប់ចម្លើយសាក្សី KW-29 ។

អង្គជំនុំជម្រះក៏សូមជម្រាបជូនដំណឹងដល់ភាគីផងដែរថា ដោយសារសាក្សី អ៊ុក ប៊ុនសេង គាត់មានជំងឺធ្ងន់មិនអាចមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបាន ដូច្នេះ អង្គជំនុំជម្រះសម្រេចអាននូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរូបនេះ ជំនួសការមកធ្វើសក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះនៅសាលសវនាការ ។

នៅល្ងាចថ្ងៃពុធ ទី១២ ខែសីហា ឆ្នាំ២០០៩ អង្គជំនុំជម្រះនឹងអាននូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ប៊ុនសេង ដែលមានឯកសារ D78/7 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ាម ហាន ឯកសារ D28/5 ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាច សៀក ឯកសារ D78/5 និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ប៉ាន់ ឯកសារ D78/3 ។

នេះគឺជាមានការប្រែប្រួលនូវកាលវិភាគដំណើរការសវនាការនៅក្នុងសប្តាហ៍នេះ អ៊ីចឹងសូមភាគីទាំងអស់ជ្រាប ។ ហើយជាបន្តអង្គជំនុំជម្រះសូមធ្វើការណែនាំចំពោះមេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូងសូមធ្វើការលើកឡើងនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះចំពោះមុខអង្គជំនុំជម្រះ ។ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងមិនត្រូវបានស្តាប់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះរួមមានដូចខាងក្រោមនេះ ៖

[០៩:០៨:១៣]

ដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ៖

១) D25/23 យឹម ឡេង, ២) D25/15 សួន សៀង, ៣) D25/20 ង៉ែត សុខ, ៤) D25/4 សួស សារិន, ៥) D25/25 កែ ខុន, ៦) D25/18 ម៉ាន ស្ងួត្រ, ៧) D25/10 ខែ ហៀម, ៨) D25/22 ទីមូធី ស្កុតដឹត, ៩) E2/41 ស៊ីន ស៊ីណែត, ១០) E2/42 រូន ស្រីណុប, ១១) E2/43 អែល លីម៉ាស់, ១២) E2/60 នង គឹមលាង, ១៣) E2/47 ស្នាន់ ណុប, ១៤) E2/45 ស្នាន់ ស, ១៥) E2/46 កែ សាមួត, ១៦) E2/47  ម៉ែន ឡាយ, ១៧) E2/48 ញ៉ែម សុផាន, ១៨) E2/49 អេង ស៊ីថា, ១៩) E2/51 ម៉ាន ម៉ាលីម៉ាស់, ២០) E2/52 កំ ម៉ែន, ២១) E2/53 គ្រី ង៉ិចលាង, ២២) E2/54 ហែង ង៉ិច ហុង, ២៣) E2/55 បេង ចាន់ថន, ២៤) E2/56 យិន ឈឺន, ២៥) E2/57 លី ឃាក, ២៦) E2/58 ពួល ពន្លឺក, ២៧) E2/59 ចាន់ គ្រួច, ២៨) E2/62, ២៩) E2/69 លឹម យ៉ុន, ៣០) E2/74 ង៉ែត អ៊ុយ, ៣១) E2/75 ខៀវ នាត, ៣២) E2/88 យ៉ូស្វ រ៉ូតឆាល់, ៣៣) E2/73 នង សាវ៉ាត់ ។

ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ៖

៣៤) D25/21 សាន់ ឡុន, ៣៥) E2/35 លាង កន, ៣៦) E2/21 អៀម សួយ, ៣៧) E2/22 ឈឹម ស៊ីថា, ២៨) (ស៊ីក) E2/25 ស៊ីន លឹមសៀ, ២៩) (ស៊ីក) E2/24 អ៊ុល សាយរាម, ៤០) E2/62 ពេញ សុខេន, ៤១) E2/64 ញ៉ឹក គឹមស្រ៊ា, ៤២) E2/83 ហុង សាវ៉ាត ។

ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបី៖

៤៣) D25/8 មាស កេតសំពណ៏ទ្រី, ៤៤) D25/11 ឃួន សារិន, ៤៥) D25/28 ទូឡុង នេវ៉ា, ៤៦) D25/26 គី ម៉ារីនេ វីនកា, ៤៧) E2/30 ញឹម គឹមប៉ាន, ៤៨) E2/37 ក្លាន ហ្វីត, ៤៩) E2/38 ភាត ប៊ីចូវ, ៥០) E2/29 គីម៉ារី វីសាកា, ៥១) E2/30 សួន សុខុម៉ាលី, ៥២) E2/65 ប៊ុន ស្រី, ៥៣) E2/63 ប៉ាន់ ប៉ិច, ៥៤) E2/76 អ៊ុង រឿន ឬហៅ ហ៊ុល រឿន, ៥៥) E2/78 មាស សារឿន, ៥៦) E2/79 សេក សៀក, ៥៧) E2/70 ចាន់ យឿង, ៥៨) E2/71 សឹម ពៅ, ៥៩) E2/72 កាន សាន, ៦០) E2/84 អ៊ុក វ៉ាសោធិន ។

ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន៖

៦១) D25/17 កាន់ ស៊ុនវ៉ា, ៦២) D25/12 ជ្រាំង សំអៀន, ៦៣) D25/19 គង់ ទេស, ៦៤) E2/28 រស់យូ ស៊ីអ៊ី, ៦៥) E2/31 ញ៉ឹក អ៊ូដាវី, ៦៦) E2/27 អ៊ូ ខាមេឡា ។

ដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងត្រូវស្តាប់ចម្លើយនៅសវនាការខាងមុខ ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង រួមមាន៖

[០៩:១៤:៥០]

ដើមបណ្ដឹងរដ្ឋប្បវេណី E2/85, E2/89 រូប៊ីត ខាំមីល, E2/87, D25/27 ហាវ សោភា, D25/4, E2/82, E2/34 នេត ផល្លី, E2/50 អ៊ូ សាវរិត, E2/26 E2/81 រស់ ម៉េន, D25/9 ជុំ នៅ, D25/16 តូច មុន្និន, D25/14 អ៊ឹម ស៊ុន្ទ, D25/7 ភុង ហ្គុតស៊ុនថាវី, D25/5 ចេសរី ចេម, E2/86 ឈិន ណាវី, D25/2 ជុំ ស៊ីវ៉ាត់, D25/6 គៀង វណ្ណារី, E2/77 និង សៀង វណ្ឌី D25/14 ។

អង្គជំនុំជម្រះសូមស្នើដល់មេធាវីការពារក្ដី ដើម្បីបញ្ជាក់ថា តើខ្លួនមានបំណងធ្វើការតវ៉ាចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីណាខ្លះក្នុងចំណោមពាក្យបណ្ដឹងទាំងនេះ ។ ហើយប្រសិនបើខ្លួនមានបំណងធ្វើដូច្នេះនោះ សូមធ្វើការបញ្ជាក់ដោយខ្លីនូវហេតុផលនៃការតវ៉ារបស់ខ្លួន ។ អង្គជំនុំជម្រះនឹងធ្វើការស្ដាប់នូវការតវ៉ារបស់មេធាវីលើបញ្ហានេះនៅថ្ងៃច័ន្ទ ទី១៧ ខែសីហា ឆ្នាំ២០០៩ ។

ដោយយោងលើការបញ្ជាក់របស់មេធាវីការពារក្ដី អង្គជំនុំជម្រះនឹងកំណត់ពេលវេលានៅពេលក្រោយសម្រាប់មេធាវីការពារក្ដីសម្រាប់ធ្វើការបង្ហាញនូវអំណះអំណាងទាំងឡាយរបស់ខ្លួន។ ម៉្យាងវិញទៀត អង្គជំនុំជម្រះក៏សូមស្នើដល់មេធាវីការពារក្ដីថា ប្រសិនបើខ្លួនអាចធ្វើការបញ្ជាក់នាពេលនេះបាននោះ សូមធ្វើការបញ្ជាក់ដល់អង្គជំនុំជម្រះថា តើខ្លួនមានបំណងនឹងធ្វើការតវ៉ាចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងមកផ្ដល់សក្ខីកម្មនាសប្ដាហ៍បន្ទាប់នេះដែរឬទេ? ហើយប្រសិនបើមេធាវីមានបំណងធ្វើដូច្នេះមែន អង្គជំនុំជម្រះសូមមេធាវីការពារក្ដីបញ្ជាក់ថា តើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីណាខ្លះដែលខ្លួននឹងធ្វើការតវ៉ានោះ ។

នេះជាព័ត៌មានដើម្បីជូនដល់ទៅមេធាវីការពារក្ដី ដើម្បីជ្រាប ហើយនិងមានចំណាប់អារម្មណ៍ និងធ្វើការចាត់ការពិនិត្យនៅលើបណ្ដឹងទាំងឡាយ ដែលអង្គជំនុំជម្រះបានសម្រេចដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ដោយនីតិវិធីរបស់អង្គជំនុំជម្រះរបស់យើងមានការសម្របសម្រួលមួយដើម្បីកាត់បន្ថយនៃពេលវេលាក្នុងការពិនិត្យល្អិតល្អន់ទាំងអស់នោះ គឺហេតុដូចនេះគឺយើងជម្រាបជូនដំណឹងដល់មេធាវីការពារក្ដីជាមុន ដើម្បីមានលទ្ធភាព និងពេលវេលាពិនិត្យនូវពាក្យបណ្ដឹងទាំងអស់ ដើម្បីមានលទ្ធភាពនឹងធ្វើការកត់សម្គាល់នូវពាក្យបណ្ដឹងទាំងឡាយ ដែលមានខ្លឹមសារដូចយើងបានជម្រាបជូនអម្បាញ់មិញនេះរួចហើយ ។

សូមអញ្ជើញមេធាវី អាឡាំង វ៉ែនណឺ ។

[០៩:១៨:៥៤]

**លោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកប្រធាន។ ខ្ញុំសូមលើកនូវបញ្ហាមួយ ហើយនិងចង្អុលបង្ហាញដើម្បីជាអត្ថប្រយោជន៍ដល់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីក្រុមទទីមួយ នឹងចាប់ផ្តើមអាទិត្យក្រោយហើយនិងអាទិត្យមួយទៀត យើងមានដើមបណ្តឹងរដ្ឋប្បវេណីបួនមកទីនេះ ដើម្បីចៀសវាងនូវបញ្ហាអ្វីដែលយើងនេះ គឺថាយើងរៀបចំជាសំណើមួយដែលដាក់នៅក្នុងអនុស្សរណៈនៅក្នុងថ្ងៃទី៥ ខែសីហា អ្វីដែលយើងព្យាយាមធ្វើនោះ យើងពន្យល់ ហើយនិងឆ្លើយនូវសំណួរជាអនុស្សរណៈជាមុននៅក្នុងករណីមួយឬពីរដែលថាយើងមានព័ត៌មានថ្មី ដែលយើងទទួលបាន ដើម្បីឲ្យមានការបញ្ជាក់នៅក្នុងនោះ ហើយដោយសារមានការបកប្រែផង សំណើហ្នឹងគឺដើម្បីបកប្រែកាលពីសប្តាហ៍មុនអាចនឹងថ្ងៃពុធ ឬថ្ងៃព្រហស្បតិ៍យើងបាន ។ ប៉ុន្តែ អ្វីដែលយើងចង់បាននោះ យើងរៀបចំថ្ងៃនេះ និងថ្ងៃស្អែកនូវឯកសារមួយ ដោយមានឯកសារបង្ហាញថ្មី ហើយអាចនឹងជូនទៅខាងមេធាវីការពារថ្ងៃនេះ ឬថ្ងៃស្អែកដើម្បីពិនិត្យ ដើម្បីឲ្យគាត់ដឹងថាយើងមានអ្វីខ្លះនៅក្នុងនោះ ។

នៅសប្តាហ៍នេះយើងមានពាក្យសុំមួយចំនួន ហើយនិងឆ្លើយតបទៅនឹងសំណួរមួយចំនួនទាក់ទងដើមបណ្តឹងរដ្ឋប្បវេណី ។ យើងសង្ឃឹមថា នឹងជួយដល់មេធាវីការពារ ដើម្បីបញ្ជាក់អំពីចំនួន ជំហរ ឬការតវ៉ារបស់ខ្លួន ។

ខ្ញុំគិតថា ជាការល្អនឹងជូនដំណឹងទៅមេធាវីការពារ ហើយនិងជូនដំណឹងពេលនេះ ថាអាចនឹងមាននូវពេលណាមួយក្នុងសប្តាហ៍នេះសម្រាប់គាត់ពិនិត្យ ដើម្បីឲ្យយើងអាចនឹងប៊ាននិយាយពីខ្លឹមសារអ្វីដែលថ្មីក្នុងអាទិត្យក្រោយនេះ ។ សូមអរគុណ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អានីស អះមេដ៖**

ដោយមានការអនុញ្ញាតពីលោកប្រធាន សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះដែលទាក់ទងថានឹងដាក់បញ្ចូលនូវពាក្យសុំ និងព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ជាមុននេះ យើងមិនមានការសង្កេត ឬការជំទាស់អ្វីទេក្នុងការដាក់ភស្តុតាង ឬក៏សំណើថ្មី ដើម្បីពិចារណានៅក្នុងសេចក្តីសម្រេចសាលក្រមនោះ ។ ដើម្បីបំភ្លឺ ខ្ញុំសូមស្នើថា សុំឲ្យអង្គជំនុំជម្រះបំភ្លឺថា នូវការទទួលសំណើរបស់

ដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះក៏ទទួលស្គាល់ឯកសារទាំងអស់ដែលភ្ជាប់ជាមួយពាក្យសុំនោះដែរ។

អ៊ីចឹងហើយ ប៉ុន្តែអង្គជំនុំជម្រះបាន-- មានន័យដូច្នេះហើយ ខ្ញុំគ្រាន់តែបញ្ជាក់បន្ថែម ។ ហើយយើងក៏មិនមានជំទាស់អ្វីទៅនឹងការដាក់ស្នើនូវភស្តុតាងជាឯកសារជាមួយពាក្យស្នើសុំនេះទេ ។

**ប្រធានអង្គជំនុំ៖**

បើមិនមានមតិយោបល់អីទៀតទេ គឺអង្គជំនុំជម្រះនឹងបន្តនីតិវិធីតាមកាលវិភាគដែលបានគ្រោងទុក ។

មន្ត្រីតុលាការអញ្ជើញសាក្សី ឈុន ផល ចូលមកកាន់បន្ទប់សវនាការ ។

*[សាក្សីចូលមកកាន់បន្ទប់សាលសវនាការ]*

**ប្រធានអង្គជំនុំ៖**

ទាក់ទងនឹងសេចក្ដីណែនាំចំពោះមេធាវីការពារក្ដីដែលយើងបានបង្ហាញអម្បាញ់មិញនេះ តើមានអ្វីទេ? មានការជជែកគ្នារវាងមេធាវីការពារក្ដីជាតិ និងអន្តរជាតិ តើមានបញ្ហាអ្វីចង់កត់សម្គាល់ ឬក៏មិនមានទេ? ពីព្រោះនេះគ្រាន់តែជាការណែនាំដើម្បីឲ្យបានត្រៀមលក្ខណៈជាមុន ដើម្បីពិនិត្យនូវឯកសារទាំងនេះ ហើយយើងនឹងធ្វើការនូវថ្ងៃច័ន្ទ មុននឹងដំណើរការ ។ យើងចាប់ធ្វើទៅ ប្រសិនបើមានបញ្ហាធំធេងកម្រិតណានោះ តើត្រូវចំណាយពេលវេលាប៉ុន្មាន ដើម្បីធ្វើការជជែកដេញដោលចំពោះពាក្យបណ្ដឹងមួយចំនួនដែលខាងមេធាវីការពារយល់ថាត្រូវការជជែកដេញដោលបញ្ជាក់អំពីភាពពាក់ព័ន្ធ ឬក៏ទៅតាមភាពនៃទម្រង់នៃពាក្យបណ្ដឹងសុំនោះ តើវាមានចំនួនប៉ុន្មាន? ហើយអង្គជំនុំជម្រះនឹងគណនាដើម្បីកំណត់ពេលវេលាសមស្រប ដើម្បីធ្វើការដេញដោលនូវពាក្យបណ្ដឹងទាំង៦៦ នៅលើដើមបណ្ដឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះសម្រេចថា មិនអញ្ជើញគាត់មកធ្វើសេចក្ដីថ្លែងការណ៍ទាំងអស់ពេលសវនាការនៅចំពោះមុខអង្គជំនុំជម្រះទេ ដោយសារមូលហេតុច្រើនពេក វានឹងអាចចំណាយពេលវេលាច្រើននៅក្នុងដំណើរការសវនាការ ។

[០៩:២៤:៤៣]

នេះជាព័ត៌មានដែលជូនទៅភាគីមេធាវីការពារក្ដី ដើម្បីបានទទួលបញ្ហានេះពិនិត្យជាមុន ហើយនិងធ្វើការបញ្ជាក់ថា ចំនួនណាខ្លះ ឬក៏ពាក្យបណ្ដឹងណាខ្លះតវ៉ា ហើយហេតុផលយ៉ាងម៉េចខ្លះក្នុងការតវ៉ានេះ ដើម្បីអង្គជំនុំជម្រះមានមូលដ្ឋានពេញលេញក្នុងការគិតគូរគណនាពេលវេលាសមស្រប ដើម្បីកំណត់កាលបរិច្ឆេទ កាលវិភាគក្នុងការដេញដោលចំពោះករណីនេះនៅក្នុងកម្មវិធី ហើយបំណងរបស់អង្គជំនុំ

ជម្រះគឺថា ដើម្បីកំណត់នូវកាលវិភាគចុងក្រោយនៃការពិភាក្សាដេញដោល ដើម្បីចៀសវាងការកំណត់កាលបរិច្ឆេទដំណើរការទៅវាមានខុស ចេះតែមានការកែសម្រួលនូវកាលវិភាគវាមិនសមរម្យប៉ុណ្ណោះទេ ។ សូមអញ្ជើញបើសិនជាមាន ។

[០៩:២៥:៣៧]

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

លោកប្រធាន ទាក់ទងទៅនឹងសំណើរបស់តុលាការ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនោះ មេធាវីការពារសូមបញ្ជាក់ជម្រាបថា ខ្លួនមានការសង្ស័យចំពោះភាពសមស្របនៃពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ ។ ក្នុងពេលបច្ចុប្បន្ននេះ មិនមានឯកសារគ្រប់គ្រាន់ដើម្បីបង្ហាញថា ជនរងគ្រោះដែលថាខ្លួនជាអ្នករងគ្រោះនៅស-២១ កាំង ហ្គេកអ៊ាវ បានពិនិត្យឯកសារហើយ ឈ្មោះអ្នកដែលនៅក្នុងបញ្ជីដែលថាជា-- នៅក្នុងបញ្ជីអ្នកទោសស-២១នោះ ពេលខ្លះគឺមិនត្រឹមត្រូវទៅតាមអ្វីដែលគេអះអាងទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីគឺ E2/77, E2/81, E2/82 អនុលោមតាមឯកសារដូចដែល អាឡាំង វែនណឺ បានបញ្ជាក់ហ្នឹងថាបាននឹងដាក់បន្ថែមនោះ នេះក៏វាពាក់ព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី E2/50 ។ មេធាវីការពារយល់ថាដើមបណ្តឹងរដ្ឋប្បវេណីដែលខ្ញុំបានបញ្ជាក់នេះ គប្បីដាក់ឯកសារបន្ថែមទៀតដើម្បីទៀតដើម្បីបញ្ជាក់ឲ្យច្បាស់ពីអត្តសញ្ញាណថា ខ្លួនជាជនរងគ្រោះពិតជាជាប់ឃុំនៅស-២១ នោះមែន ។

ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី D2/25 កាំង ហ្គេកអ៊ាវ មិនជំទាស់អង្គហេតុដែលថាបង ឬប្អូនរបស់ជននេះជាប់នៅស-២១ នេះទេ ប៉ុន្តែគាត់ជំទាស់អំពីបងថ្លៃស្រី ហើយនិងម្តាយមីងរបស់គាត់ថាមិនមែនជាអ្នកឆ្លងកាត់ ឬក៏ឃុំនៅស-២១ នោះទេ ។

ហើយទីបញ្ចប់ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី E2/89 យើងមិនដឹងថាមានឯកសារអ្វីខ្លះទេ អ៊ីចឹងហើយកាលណាមានហេតុការណ៍អ្វីដែលគួរឲ្យភ្ញាក់ផ្អើល ឬក៏ឯកសារនោះ យើងនឹងមានការជំទាស់ ទោះបីជាជនជាប់ចោទមិនជំទាស់លើពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងក៏ដោយ គាត់អាចនឹងចង់នឹងធ្វើការសង្កេតនៅពេលណាមួយសមស្របនៅពេលក្រោយ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ នេះជាការកត់សម្គាល់ជាបឋម ផ្នែកខាងរបស់មេធាវីការពារក្តីចំពោះពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ។ ប៉ុន្តែបញ្ហានេះអង្គជំនុំជម្រះជម្រាបហើយថា នេះជាការជូនដំណឹងដើម្បីមេធាវីការពារក្តីហ្នឹងមានលទ្ធភាពក្នុងការរៀបចំឯកសារ ដើម្បីតវ៉ាទៅនឹងពាក្យសុំតាំងខ្លួនជាដើម

បណ្ដឹងរដ្ឋប្បវេណីទាំងនេះ ហើយសេចក្ដីបញ្ជាក់អំពីសេចក្ដីតវ៉ារបស់ខ្លួននោះ អង្គជំនុំជម្រះនឹងផ្ដល់ពេលវេលាមួយសមស្រប ដើម្បីមេធាវីការពារក្ដីធ្វើការបង្ហាញអំពីតវ៉ារបស់ខ្លួននៅព្រឹកថ្ងៃច័ន្ទ ទី១៧ ខែសីហា ឆ្នាំ២០០៩ ។ នេះគឺជាផែនការរបស់អង្គជំនុំជម្រះ ដើម្បីអង្គជំនុំជម្រះទទួលព័ត៌មាននោះ យកទៅវិភាគពិចារណា ហើយគណនាពេលវេលាដាក់នៅក្នុងកាលវិភាគសម្រាប់ធ្វើការដេញដោល ចំពោះពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយណាដែលមេធាវីការពារក្ដីសម្ដែងនូវការតវ៉ារបស់ខ្លួន ។

សូមអញ្ជើញ អាឡាំង វ៉ែនណឺ ប៉ុន្ដែបញ្ជាជម្រាបអ៊ីចេះ ថានេះគ្រាន់តែជាការរំឭកនិងដាស់តឿនដល់ទៅភាគីមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីឲ្យគាត់បានត្រៀមនូវលក្ខណៈសម្បត្តិ ដើម្បីគាត់ពិនិត្យនូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ភាពមិនសមស្របទាំងឡាយដែលគាត់យល់ថាត្រូវជំទាស់ ហើយគាត់នឹងធ្វើការជំទាស់ត្រៀមជាស្រេច ហើយនិងធ្វើការបង្ហាញអំពីការជំទាស់របស់ខ្លួននៅព្រឹកថ្ងៃច័ន្ទ ទី១៧ ខែសីហា ឆ្នាំ២០០៩ ខាងមុខ ។ ការជំទាស់នេះ គឺអង្គជំនុំជម្រះក្ដាប់តែហេតុផលនៃការជំទាស់ ហើយនិងប៉ាន់ស្មាននូវចំនួន និងរឿងហេតុទាំងអស់នៃការជំទាស់ ដើម្បីគណនាថាតើយើងកំណត់ពេលវេលាមួយព្រឹកមួយថ្ងៃ ឬក៏ប៉ុន្មានថ្ងៃ? ដើម្បីដោះស្រាយបញ្ហាជំទាស់នៅលើបណ្ដឹងដើមបណ្ដឹងរដ្ឋប្បវេណីចំនួនជាក់លាក់ដែលមេធាវីការពារក្ដីនឹងជំទាស់តែប៉ុណ្ណោះ ។

ដូច្នេះ វេទិកានេះយើងមិនមែនវេទិកាយកជជែកថា ជាការជំទាស់ទេ គ្រាន់តែជាការជូនដំណឹងឲ្យបានត្រៀមខ្លួនជាស្រេចប៉ុណ្ណោះ។ ទីមួយ គឺយើងបញ្ជាក់ថាយើងបានប្រកាសដាក់នូវឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ ហើយប្រសិនបើឯកសារណាមានបញ្ហា មានការតវ៉ាយើងនឹងកំណត់កាលវិភាគក្នុងការជជែកដេញដោលនៅលើបញ្ហានេះទៅតាមស្ថានភាពជាក់ស្ដែងនៃករណីដែលមានបញ្ហា ។

[០៩:៣១:១១]

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំមិនជំទាស់ទេ ។ ខ្ញុំចង់ជម្រាបមេធាវីការពារក្ដីថា E2/52 នោះ អឺ! E2/50 នោះប្រសិនបើគាត់ចង់បាននោះយើងមានវត្ថុតាង ឬក៏ព័ត៌មានផ្សេងៗដែលអាចដោះស្រាយទៅលើបញ្ហានេះបាន ។ ដូច្នេះខ្ញុំគ្រាន់តែជូនដំណឹងទៅខាងមេធាវីការពារក្ដីថា យើងមានឯកសារនោះដែលចាំបាច់សម្រាប់ខាងភាគីការពារ ។

**ប្រធានអង្គជំនុំ៖**

បញ្ហាពាក់ព័ន្ធទៅនឹងការដាក់ឯកសារនៃដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនត្រូវបានកោះហៅមក

ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គឺសម្រេចបញ្ឈប់ការពិភាក្សាផ្តល់យោបល់ត្រឹមនេះ ។ ហើយដោយសារហេតុនេះ យើងគ្រាន់តែជាការជម្រាបជូនដំណឹងហើយពេលវេលាក្នុងការជជែកដេញដោលនោះ គឺយើងបានកំណត់ជាក់លាក់ហើយនៅព្រឹកថ្ងៃច័ន្ទទី១៧ ខែសីហា ឆ្នាំ២០០៩ ខាងមុខ ។

[០៩:៣២:៣៧]

អ្នកបកប្រែឮទេ?ៗ

**អ្នកបកប្រែ៖**

លោកចៅក្រម យើងខ្ញុំបានឮចៅក្រមប្រធានមានប្រសាសន៍ហើយ ក៏ប៉ុន្តែ យើងហាក់បីដូចជាមានបញ្ហាទំនាក់ទំនងទៅខាងភាសាបារាំង ។

**ប្រធានអង្គជំនុំ៖**

ឥឡូវសាកល្បងមើលតើអាចយ៉ាងម៉េចបាន? សាកល្បងម្តងទៀតមើល៍! មន្ត្រីតុលាការសម្របសម្រួលជាមួយនឹងខាងអ្នកបកប្រែភាសាដើម្បីឲ្យដំណើរការល្អឡើងវិញ ។

**អ្នកបកប្រែ៖**

បាទ, ជម្រាបលោកប្រធាន! ឧបករណ៍ដំណើរការធម្មតាហើយ។

[០៩:៣៤:១៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចបញ្ឈប់នូវការកត់សម្គាល់អំពីបញ្ហាដែលអង្គជំនុំជម្រះ បានណែនាំដល់មេធាវីការពារក្តីពាក់ព័ន្ធទៅជាមួយនឹងការដាក់ឯកសារ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនហុកសិបប្រាំមួយនាក់ ដែលអង្គជំនុំជម្រះសម្រេចមិនយកគាត់មកឲ្យធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះ ។

ដោយហេតុបញ្ហានេះ គឺគ្រាន់តែជាការផ្តល់ព័ត៌មានដើម្បីឲ្យភាគីមេធាវីតំណាងដើមបណ្តឹងរដ្ឋ-ប្បវេណីត្រៀមខ្លួនពិនិត្យនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ។ ហើយធ្វើការកត់សម្គាល់នឹងបញ្ជាក់អំពីការជំទាស់របស់ខ្លួននៅលើពាក្យបណ្តឹងទាំងឡាយណាដែលខ្លួនយល់ឃើញថា មានភាពមិនសមស្រប ឬក៏មានហេតុផលផ្សេងៗដែលមិនគប្បីជំទាស់ទៅនឹងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងហុកសិបប្រាំមួយនាក់ ។ ហើយជាបន្តទៀតនេះអង្គជំនុំជម្រះសម្រេចធ្វើដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សីឈ្មោះ ឈុន ផល ។

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សាក្សីតើលោកឈ្មោះ ឈុន ផល អ៊ីចឹងពិតមែនទេ?

**ផ៖** បាទ ខ្ញុំបាទឈ្មោះ ពិតមែន ។

**ស៖** ក្រៅពីឈ្មោះផល តើលោកដែលប្រើប្រាស់ឈ្មោះផ្សេងទៀតដែរឬទេ?

**ផ៖** ទេ ។

**ស៖** លោក ឈុន ផល តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ផ៖** (មិនឮសំឡេង)

**ស៖** លោក ឈុន ផល មិនគប្បីនិយាយមុនពេលសញ្ញាភ្លើងក្រហមនៅក្បាលមេក្រូនេះទេ ចាំរង់ចាំភ្លើងសញ្ញាក្រហមនឹងចេញទើបលោកចាប់ផ្តើមនិយាយ ដើម្បីឲ្យសំឡេងរបស់លោកស្រូបចូលទៅក្នុង*អូឌីយ៉ូ*នៃប្រព័ន្ធសំឡេងនៅទីនេះ ដោយធ្វើការប្រតិចារឹក ធ្វើការកត់ត្រាផង ហើយប្រព័ន្ធមានការបកប្រែទៅជាភាសាបារាំងនិងភាសាអង់គ្លេស សម្រាប់អ្នកដែលចូលរួមទាំងអស់នេះផងដែរ ។ លោកយល់ដែរទេ? លោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ផ៖** ខ្ញុំបាទ មានអាយុ ៤៧ឆ្នាំ ។

[០៩:៣៧:០៣]

**ស៖** លោកប្រកបមុខរបររកស៊ីអ្វីដែរសព្វថ្ងៃនេះ?

**ផ៖** ធ្វើស្រែ ។

**ស៖** តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា លោកពុំមានចំណងញាតិលោហិត ញាតិពន្ធ ឬសហពន្ធជាមួយនឹងភាគីនៃរឿងក្តីនេះទេ ។ ហើយបានរាយការណ៍ថា លោកបានស្បថរួចហើយមុននឹងចូលមកកាន់សាលសវនាការនេះ ។ តើជាការពិតមែនដែរឬទេ?

**ផ៖** ស្តាប់អត់ទាន់ទេ ។ សូមសួរម្តងទៀត ។

**ស៖** តាមរបាយការណ៍របស់ក្រឡាបញ្ជីអម្បាញ់មិញនេះ ថាលោកពុំមានចំណងញាតិលោហិតឬក៏ញាតិពន្ធ បានន័យថាបងប្អូនសាច់ញាតិ ញាតិសន្តានជាមួយនឹងភាគីនៃរឿងក្តីនេះទេ តើពិតមែនដែរឬទេ?

**ផ៖** ពិតមែន ។

**ស៖** ហើយក្រឡាបញ្ជីបានរាយការណ៍ទៀតថា លោកបានស្បថរួចហើយមុននឹងចូលមកកាន់សាលសវនាការនេះ ។ តើពិតមែនដែរឬទេ?

**ផ៖** ពិតមែន ។

**ស៖** មុននឹងស្តាប់សក្ខីកម្មក្នុងនាមលោកជាសាក្សី យើងប្រាប់អំពីសិទ្ធិនឹងករណីកិច្ចដល់សាក្សីដូចខាងក្រោមនេះ៖

លោក ឈុន ផល ក្នុងនាមលោកជាសាក្សី លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរឬអំណះអំណាងណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើកខ្លួនលោក សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ។ មានន័យថា ដោយសារតែចម្លើយ ឬក៏អំណះអំណាងទាំងនោះនាំឱ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់ ។ ទន្ទឹមនឹងនេះលោក ឈុន ផល ក្នុងនាមលោកជាសាក្សី លោកមានករណីយកិច្ចនិយាយតែការណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮដោយផ្ទាល់ ហើយនៅក្នុងការផ្តល់សក្ខីកម្មរបស់លោក លោកមិនគប្បីផ្តល់សក្ខីកម្មជាសេចក្តីសន្និដ្ឋាននោះទេ ។

លោក ឈុន ផល តើលោកចូលក្នុងចលនាបដិវត្តន៍ ឬក៏កងកម្លាំងបដិវត្តន៍ចាប់ពីពេលណាមក?

[០៩:៣៩:៥៥]

**ផ៖** ខ្ញុំបាទចូលបដិវត្តន៍នៅឆ្នាំ៧៥ ។

**ស៖** នៅក្នុងខែណាដែរ លោកចងចាំដែរឬទេ?

**ផ៖** បាទ, អត់បានចាំទេ ។

**ស៖** លោកចូលក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ឬក៏មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥?

**ផ៖** ចូលឆ្នាំ៧៥ ក្រោយទេ ។

**ស៖** ពេលចូលដំបូងហ្នឹង ចូលនៅទីកន្លែងណា? ហើយចូលធ្វើការងារអ្វី?

**ផ៖** ចូលមុនដំបូង ចូលមកតាមរយៈភូមិ ។

**ស៖** ភូមិឈ្មោះ ភូមិអីគេ? ហើយភូមិនោះនៅក្នុងឃុំណា? ស្រុកណា? ខេត្តណាដែរ?

**ផ៖** (ស្តាប់មិនឮ) ឃុំចោងម៉ោង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

**ស៖** ហើយក្រោយពីចូលនៅភូមិនោះមក តើគេបញ្ជូនលោកមកឱ្យធ្វើការនៅកន្លែងណា?

**ផ៖** គេបញ្ជូនខ្ញុំមកនៅសាលាលេខ៥ ។

**ស៖** គេបញ្ជូនលោកមកនៅសាលាលេខ៥ គេឲ្យលោកធ្វើអ្វី? ហើយធ្វើការនៅទីនោះអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** គ្រាន់តែសម្រាកនៅឡើយទេ ។

**ស៖** លោកនៅសាលាលេខ៥ អស់រយៈពេលប៉ុន្មានទើបគេបញ្ជូនចេញពីសាលាលេខ៥ ចេញមកកន្លែងផ្សេងទៀត?

**ឆ៖** នៅចំនួនប្រហែលមួយអាទិត្យ ។

**ស៖** ហើយគេបញ្ជូនលោកទៅកាន់ទីណា?

**ឆ៖** បញ្ជូនមកកាន់នៅបឹងទំពុន ។

**ស៖** គេបញ្ជូនលោកមកបឹងទំពុនហ្នឹង មកនៅពេលណា? ហើយមកឲ្យលោកធ្វើអ្វីដែរ នៅទីនោះ?

**ឆ៖** ស្តាប់អត់ទាន់សូម-- ។

**ស៖** ពេលគេបញ្ជូនលោកមកកាន់-- មកនៅកន្លែងបឹងទំពុនហ្នឹង ថាតើគេបញ្ជូនលោកហ្នឹងមកដល់បឹងទំពុននឹងនៅពេលណា? បានន័យថា នៅថ្ងៃខែឆ្នាំណា? លោកចាំដែរឬទេ? ហើយពេលដែលលោកមកដល់បឹងទំពុននុ៎ង គេឲ្យលោកធ្វើអ្វីដែរ?

**ឆ៖** គេបញ្ជូនខ្ញុំមកដល់បឹងទំពុនគ្រាន់តែឲ្យសម្រាកនិងនៅកន្លែងនោះមួយរយៈ ។

**ស៖** ក្រោយពីមកដល់បឹងទំពុន ហើយនឹងបានសម្រាកមួយរយៈមក តើគេបញ្ជូនលោកឲ្យមកធ្វើការនៅកន្លែងណា?

**ឆ៖** ក្រោយមកទៀតអស់រយៈពេលមួយខែ ឬមួយកន្លះខែមិនដឹងខ្ញុំមិនបានចាំ ។ ក្រោយមកទៀតគេបានបញ្ជូនខ្ញុំមកតាខ្មៅ ។

[០៩:៤៥:២១]

**ស៖** គេបញ្ជូនលោកទៅតាខ្មៅហ្នឹង ទៅដល់តាខ្មៅគេឲ្យលោកធ្វើការងារអ្វីដែរ?

**ឆ៖** ទៅដល់តាខ្មៅគេឲ្យរៀនអំពីក្បាច់យុទ្ធសាស្ត្រ ក្បាច់ច្បាប់ទាហាន ។

**ស៖** អ៊ីចឹងបានន័យថា លោកទៅទីនោះ គឺលោកទៅចូលហាត់រៀននៅសាលារៀនមួយ សាលាហ្វឹកហ្វឺនយោធាហ្នឹងមែនទេ?

**ឆ៖** បាទ, មែន ។

[០៩:៤៥:00]

**ស៖** អ៊ីចឹងបានន័យថា លោកទៅទីនោះ គឺលោកទៅចូលហាត់រៀននៅរៀនសាលាមួយ ។ សាលាហ្វឹកហ្វឺនយោធាហ្នឹងមែនទេ?

**ឆ៖** បាទ, មែន ។

**ស៖** លោកទៅហាត់ហ្វឹកហ្វឺននៅសាលាបច្ចេកទេសយោធា នៅតាខ្មៅហ្នឹងអស់រយៈពេលប៉ុន្មានដែរ នៅទីនោះ?

**ឆ៖** ទៅហាត់នៅ-- ដែលសាលាយោធាតាខ្មៅអស់រយៈប៉ុន្មាន ខ្ញុំមិនបានចំណាំចាំពិតប្រាកដនោះទេ ។

**ស៖** ក្រោយពីហាត់នៅសាលាយោធាតាខ្មៅចប់នុ៎ង តើគេបញ្ជូនលោកទៅកាន់ទីណាដែរ?

**ឆ៖** បញ្ចប់ការសិក្សា ការហាត់នៅសាលារួច គេបានបញ្ជូនខ្ញុំទៅនៅព្រៃស ។

**ស៖** លោកទៅ គេបញ្ជូនលោកទៅនៅព្រៃសហ្នឹង តើនៅព្រៃសហ្នឹង គេឲ្យលោកធ្វើការងារអ្វីនៅទីនោះ?

**ឆ៖** គេបញ្ជូនខ្ញុំឲ្យទៅនៅព្រៃស ដើម្បីឲ្យធ្វើស្រែ ធ្វើប្រឡាយទឹក ។

**ស៖** លោកចាំទេ កាលដែលគេបញ្ជូនលោកពីកំពង់ឆ្នាំងមកភ្នំពេញ ហើយមកហាត់បច្ចេកទេសកងទ័ព ហើយនិងរួចបញ្ជូនលោកទៅកាន់ធ្វើស្រែនិងជីកប្រឡាយ លើកទំនប់នៅព្រៃសនោះ តើកាលនោះ លោកអាយុប៉ុន្មានឆ្នាំ?

**ឆ៖** នៅពេលៗ ខ្ញុំគេបញ្ជូនទៅនៅព្រៃស ខ្ញុំមានអាយុប្រហែល១៥ឆ្នាំ ។

**ស៖** ក្រោយពីការលោកធ្វើការនៅព្រៃស តើគេបានបញ្ជូនលោកទៅធ្វើការនៅកន្លែងណាទៀត?

**ឆ៖** រយៈពេលក្រោយពីចេញពីព្រៃសមកទៀត គេបញ្ជូនខ្ញុំមកនៅទួលស្លែង ។

**ស៖** លោកនិយាយថា ទួលស្លែងហ្នឹង កន្លែងទួលស្លែងហ្នឹង នៅឯណា តាមលោកដឹង? ហើយកន្លែងនោះ គេធ្វើអ្វីនៅទីនោះ?

**ឆ៖** កន្លែងនោះ ដែលគេឲ្យខ្ញុំទៅគឺគេឲ្យខ្ញុំទៅចូលធ្វើការខាងយាម ។

**ស៖** ទួលស្លែង អំមិញលោកថាទួលស្លែងនោះ ទួលស្លែងដែលលោកតាមលោកចំណាំហ្នឹង កាលនុ៎ង លោកថាគេបញ្ជូនលោកឲ្យធ្វើការនៅទួលស្លែង ។ សំណួរសួរថា តើទួលស្លែងហ្នឹង នៅកន្លែងណា? នៅក្នុងខេត្តក្រុងណា? ទីណាទួលស្លែងនុ៎ង?

**ធ៖** ខ្ញុំអត់បានដឹងខេត្ត ដឹងក្រុង នៅទីណាទេ ។

**ស៖** ហើយកាលនោះ គេហៅថាទួលស្លែង អ៊ីចឹង? ឬក៏គេហៅឈ្មោះផ្សេងពីនេះ កន្លែងដែលលោកធ្វើការកាលនោះ ។ កាលពីលោកទៅដល់ទីនុំង គេហៅកន្លែងនុំង គេហៅអី? គេហៅកន្លែងអីគេ?

**ធ៖** ទៅដល់គេហៅថា កន្លែងស-២១ ប៉ុន្តែគេថាហៅ ទួលស្លែង ផង ។

[០៩:៤៩:១៧]

**ស៖** លោកនិយាយថា ពេលដែលលោកទៅដល់ទួលស្លែង លោកគេឲ្យធ្វើអ្នកយាម ។ លោកយាមស្អីគេ?

**ធ៖** អ្នកយាមអ្នកទោស ។

**ស៖** លោកធ្វើជាអ្នកយាមអ្នកទោស តើលោកជាអ្នកយាមខាងក្រៅ ឬក៏ជាអ្នកយាមខាងក្នុង?

**ធ៖** ខ្ញុំយាមខាងក្នុង ។

**ស៖** ហើយកាលដែលលោកយាមខាងក្នុងហ្នឹង តើគេឲ្យលោកធ្វើការងារអ្វីខ្លះដែរ?

**ធ៖** គេឲ្យធ្វើការងារត្រួតពិនិត្យអ្នកទោស។ ពិនិត្យអ្នកទោសនៅពេលដែលគេយកមកពីនេះពីនោះ មកដើម្បីឲ្យខ្ញុំនៅយាមមើលការខុសត្រូវកន្លែងនោះ ។

**ស៖** លោកយាមខាងក្នុងហ្នឹងមានន័យថាម៉េច? យាមខាងក្នុងបន្ទប់ឃុំឃាំង ឬក៏ខាងក្នុងទីតាំងបរិវេណនៃអគារឃុំឃាំង ដែលគេដាក់ឃុំឃាំងមនុស្ស?

**ធ៖** យាមនៅក្នុងអគារ ។

**ស៖** លោកចាំទេ ថាលោកនៅទីនោះ មានអគារឃុំឃាំងហ្នឹងប៉ុន្មានដែរ? ហើយលោកនៅយាមអ្នកទោសនៅអគារឃុំឃាំងមួយណា?

**ធ៖** យាមនៅអគារទីពីរ ។

**ស៖** លោកចងចាំទេ អគារទីពីរហ្នឹង? បើលោកប្រៀបធៀបមើ តើអគារហ្នឹងទទឹងថ្ងៃ ឬក៏បណ្តោយថ្ងៃ?

**ធ៖** អគារនុំង បណ្តោយថ្ងៃ ។

**ស៖** នៅទីនោះមានប៉ុន្មានអគារ? ដែលលោក-- តាមលោកចងចាំនៅកន្លែងទួលស្លែង ដែលលោកនិយាយថា គុកទួលស្លែង ហ្នឹង តើមានប៉ុន្មានអគារនៃអគារឃុំខ្លួនហ្នឹង មានប៉ុន្មានដែរ ដែលលោកចងចាំ?

**ឆ៖** មានបួនអគារ ។

**ស៖** លោករាប់មើលអគារណាខ្លះ? ហើយអគារនីមួយៗមានទីតាំងនៅកន្លែងណា?

**ឆ៖** ខ្ញុំអត់បានដឹងពីរឿងអគារនៅទីតាំងកន្លែងណាៗ ខ្ញុំដូចភ្លេចបាត់ដែរហើយហ្នឹង ។

**ស៖** កាលនោះ លោកចូលទៅក្នុងនៃមន្ទីរស-២១ លោកទៅធ្វើការនៅនុ៎ងមន្ទីរស-២១ តើលោកចូលតាមច្រកណា? ច្រកពីទិសខាងណា?

**ឆ៖** កាលពីខ្ញុំធ្វើការនៅកន្លែងនោះ ចូលមកដល់បច្ចុប្បន្ននេះ ខ្ញុំភ្លេចមិនដឹងជាចូលទៅណាផង ព្រោះខ្ញុំភ្លេចបាត់ហើយ បើដល់រាល់ថ្ងៃហ្នឹង ។

**ស៖** ចុះមិញលោកបានឆ្លើយថា អគារទីពីរ ។ ចុះអគារទីមួយ នៅខាងៗណាខាងអគារទីពីរ?

[០៩:៥៤:00]

**ឆ៖** សុំសន្មតថា អគារទីមួយ និងអគារទីពីរ វាមានបន្ទាប់ពីមួយទៅ វាដល់មួយ ។

**ស៖** បន្ទាប់ពីអគារទីមួយ ទៅដល់មួយម៉េច? មានតែដល់អគារ-- បន្ទាប់ពីមួយទៅដល់អគារទីពីរ ។ អ៊ីចឹងអី? បន្ទាប់ពីអគារទីមួយ ដល់មួយ បានន័យថា ដល់អគារទីមួយ បន្ទាប់មកអគារទីពីរ ។ អ៊ីចឹងមែនទេ?

**ឆ៖** (មិនឮសំឡេង)

**ស៖** ចុះអគារទីបី នៅខាងណា? អគារទីបី? អគារទីបួន? នៅខាងណាអគារទីពីរ?

**ឆ៖** នៅអគារវាមានដង្ហែ-- អាហ្នឹងខ្ញុំបើរឿងត្បូងលិចកើត ខ្ញុំភ្លេចអស់ហើយ។ បើអគារហ្នឹងវាមានដូចថា ពីរខាងត្បូង-- ពីរនៅមួយចំហៀង ។ មួយនៅខាងៗ តែមិនដឹងខាងណាលិច ខាងណាកើតខ្ញុំមិនបានចាំ មកដល់រាល់ថ្ងៃហ្នឹងទេ ។

**ស៖** អ៊ីចឹងបានន័យថា អគារពីរនៅទទឹមគ្នា ។ ហើយអគារពីរទៀត មួយនៅម្ខាង អ៊ីចឹង?

**ឆ៖** វានៅខាងនេះមួយៗ នៅបន្តគ្នាចេះពីរ ។ ប៉ុន្តែខាងណាត្បូង ខាងណាជើង ខ្ញុំអត់បានចាំទេ កាលនុ៎ង ខ្ញុំនៅកន្លែងនោះ មកដល់រាល់ថ្ងៃហ្នឹង ដូចវង្វេងដែរទៅហើយ ។ ប៉ុន្តែ គ្រាន់ចំណាំរបស់នោះ វាមានប៉ុននុ៎ង ។

**ស៖** ហើយលោកគេឲ្យធ្វើយាមនៅអគារលេខពីរ ដែលលោកចង់ចាំ ។ អ៊ីចឹងមែនទេ?

**ឆ៖** នៅអគារទីពីរ ។

**ស៖** លោកយាមហ្នឹង លោកនិយាយមើល៍ តើពាក្យថា យាមហ្នឹង តើគេឲ្យលោកការងារហ្នឹង យ៉ាងដូចម្ដេចខ្លះ?

**ឆ៖** ឲ្យធ្វើការគ្រាន់តែត្រួតអ្នកទោសនៅក្នុងបរិវេណ មើលការខុសត្រូវក្នុងកន្លែងតែប៉ុណ្ណោះ។

**ស៖** អគារហ្នឹងសង់ផ្ទាល់ដី ឬក៏អគារហ្នឹង សងខ្ពស់ច្រើនជាន់?

**ឆ៖** អគារមានកម្ពស់បីជាន់ ។

**ស៖** ហើយអគារហ្នឹង សង់អំពីឈើ ឬសង់អំពីថ្ម?

**ឆ៖** សង់អំពីថ្ម ។

**ស៖** ហើយលោកគេយាមនៅអគារទីពីរហ្នឹង នៅបន្ទប់ណាមួយ? ឬក៏នៅជាន់ណាមួយ?

**ឆ៖** នៅយាមធ្វើការមិនទៀង ។ ចួនកាល គេទៅលើ ។ ចួនកាល គេចាត់តាំងឲ្យមកក្រោម ។ ចួនកាលក៏លើបំផុត ។ ចួនកាល ក៏កណ្ដាលអ៊ីចឹងទៅ តាមដែលមេក្រុម ការចាត់ចែង ចាត់តាំងឲ្យធ្វើ ។

[០៩:៥៧:៥០]

**ស៖** ហើយការយាមរបស់លោកហ្នឹង លោកគេឲ្យយាមអ្នកទោសហ្នឹង ក្នុងមួយថ្ងៃហ្នឹង យាមប៉ុន្មានពេល? ហើយលោកយាមពេលណា? ហើយមួយពេលហ្នឹងមានគ្នាប៉ុន្មាននាក់ជាមួយលោក?

**ឆ៖** ពេលចូលយាមមាន ចំនួនគ្នាមួយក្រុម ។ ប្រហែលជាដប់ពីរនាក់ ។

**ស៖** ចុះវេនយាម គេចែកឲ្យលោកយាមកាមហ្នឹងយ៉ាងដូចម្ដេចទៅ?

**ឆ៖** ការយាមកាម មេក្រុមបានបង្គាប់ថា ឲ្យមើលអ្នកទោសក្រែងលោរត់រួច ឬមួយចង់កសម្លាប់ខ្លួន ។

**ស៖** តាមធម្មតាលោកយាមនៅពេលណា? ក្នុងមួយថ្ងៃម្ភៃបួនម៉ោង មួយថ្ងៃមួយយប់អ៊ីចឹង តើលោក-- ក្រុមលោកហ្នឹងគេឲ្យយាមនៅពេលណាថ្ងៃ? ឬក៏ពេលយប់? ឬក៏ទាំងថ្ងៃទាំងយប់ ឆ្លាស់គ្នា ហើយយាមក្នុងមួយថ្ងៃហ្នឹង ប៉ុន្មានវេន? ហើយមួយវេនៗម្ដងហ្នឹង យាមប៉ុន្មានម៉ោង?

**ឆ៖** ក្នុងមួយវេន បើយាមពីម៉ោងប្រាំមួយ ប្រាំមួយកន្លះ ឬមួយម៉ោងប្រាំពីរ ដល់ម៉ោងដប់ពីរដូរគ្នា ។

**ស៖** អ្នកយាមវេនពេលថ្ងៃហ្នឹងទៅដល់ពេលយប់ យាមទៀតដែរឬទេ?

**ឆ៖** ពេលយាមពេលថ្ងៃដូរគ្នានៅម៉ោងដប់ពីរថ្ងៃ ទៅដល់ម៉ោងបួនល្ងាច ឬមួយម៉ោងបួនល្ងាចចូលមកដូរគ្នាវិញ ។ ខ្ញុំបាទយាមយប់ម្ដង ។

**ស៖** នៅពេលដែលលោកចូលយាម គ្រប់ពេលដែលលោកយាមហ្នឹង តើលោកយាមនៅពីខាងក្រៅនៃបន្ទប់ឃុំឃាំងអ្នកទោស ឬក៏ចូលទៅឈរនៅក្នុងបន្ទប់ឃុំឃាំងអ្នកទោស ហើយមើលឈរមើលអ្នកទោសផ្ទាល់ដូច្នេះ នៅក្នុងបន្ទប់ឃុំឃាំងនោះ?

**ឆ៖** ខ្ញុំបាទដែលគេឲ្យយាមនៅកន្លែងនោះ មិនបានឈរជាមួយអ្នកទោសនៅក្នុងបន្ទប់ផ្ទាល់នោះទេ ។ ហើយដែលផ្ទះនោះគេបានវាយជញ្ជាំងទម្លាយទាំងអស់ គេឲ្យយើងគ្រាន់តែដើរមើលដូចតែតាមប្រឡោះៗហ្នឹងអ៊ីចឹងទៅ ប៉ុន្តែ មានអ្នកទោសនៅក្នុងបន្ទប់សងខាង ។

**ស៖** បានន័យថា កន្លែងដែលអគារដែលលោកយាមហ្នឹង គឺគេដាក់អ្នកទោសហ្នឹងបន្ទប់ឃុំឃាំងតូចៗម្នាក់ៗហ្នឹង ឬក៏បន្ទប់មានបន្ទប់ឃុំឃាំងរួម បានន័យថា បន្ទប់មួយហ្នឹងមានគេដាក់ឃុំឃាំងមនុស្សអ្នកទោសហ្នឹងច្រើននាក់ដែរ?

**ឆ៖** មានតែ មានបន្ទប់ដាក់ដាច់ៗពីគ្នាតូចៗក៏មាន បន្ទប់ថ្នាក់ជាន់ខ្ពស់ដាក់ជារួមក៏មាន ។

**ស៖** ពេលលោកដើរយាមមើលតាមបន្ទប់ឃុំឃាំង ដាច់ៗដោយឡែកគ្នាហ្នឹង តើលោកមើលយ៉ាងម៉េចទៅ ប្រសិនបើនៅក្នុងបន្ទប់ឃុំឃាំងមួយៗហ្នឹង តើលោកដើរមើលយ៉ាងម៉េច?

**ឆ៖** ដើរមើលកន្លែងនោះដូចខ្ញុំបានឃើញពីអង្កាល់ ដែលខ្ញុំគេឲ្យធ្វើការនៅកន្លែងនោះ គេមានដាក់បន្ទប់តូចៗ ហើយគេចោះ គេធ្វើជាបង្អួច យើងសម្រាប់នឹងអើតមើល អាចមើលឃើញទាំងសងខាង ។ ហើយគ្រាន់តែពិនិត្យសោដែលដាក់ទៅតាមប្រឡោះៗមកហ្នឹង ក្រែងលោវាវបូតវាអី គេឲ្យយើងឧស្សាហ៍ត្រួត ឧស្សាហ៍ពិនិត្យ ។

**ស៖** ចុះបន្ទប់តូចដែលលោកដើរយាមអ៊ីចឹង បើសិនជានៅពេលយប់លោកមើលម៉េចឃើញ បើងងឹត លោកមើលសោ មើលស្ថានភាពនៃអ្នកទោសយ៉ាងម៉េចឃើញ ប្រសិនបើលោកយាមនៅពេលយប់នោះ?

**ឆ៖** យាមនៅពេលយប់មានភ្លើងអគ្គិសនី បើកវាស់ព្រឹក ។

**ស៖** បន្ទប់ៗដោយឡែកហ្នឹង តើមានអំពូលភ្លើងភ្លឺ អាចមើលឃើញអ្នកទោស ឬក៏មើលសោមើលច្រវាក់អីបានដែរឬទេ?

**ឆ៖** ភ្លើងដាក់ បើតាមខ្ញុំចំណាំចាំបាន ដាក់មួយមើលឃើញសម្រាប់ពិនិត្យ ។

**ស៖** ចុះករណីលោកយាមនៅជាន់ ដែលមានបន្ទប់ឃុំឃាំងរួមវិញ តើរបៀបនៃការយាមកាមរបស់លោកហ្នឹង លោកយាមដូចម្តេច?

**ឆ៖** ការយាមបន្ទប់ដាក់រួម យាមដាក់អ្នកទោសគេដាក់នៅខាងក្នុង ខ្ញុំគ្រាន់តែដើរត្រួតនៅពីខាងយ៉ខាងក្រៅ ហើយមើលទៅក្នុងតែប៉ុណ្ណោះ ។

**សៈ** ចុះប្រសិនបើ-- អ៊ន៎ែ លោកដែលបាន-- ក្នុងអំឡុងពេលដែលលោកយាមហ្នឹង លោកដែលបានឃើញនូវអ្នកទោសស្លាប់នៅក្នុងអំឡុងពេល ដែលជាប់ឃុំឃាំងដែរឬទេ?

**ឆ៖** ខ្ញុំយាមនៅពេលដែលវេនខ្ញុំចូលយាម ខ្ញុំមិនដែលបានឃើញអ្នកទោសស្លាប់ដែលពេលខ្ញុំយាមទេ ។

**សៈ** លោកបានកត់សម្គាល់នូវអ្នកទោសទាំងអស់ ទាំងបន្ទប់តូចទាំងបន្ទប់ធំ ដែលលោកដើរយាមប្រចាំជារៀងរាល់ថ្ងៃ រៀងរាល់ពេលដែលលោកយាមនោះ តើលោកឃើញកត់សម្គាល់ឃើញទិដ្ឋភាព ស្ថានភាពនៃរាងកាយរបស់អ្នកទោសទាំងនោះយ៉ាងដូចម្ដេចដែរ?

**ឆ៖** តាមខ្ញុំដើរយាមដើរត្រួតដើរពិនិត្យមើល ឃើញអ្នកទោសនុ៎ង ស្គមៗមិនសូវធាត់ទេ ព្រោះរបបវាដូចថា តូចតាច ដែលការខ្ញុំមើលឃើញ ប៉ុន្តែខ្ញុំមិនមែនអ្នករៀបបាយរៀបទឹកឲ្យអ្នកទោសទេ គឺគេមានគេអ្នករៀប គេអ្នកយកទៅឲ្យផ្សេង ។ ខ្ញុំគ្រាន់តែមានតួនាទីខាងពិនិត្យមើល និងមើលការខុសត្រូវតែប៉ុណ្ណឹង ។

**សៈ** អ្នកទោសដែលជាប់ឃុំឃាំង ដែលលោកបានមើលអម្បាញ់មិញហ្នឹង ទាំងបន្ទប់តូច ទាំងបន្ទប់ធំហ្នឹង តើគេលែងគាត់គ្រាន់តែដាក់ឃុំឃាំង ចាក់សោពីខាងក្រៅ ឬក៏នៅខាងក្នុងហ្នឹង គេត្រូវដាក់ខ្នោះជើង ឬក៏ខ្នោះដៃ ឬក៏យ៉ាងម៉េច? គេដាក់ខ្នោះជើងផង ឬក៏ដៃផង ឬក៏ដាក់តែខ្នោះជើង ឬក៏អ្នកទោសទាំងអស់នៅក្នុងបន្ទប់ឃុំឃាំងហ្នឹង គឺគេលែងទេ គេគ្រាន់តែចាក់សោពីខាងក្រៅទេ?

**ឆ៖** តាមខ្ញុំពិនិត្យមើលដែលអ្នកទោសនៅបន្ទប់ដែលដាក់ជាទូទៅ ជាគ្នាច្រើន បើខ្ញុំបានចាំច្បាស់បើប្រុសៗគេដាក់ខ្នោះជាខ្សែ គេដាក់ខ្នោះជាខ្សែ ខ្សែដែកហ្នឹងដាក់បួនប្រាំ-- បួនប្រាំមួយប្រាំពីរនាក់ បួនដប់នាក់អីចឹងទៅ គេកឹបសោរតែមួយ ។ បើហ្នឹងបើនិយាយពីរឿងប្រុសៗ បើរឿងស្រីតាមការខ្ញុំចាំពីឆ្នាំនោះមកដល់ឆ្នាំនេះ គេដាក់ជា ដូចថាយើងលែងទាំងអស់អីចឹងតែម្ដង ហើយប៉ុន្តែ គេគ្រាន់តែចាក់សោពីក្រៅ ។

[១០:០៥:២៤]

**សៈ** អ្នកទោសហ្នឹងអាចឈរបានទេ?

**ឆ៖** ស្ដាប់អត់ទាន់ ។

**ស៖** អ្នកទោសអំមិញថាអ្នកទោសហ្នឹង គឺអ្នកទោសដែលដាក់ជាប់ខ្នោះ អ្នកទោសប្រុសៗហ្នឹង ដាក់ជាប់ខ្នោះជើងនែ ហើយដាក់ជាសួរ ហើយសូម្បីតែនេះក៏ដាក់ខ្នោះដែរ ម្នាក់ៗហ្នឹងក៏ដាក់ខ្នោះដែរ ។ សំណួរថា អំឡុងពេលដែលដាក់ទោស អ្នកទោសដាក់ជាប់ខ្នោះជើងហ្នឹង សួរថាគាត់លទ្ធភាពគាត់អាចឈរបានទេ?

**ឆ៖** នៅពេលដែលងើបឈរ គឺអាចឈរបាន ព្រោះថាកងគេដាក់នុំងវាមានទំហំធំ មួយអាចមនុស្សងើបឈរបាន ប៉ុន្តែឈរទាល់តែ បើតាមខ្ញុំចាំច្បាស់ ទាល់តែយកឈើ-- យកដូចថា ដុំអីមួយអ៊ីចឹងទៅកល់ដាក់ពីក្រោមទៅបានឈរបាន បើងើបតែម្នាក់ឯងងើបអត់បានទេ ។ បើថាម្នាក់ឈរអ៊ីចឹងឈរបីបួននាក់ទាល់តែយើងកល់ បើថាឈរទាំងអស់គ្នា ហ្នឹងយើងមិនបាច់ចាំកល់ទេ ព្រោះវាបានកជើងច្រើន បើថា លើកឈរម្នាក់ទាល់តែយើងកល់ទៅបានឈរបាន ។

**ស៖** លោកដែលឃើញអ្នកទោស នៅក្នុងអំឡុងពេលជាប់ខ្នោះជើងហ្នឹងគាត់ឈរទេ?

**ឆ៖** ស្តាប់អត់ទាន់ទេ សុំសួរម្តង--

**ស៖** នៅក្នុងពេលដែលលោកមើលហ្នឹង ដែលលោកដែលឃើញថា ក្នុងអំឡុងពេលលោកយាមហ្នឹង ដែលឃើញអ្នកទោសក្រោកឈរដែរទេ?

**ឆ៖** អ្នកទោសបើតាមការយាម បើសិនណាគេចង់ក្រោកឈរទាល់តែសុំអ្នកយាមអ៊ីចឹងទៅ អ្នកយាមឲ្យគាត់ងើបបានគាត់ហ៊ានងើប បើសិនណាអ្នកយាមមិនទាន់មកដល់ទេ គឺថា គាត់អត់ហ៊ានងើបទេ ។

**ស៖** ចុះសម្លៀកបំពាក់ លោកឃើញយ៉ាងម៉េចដែរសម្លៀកបំពាក់របស់អ្នកទោសក្នុងអំឡុងពេលជាប់ខ្នោះជើងហ្នឹង ជាប់ឃុំឃាំងហ្នឹង តើសម្លៀកបំពាក់គាត់យ៉ាងម៉េចដែរ?

**ឆ៖** បញ្ហាការស្លៀកពាក់ហ្នឹង ដូចថាវាមិនដូចយើងធម្មតាទេ គឺស្លៀកពាក់ដូចថា វាចាស់ៗអ៊ីចឹងទៅ ឬមួយក៏វាមានខ្លី វាមានខើច អ្នកខ្លះអ៊ីចឹងទៅ ក៏ស្លៀកបានគ្រាន់វែងទៅ អ្នកខ្លះក៏ខ្លីអ៊ីចឹងទៅ អ្នកខ្លះអ៊ីចឹងក៏រហែកខ្លះអ៊ីចឹង ។ អ្នកខ្លះក៏មានផ្លាស់ប្តូរអ៊ីចឹង គេអ្នកយកខោអាវយកទៅឲ្យអ៊ីចឹងទៅ បើយកបានទៅ គេយកទៅ បើក្រយកទៅអ៊ីចឹងទៅ អត់អ៊ីចឹងទៅស្លៀកពាក់រហែករហែកអ៊ីចឹងដែរ ។

[១០:១២:៥៤]

**ស៖** ជាទូទៅ អ្នកទោសស្លៀកខោខ្លី ឬក៏ស្លៀកខោជើងវែង? ហើយពាក់អាវ ឬក៏មានតែខោអត់អាវទេ?

**ឆ៖** ខោ ចួនកាលស្លៀកតែខោ ខ្លះអត់មានអាវក៏មានដែរ ។ អ្នកស្លៀកខោមានអាវពាក់ក៏មានដែរ ហ្នឹងតាមបញ្ជាមេក្រុមគេការអនុញ្ញាតគេឲ្យស្លៀកឲ្យពាក់ ឬមួយគេថាថ្នាក់លើឲ្យស្លៀកឲ្យពាក់ ។

**ស៖** ចុះរបបហូបចុក ដែលលោកនិយាយអំមិញហ្នឹង ដែលថាអ្នកខ្លះស្គមខ្លាំង ស្គមស្គាំងខ្លាំង ហ្នឹងថាដោយសាររបបហូបចុក តើលោកដឹងទេថារបបហូបចុកហ្នឹង គេផ្តល់ឲ្យអ្នកទោសហ្នឹងយ៉ាងដូចម្តេចដែរ? ប៉ុន្មានពេលមួយថ្ងៃ ហើយក្នុងមួយពេលហ្នឹងមានស្ថានភាពយ៉ាងម៉េចដែរ? មានកម្រិតប៉ុនណាដែរ ជាបាយ ឬក៏ជាបបរ?

**ឆ៖** តាមខ្ញុំនៅចាំបាន របបហូប បបរ ។ បបរចំនួនមួយចានម្នាក់អ៊ីចឹងទៅ ចានយើងទៅតាមតូចតាមធំអ៊ីចឹងទៅ បើសិនជា ខ្ញុំកាលនៅកន្លែងនោះគេ ខ្លះគេថាខ្ញុំគ្រាន់តែមានតួនាទីខាងថា ត្រួតពិនិត្យក្នុងការយាម ក្នុងការបាយ ក្នុងការទឹក នេះគេថាគេអ្នកឲ្យផ្សេង គេថាមានអ្នកទោសពិសេស មានអ្នកទោសដែលត្រូវហូបចុកមានរបបខុសៗគ្នាហ្នឹងតាមគេអ្នកឲ្យ ខ្ញុំក៏ឃើញថា របបហ្នឹងវាមានខុសៗគ្នាអ៊ីចឹងដែរ ។

**ស៖** លោកដែលឃើញអ្នកទោសហ្នឹង គេឲ្យងូតទឹកដែរឬទេ? ហើយបើងូតទឹក ងូតទឹករបៀបម៉េច ប្រសិនបើគាត់ជាប់នៅក្នុងការឃុំឃាំងចាក់សោពីក្រៅហើយ ហើយជាប់ខ្នោះជើងដែលដើបស្ទើរតែមិនរួច ដូច្នេះតើការងូតទឹកហ្នឹងគេផ្តល់របប ឬក៏របៀបនៃងូតទឹកដល់អ្នកទោសហ្នឹងយ៉ាងដូចម្តេច?

**ឆ៖** ការដែលពេលងូតទឹក ពេលងូតទឹកត្រូវដូចថា ថ្ងៃហ្នឹង-- នេះបើសិនងូត មិនមែនថាងូតមួយថ្ងៃហ្នឹង ងូតតែម្នាក់ ឬមួយពីរទេ បើវេនប៉ះថ្ងៃណាត្រូវងូតទៅ គឺងូតទាំងអស់គ្នាហ្នឹងតែម្តង ។ ងូតទាំងអស់គ្នា ក៏មិនមែនគេឲ្យបទបញ្ជាពីថ្នាក់លើមកថា ឲ្យដោះ ឲ្យលែងមកងូតទេអានេះ ដូចថាអ្នកយាមហ្នឹងអ៊ីចឹង ដូចថាងូតរួចម្នាក់អ៊ីចឹងទៅ ទុយោយើង ទុយោគេបូមទឹកពីក្រោមអ៊ីចឹងទៅហ្នឹង អូសយកទៅឲ្យម្នាក់ៗ អាតាមបន្ទប់តូច ចេះតែងូតបន្តៗគ្នាអ៊ីចឹង ទាល់តែអស់គ្នាអ៊ីចឹងទៅ ។ ហ្នឹងតាមការដែលខ្ញុំចាំបាន ។

**ស៖** ចុះពួកជាប់ឃុំឃាំងកន្លែងបន្ទប់ឃុំឃាំងរួម គេងូតទឹកយ៉ាងដូចម្តេច?

**ឆ៖** ជាប់ឃុំឃាំងនៅជារួមហ្នឹង ដូចថាយើងមិនបាន-- យើងអត់ចូលទៅទេ កាលណាគេមានបទបញ្ជាពីថ្នាក់លើមកថា ឥឡូវពីថ្នាក់លើ ប៉ុន្តែថ្នាក់លើមិនដឹងជាថ្នាក់ត្រឹមប៉ុន្មានទេ ថ្នាក់ក្រុមមិនដឹងថ្នាក់ណាៗទៀតមិនដឹង គឺខ្ញុំមិនបាននេះដែរ ។ ប៉ុន្តែគ្រាន់តែថាទទួលផែនការពីរឿងក្រុម ក្រុមថាគេឲ្យអ្នកទោសងូតទឹក ងូតហើយ បើគេថាអត់ អត់នុ៎ងហើយ ។ ព្រោះថាស្រេចនឹងគេថ្នាក់លើៗ ខ្ញុំអត់បាន

ដឹងទេ រួចទាល់ហ្នឹងអ្នកងូតទឹកនៅជាន់រួម ពេលងូតអ៊ីចឹងទៅ គេបូមទឹកដាក់ទុយោទៅក្នុងហ្នឹងទៅ ឲ្យគេក្រោកឈរទៅ គេនាំគ្នាងូតទឹកទាំងអស់គ្នាអ៊ីចឹងទៅជារួមទាំងអស់គ្នា ប៉ុន្តែក្រោកឈរ យើងឲ្យទុយោទៅ ដើម្បីឲ្យគាត់ងូត គាត់លាងដុសក្អែល ដុសអីគ្នាគាត់ បើថារួចរាល់សព្វគ្រប់ហើយ យើងយកទឹកទុយោមកវិញមក ។

**ស៖** ចុះមានការដោះដូរសម្លៀកបំពាក់យ៉ាងដូចម្តេច ក្រោយពេលងូតទឹក?

**ឆ៖** តាមការខ្ញុំ ដែលចាំបាននៅចាំបាននេះ ប្រុសៗបានថាងូតទឹកមិនបានមានសម្លៀកបំពាក់នោះទេ ។

**ស៖** អត់មានសម្លៀកបំពាក់យ៉ាងម៉េច? ចុះសម្លៀកបំពាក់គាត់ស្លៀកគាត់ពាក់នៅជាប់ខ្លួនហ្នឹងធ្វើម៉េចបើអត់ស្លៀកសម្លៀកបំពាក់?

**ឆ៖** (អត់បើកមីក្រូហ្វូន) ។

**ស៖** ឈប់សិនកុំអាលឆ្លើយ ចាំភ្លើងក្រហមសិន ។

[១០:១៨:៥៣]

**ឆ៖** ពេលដែលគាត់ងូតទឹកហ្នឹង គាត់ដូចថា ខោអាវវាមានតិចអ៊ីចឹងទៅ ក៏ដូចថាមានតែទឹកទៅនឹង នាំគ្នាដូចថាអ្នកយាមហ្នឹង ក៏ប្រុស ហើយអ្នកទោសហ្នឹងក៏ប្រុសដែរ នាំគ្នាដូចថា បទបញ្ជាពីថ្នាក់លើទៅ គេអត់ឲ្យមានផ្លាស់មានប្តូរអ៊ីចឹងទៅ ក៏ទៅតាមហ្នឹងទៅ នាំគ្នាងូតស្រាតហ្នឹងទៅ អាខោអាវដោះទុកអ៊ីចឹងទៅ ដល់ពេលងូតរួច អីរួចនាំគ្នាស្លៀករៀងៗខ្លួនវិញទៅ ។ អាខោដែលជាប់ៗហ្នឹងខ្លួន អាខោដែលស្រាតមួយភ្លែតៗហ្នឹង ។

**ស៖** លោកដឹងថារបៀបគេស្រាតយ៉ាងម៉េចទៅ បើជើងជាប់ខ្នោះ ហើយអាខោស្លៀកជាប់ចង្កេះហើយជើងពីរ ហើយដល់ពេលស្រាតហ្នឹង ស្រាតយ៉ាងម៉េច បើអត់ខ្នោះចេញផង ស្រាតខោពីខ្លួនយ៉ាងម៉េចទៅ? លោកដែលកត់សម្គាល់ចំណុចនេះទេ?

**ឆ៖** ខោដែលស្រាតចេញពីខ្លួន ចួនកាលទៅខោ បើតាមខ្ញុំពិនិត្យឃើញ ខោស្លៀក ខោណាដែលស្តើងទៅ ខ្លះទៅក៏ អ្នកទោសខ្លះទៅ ក៏អាចថា គាត់អាចស្រាតបានចេញទៅតាមកងហ្នឹងទៅ អ្នកណាដែលឲ្យស្លៀកខោវែងអ៊ីចឹងទៅ ក៏ដាក់ត្រឹមជង្គង់អ៊ីចឹងទៅ ។ គាត់ហ្នឹង អ្នកទោសហ្នឹង គាត់ងូតទឹកដូចថានៅសល់ជើងមួយចំហៀងអ៊ីចឹង ព្រោះថាឥឡូវវាគ្នាច្រើន បើកាលណាអ្នកយាមតែម្នាក់ ឬមួយពីរ

ហ្នឹង កាលណាបើហូតទាំងអស់មកឲ្យផ្លាស់ខោផ្លាស់អាវ ច្បាស់ជាអត់កើតទប់មិនឈ្នះទេ ច្បាស់ជាខ្លាចដែរ ធ្លាក់លើអត់-- មួយរឿងហ្នឹងធ្លាក់លើគេអត់អនុគ្រោះឲ្យយើងធ្វើអ៊ីចឹង គេខ្លាចថាអ្នកទោសការតវ៉ាអ៊ីចឹងទៅ ។ ហ្នឹងបទបញ្ជាគេអ៊ីចឹងថា បើអ្នកងូត ងូតដោះស្រាតបានខ្លះ ងូតខ្លះ បើអត់ អត់ខ្លះអ៊ីចឹងទៅ ។

**ស៖** កន្លែងលោកយាមហ្នឹង តើលោកដែលឃើញជនជាតិបរទេសដែរឬទេ? ពួកបស្ចិមប្រទេសដូចជាពួកនៅឯនាយសមុទ្រអ៊ីចឹង ពួកស្បែកស ហើយនិងសក់ទង់ដែង សក់លឿងអ៊ីចឹង លោកដែលឃើញដែរឬទេ? មាឌធំៗនោះណាស់ នៅកន្លែងដែលលោកយាមនោះ លោកដែលឃើញទេ?

**ឆ៖** ជនខាងបរទេសធ្លាប់ឃើញដែរ ប៉ុន្តែឃើញតែគេដូចថា គេយកមកថ្មីៗ គេយកមកដូចថាដាក់ក្នុងបន្ទប់ដាក់អីហ្នឹង អីទៅ ចួនកាលខ្ញុំក៏មានការថាមួយយប់ ពីរយប់អ៊ីចឹងទៅ ក៏យាមមាន-- ក៏យាមហ្នឹងក៏មានការជួបខ្លះៗអ៊ីចឹង ។ ប៉ុន្តែ ជួបហ្នឹងមិនមែនមានពេល រយៈពេលយូរទេតែពីរថ្ងៃ ឬមួយ មួយថ្ងៃហ្នឹង គឺជនបរទេសកន្លែងខ្ញុំ ដែលខ្ញុំធ្វើការហ្នឹង ដែលខ្ញុំយាមហ្នឹងអត់មានទេ ដូចថាយកមកអ៊ីចឹង គ្រាន់តែដាក់មួយថ្ងៃ ពីរថ្ងៃអ៊ីចឹង ក៏គេបញ្ជូនបាត់អស់ទៅទេ ។

[១០:២២:២៦]

**ស៖** ការប្រព្រឹត្តិនូវរបៀបរបបដាក់ឃុំឃាំងអ្នកទោសហ្នឹង គេប្រព្រឹត្តដូចគ្នាជាមួយអ្នកទោសជាជនជាតិខ្មែរដែរទេ ដូចជាថានៅក្នុងឃុំខ្លួនហ្នឹង គេដាក់ខ្នោះជើង គេដោះខោអាវចេញទុកខោខ្លី ហើយដាក់ចាក់សោពីរក្រៅមួយជាន់ទៀតអ៊ីចឹងទេ? ហើយគេដាក់នៅក្នុងបន្ទប់ឃុំឃាំងដោយឡែកម្នាក់ៗ ឬក៏គេដាក់នៅក្នុងបន្ទប់ឃុំឃាំងរួមជាមួយហ្នឹងមនុស្សច្រើននាក់?

**ឆ៖** គឺអ្នកទោសមកពីបរទេសច្រើនតែយកមក យកមកគេដាក់បន្ទប់ផ្សេងៗមិនដាក់ឡូកឡំជាមួយនឹងជនជាតិខ្មែរយើងទេ ។

**ស៖** លោកដែលឃើញអ្នកទោស ជាជនជាតិវៀតណាមទេ ជាឈ្លើយសឹកវៀតណាម ដែលឃើញទេ?

**ឆ៖** ជនជាតិវៀតណាមធ្លាប់ឃើញ ។

**ស៖** នៅអគារលោកយាមហ្នឹង ពិតមែនដែរទេ?

**ឆ៖** ស្តាប់អត់បានអំមិញ ។

**ស៖** អ្នកទោសវៀតណាមទាំងអស់ហ្នឹង ដូចជាឈ្លើយសឹកវៀតណាមដែលគេដាក់ឃុំឃាំងនៅទីនោះ នៅកន្លែងអគារដែលលោកយាម គេចាត់ឲ្យលោកយាមនោះ ពិតមែនដែរឬទេ?

**ឆ៖** ដាក់អ្នកទោសនៅកន្លែងខ្ញុំបាទយាម តែដាក់ចួនកាលអត់បានយូរទេ បីថ្ងៃបួនថ្ងៃ ក៏ត្រូវបញ្ជូនយកទៅខាងណាវិញបាត់ដែរ ។

**ស៖** លោកឃើញអ្នកទោសជាជនជាតិវៀតណាមហ្នឹងមកដល់អ្នកឯង កន្លែងអ្នកឯងយាមហ្នឹង មានចំនួនច្រើននាក់ដែរទេ?

**ឆ៖** ខ្ញុំបាទមិនបានឃើញច្រើននាក់ទេ ឃើញចួនកាលពេលយូរអ៊ីចឹងទៅ ឃើញម្នាក់ ឃើញពីរនាក់ ឃើញបីនាក់ មិនឃើញតែម្តងឲ្យច្រើនទេ ។

**ស៖** នៅកន្លែងអគារអ្នកឯងយាមហ្នឹង អ្នកឯងឃើញអ្នកទោសជាស្ត្រីដែរទេ?

**ឆ៖** អ្នកទោសស្ត្រីធ្លាប់បានឃើញ ។

[១០:២៥:១៦]

**ស៖** មានចំនួនច្រើនទេ? ហើយគេឃុំឃាំងនៅកន្លែងណា? នៅបន្ទប់ឃុំឃាំងរួម ឬក៏បន្ទប់ឃុំឃាំងដោយឡែក?

**ឆ៖** ស្រី បើស្រី បើស្រីអ្នកទោសស្រី គេអាចឃុំឃាំងជារួម ។ ហើយបើដល់តែពេលដូចថាការងារថ្នាក់លើ អង្គការគេថា ឥឡូវត្រូវគេយកទៅយកឯកសារ ឬមួយយកស្អី ហ្នឹងគេបំបែកទៅតាមហ្នឹងដែរ ។

**ស៖** លោកដែលឃើញមានកុមារទេ ទៅដល់កន្លែងឃុំឃាំងនៃអគាររបស់លោកហ្នឹង តើមានកុមារទៅជាមួយនឹងស្ត្រីនៅក្នុងបន្ទប់ឃុំឃាំងទាំងនោះដែរឬទេ?

**ឆ៖** ក្មេងតូចៗមិនសូវជាមានច្រើនប៉ុន្មានទេ តាមដែលខ្ញុំមុខ-- កន្លែងខ្ញុំធ្វើការ ។ ឃើញចួនកាលទៅគេយកម្តាយមកអ៊ីចឹងទៅ ម្តាយមានកូនតូច ចួនកាលយូរៗអ៊ីចឹងទៅឃើញដោយមួយ យូរមានពីរអ៊ីចឹងទៅ ។ មិនមែនមានថា យកម្តងច្រើនៗ ច្រើនដូចថាគេយកម៉ែមកដោយកូនមក ។

**ស៖** លោកសង្កេតឃើញកូនទាំងអស់នោះ គេយកទៅទីណាក្រោយពីចាប់ឃុំឃាំងម្តាយ? កូនក្មេងដែលមកជាមួយម្តាយហ្នឹង តើគេយកក្មេងទាំងអស់នោះយកទៅទីណា? លោកដឹងដែរឬទេ?

**ឆ៖** នៅច្ចូនកាល ទៅនៅពីរបីថ្ងៃអ៊ីចឹង នៅជាប់ជាមួយម៉ែ ដល់រយៈពេលក្រោយទៅ ច្ចូនកាលក៏គេបំបែកគាត់ពីកន្លែងដាក់រួមហ្នឹងគេបញ្ជូនទៅកន្លែងផ្សេង តែមិនដឹងទៅបញ្ជូនទៅនៅកន្លែងណាវិញ។

**ស៖** ចុះទំនាក់ទំនងជាមួយនឹងការងារសួរចម្លើយ តើអ្នកសួរចម្លើយហ្នឹងមកយកអ្នកទោសទៅសួរចម្លើយហ្នឹង ការប្រគល់ទទួលអ្នកទោសពីកន្លែងបន្ទប់ឃុំឃាំងរួម ឬក៏ឃុំឃាំងដោយឡែកទៅឲ្យអ្នកសួរចម្លើយហ្នឹង ខាងណាជាអ្នកចាត់ការរឿងហ្នឹង ក្នុងការដោះខ្នោះចេញ រួចហើយប្រគល់ទៅឲ្យអ្នកសួរចម្លើយ ឬក៏បើក យើងបើកទ្វារឲ្យអ្នកសួរចម្លើយចូលយកអ្នកទោស ពីកន្លែងឃុំឃាំងហ្នឹងនាំទៅសួរចម្លើយដោយខ្លួនឯងរបស់អ្នកសួរចម្លើយ?

**ឆ៖** ខ្ញុំបាទបានពិនិត្យមើលឃើញអ្នកយកអ្នកទោសទៅសួរចម្លើយ គឺមិនមែនគេមកយក អ្នកសួរចម្លើយគេមកយកខ្លួនគេទេ គេមកយកដោះសោផ្ទាល់ពីក្នុងបន្ទប់យកទៅទេ គេមកដល់អ៊ីចឹង ដូចថាគេទាក់ទងជាមួយមេក្រុម មេអីអ៊ីចឹងទៅ មេក្រុមអនុញ្ញាតអ៊ីចឹងទៅ គេដោះគេអីអ៊ីចឹង បញ្ជូនទៅឲ្យអ្នកសួរចម្លើយទៅ ។ ហ្នឹងតាមការខ្ញុំនៅចាំបាន ។

[១០:២៨:៥៨]

**ស៖** ចុះពេលក្រោយពេលសួរចម្លើយចប់ ហើយគេយកត្រឡប់មកវិញ គេប្រព្រឹត្តយ៉ាងដូចម្តេច? បានន័យថាយកមកដល់ដាក់បញ្ចូល អ្នកសួរចម្លើយយកបញ្ចូលដល់ខាងក្នុង រៀបចំដាក់ខ្នោះជើង ឬក៏ដាក់ខ្នោះទាំងជើងទាំងដៃឡើងវិញ? ឬក៏យកមកគ្រាន់តែយកមកប្រគល់ឲ្យអ្នកយាមខាងក្នុងហ្នឹង អ្នកយាមខាងក្នុងចាត់ការនាំអ្នកទោស ដែលសួរចម្លើយរួចបន្តយកទៅដាក់ឃុំឃាំងនៅខាងក្នុង?

**ឆ៖** ពេលដែលគេយកអ្នកទោសមកពីសួរចម្លើយវិញ គេមិនបានចូលដាក់ខ្លួនគេទេ គឺយកមកប្រគល់ឲ្យត្រឹមមេក្រុម ត្រឹមមេក្រុមៗ ចាត់ចែងទុកដាក់ដោយខ្លួនមេក្រុមខ្លួនគាត់ ។ ហើយខ្ញុំមានតួនាទីខាងត្រួតពិនិត្យរឿងអ្នកទោសហ្នឹង គ្រាន់តែដើរត្រួតពិនិត្យជាបន្តទៀត ។

**ស៖** លោកឃើញស្ថានភាពយ៉ាងម៉េចដែរ អំពីលើរាងកាយរបស់អ្នកទោស ជាពិសេសគឺក្រោយពេលដែលសួរចម្លើយអ៊ីចឹងតើមាន-- លោកមានដែលកត់សម្គាល់លើរូបរាងកាយដងខ្លួនរបស់អ្នកទោសទេ? តើមានទិដ្ឋភាពយ៉ាងដូចម្តេចដែរ?

**ឆ៖** អ្នកទោសដែលគេយកទៅសួរចម្លើយ ខ្លះមកវិញក៏មានវាយទៅ ខ្លះមកវិញទៅ ក៏ច្ចូនកាលអត់ទៅ ។ ហ្នឹងទៅតាមដែលអង្គាល់ខ្ញុំមើលឃើញ ច្ចូនកាលនៅកន្លែងខ្ញុំយាមពីរថ្ងៃបីថ្ងៃហើយនោះ យកសួរចម្លើយ គេយកមកដាក់ទាល់មួយថ្ងៃពីរថ្ងៃអ៊ីចឹង គេប្តូរទៅកន្លែងផ្សេងបាត់អ៊ីចឹងទៅ ។

**ស៖** ម៉េចបានជាលោកគិតថា អ្នកទោសពេលដែលគេយកសួរចម្លើយ យកត្រឡប់មកវិញហ្នឹង ខ្លះវាយ ខ្លះអត់វាយ? ម៉េចបានជាលោកគិតថា អ្នកទោសដែលយកត្រឡប់មកវិញហ្នឹង មានត្រូវគេវាយដំនៅលើរាងកាយរបស់គាត់? ម៉េចបានជាលោកនិយាយដូច្នេះ មូលហេតុអីទៅ?

**ឆ៖** នេះតាមខ្ញុំគ្រាន់តែយល់ ត្រង់ថាក្រែងលោអ្នកខ្លះទៅ ក្រែងលោការដែលថាគេពិបាក គេអីទៅ ក្រែងលោវ៉ៃអីទៅ អ្នកខ្លះក្រែងលោ គេស្រួលយកឯកសារអីទៅ ក្រែងលោគេអត់វ៉ៃអីអ៊ីចឹងទៅ ហ្នឹងខ្ញុំមិនសន្និដ្ឋាន ខ្ញុំនឹកតែក្នុងចិត្តខ្ញុំទេ ។

**ស៖** លោកនិយាយអំមិញថា អ្នកខ្លះគេអត់វាយទេ បើអ្នកខ្លះ គឺលោកគិតថា គេវាយនៅក្នុងអំឡុងពេលដែលទៅសួរចម្លើយ ពេលដែលនាំមកវិញនោះ ។ បានន័យថា លោកឃើញស្លាកស្នាមនៅលើរាងកាយគេ ដូចជាស្នាមកន្ទួល ស្នាមជាំ ឬក៏បែកឈាមអ៊ីចឹងទេ បានលោកនិយាយថា មានអ្នកត្រូវទទួលរងការវាយដំនៅក្នុងអំឡុងពេលសួរចម្លើយនោះ?

[១០:៣២:៣០]

**ឆ៖** ខ្ញុំគ្រាន់តែឃើញជាស្នាម ជារបួសតែប៉ុណ្ណឹង ហើយអ្នកខ្លះក៏អត់តែប៉ុណ្ណឹង ហើយខ្ញុំក៏អត់សួរដឹងដែរហ្នឹង ស្រេចដែលអង្គការគេទេ ។ ប៉ុន្តែ តាមពិតខ្ញុំពិនិត្យទៅវាឃើញមានអ៊ីចឹងខ្លះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការស្តាប់សាក្សី សក្ខីកម្មសាក្សីរូបនេះទៀត ។ មន្ត្រីតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សីរូបនេះ ក្នុងអំឡុងពេលឈប់សម្រាក ហើយឲ្យនាំគាត់មកកាន់សាលសវនាការមុនម៉ោងកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:៣៣នាទី ដល់ម៉ោង ១០:៥៤នាទី]*

**សួរដោយប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មសាក្សី ឈុន ផល ។

**ស៖** លោក ឈុន ផល នៅក្នុងអំឡុងពេលដែលលោកធ្វើជាកងការពារឃាមអ្នកទោសនៅខាងក្នុងតាមអគារនៃអគារឃុំឃាំងនៅមន្ទីរស-២១ ដែលលោកបានអះអាង តើលោកដែលបានជួបប្រទះនូវទិដ្ឋភាពនៃការដែលគេនាំអ្នកទោសចាកចេញ បញ្ចេញអ្នកទោសពីបន្ទប់ឃុំឃាំងនីមួយៗនៅពេលព្រលប់ ឬក៏ពេលយប់ដែរឬទេ?

**ឆ៖** បាទ, បានឃើញមានក្នុងពេលដែលខ្ញុំយាម ។ ឃើញគេមកយកអ៊ីចឹងទៅ ។

**ស៖** ពេលគេយកមនុស្សចេញទៅពេលយប់អ៊ីចឹង តើមានការយកត្រឡប់មកវិញដែរឬទេ?

**ឆ៖** ចួនមិនសូវឃើញយកមកវិញទេ ។

**ស៖** អ៊ីចឹងបានន័យថា មានករណីមួយចំនួន គឺយកចេញទៅពេលព្រលប់ៗ ប៉ុន្តែដល់យប់ជ្រៅគេយកមកវិញ ។ ប៉ុន្តែ មួយចំនួនធំហ្នឹងគឺគេយកចេញទៅបាត់មិនមានឃើញមានបញ្ជូនត្រឡប់មកបន្ទប់ឃុំឃាំងវិញទេ ។ អ៊ីចឹងមែនទេ? ឆ្លើយ ។

**ឆ៖** មែន ។

**ស៖** ករណីណា ដែលគេយកចេញនៅពេលព្រលប់ៗ ហើយស្រាប់តែដល់ពេលយប់ជ្រៅឃើញគេយកបញ្ចូល-- បញ្ជូនចូលត្រឡប់មកបន្ទប់ឃុំឃាំងវិញ ។ តើក្នុងករណីណាដែរ?

**ឆ៖** ក្នុងករណីនោះ ខ្ញុំមិនបានដឹងទេ ។ ដឹងតែត្រឹមថ្នាក់មេក្រុមឡើងទៅលើ ខ្ញុំគ្រាន់តែទទួលភារៈត្រង់ថា ដឹងថាគេយក ហើយគេយកទៅ ហើយគេយកមកវិញតែប៉ុណ្ណឹង ។

**ស៖** ចំពោះអ្នកដែលគេចេញទៅបាត់ ដោយមិនឃើញនាំចូលត្រឡប់មកវិញ លោកដឹងថាតើគេនាំចេញ នាំអ្នកទោសចេញនៅពេលយប់ហ្នឹង យកទៅកាន់ទីណាទេ?

**ឆ៖** ខ្ញុំបាទមិនដឹងទេ ។

**ស៖** លោកនិយាយថា លោកធ្វើការនៅមន្ទីរ-២១ ហើយលោកនិយាយច្រើនលើកច្រើនសាអំពីប្រធានក្រុម ។ សួរថា តើប្រធានក្រុមរបស់លោកដែលលោកនិយាយហ្នឹង គាត់ឈ្មោះអ្វីដែរ?

**ឆ៖** ប្រធានក្រុមគាត់និយាយ ប្រធានក្រុមខ្ញុំឈ្មោះ-- កាលខ្ញុំធ្វើកន្លែងហ្នឹង ឈ្មោះ គន ។

**ស៖** អ្នកធំពីលើឈ្មោះ គន លោកស្គាល់ទេ? ឈ្មោះអ្វីដែរ?

**ឆ៖** ធំពីលើហ្នឹងទៀត បើតាមខ្ញុំធ្លាប់ស្គាល់មានតែឈ្មោះ តាប៉េង ហើយនិង តាហ៊ី ហ្នឹងដែលខ្ញុំធ្លាប់ឃើញគាត់ ។

**ស៖** លោកដែលស្គាល់ឈ្មោះ ហ៊ឹម ហ៊ុយ ដែលឬទេ?

[១០:៥៨:៥៤]

**ឆៈ** ពីខ្ញុំ-- អត់ដែលស្គាល់ទេ ។

**សៈ** លោកស្គាល់អ្នកណាខ្លះ ជាអ្នកធ្វើការនៅមន្ទីរស-២១ តាមដែលលោកចងចាំ ចូរលោករៀបរាប់ ។

**ឆៈ** តាមការដែលខ្ញុំចងចាំពីរឿងអ្នកធ្វើការនៅកន្លែងនោះ បើស្គាល់មានឈ្មោះ៖ មួយប្រធានក្រុមខ្ញុំឈ្មោះ គន ។ ពីរឈ្មោះ តាប៉េង, តាហ៊ី ប៉ុណ្ណឹងហើយ ។ ខ្ញុំវាភ្លេចអស់ហើយអ្នកផ្សេងៗទៀត ។

**សៈ** លោកដែលស្គាល់ឈ្មោះ ឌុច ដែរឬទេ?

**ឆៈ** ឈ្មោះ ឌុច ខ្ញុំបាទតាំងពីធ្វើការកន្លែងនោះ មិនបានជួបគាត់ទេ ។

**សៈ** តាមដែលលោកដឹង តើអ្នកណាជាប្រធាននៃមន្ទីរស-២១ កាលដែលលោកទៅធ្វើការនៅទីនោះ? ប្រធានមន្ទីរស-២១ ឈ្មោះអ្វី?

**ឆៈ** ខ្ញុំពីមួយរាជធ្វើការកន្លែងនោះ ខ្ញុំមិនបានដឹងថា ប្រធានមន្ទីរស-២១ ឈ្មោះអ្វីនោះទេ ។

**សៈ** កាលនោះ លោកដឹងថាអ្នកណាធំជាងគេនៅទីនោះ? តាមដែលលោកស្គាល់ តើអ្នកធ្វើការធំជាងគេ ជាមេគេនៅទីនោះ?

**ឆៈ** ខ្ញុំបើស្គាល់ៗតែត្រឹមថ្នាក់ក្រោមៗ ថ្នាក់ក្រោមត្រឹមតាប៉េង ហើយតាហ៊ី ប៉ុនន៎ុង ដែលខ្ញុំធ្លាប់ឃើញ ។

**សៈ** អំឡុងពេលដែលលោកធ្វើការនៅមន្ទីរស-២១ តើលោកដែលធ្វើការងារយាមខាងក្រៅដែរឬទេ?

[១១:០១:៤២]

**ឆៈ** យាម ខ្ញុំយាមនៅខាងក្រៅ ចួនកាលមានដែរ ។ យូរៗម្តង មិនមែនយាមរហូត ។ យូរៗគេចាត់តាំងឲ្យយាមម្មុងង ។ យូរអ៊ីចឹង គេចាត់តាំងឲ្យយាមម្តងក្នុងមួយខែអ៊ីចឹងទៅ ចួនកាលម្តងចួនកាលកន្លះខែ ចួនកាលអីអ៊ីចឹងទៅតាមតែថ្នាក់លើគេចាត់ចែង អត់បានយាមនៅរាល់តែថ្ងៃទេ ។

**សៈ** លោកយាមនៅខាងក្រៅ យាមនៅម្តុំខាងណានៃមន្ទីរស-២១? ហើយការងារយាមខាងក្រៅហ្នឹង លោកគេឲ្យធ្វើអ្វី?

**ឆ៖** ខ្ញុំបាទយាមនៅខាងក្រៅ ជួនយាមទ្វារខាងក្រោយ ជួនយាមទ្វារខាងមុខ ។ ប៉ុន្តែ បច្ចុប្បន្ន មិនដឹងខាងណាមុខ ខាងណាក្រោយ ទ្វារវាមានពីរ ។

**ស៖** ក្នុងអំឡុងពេលដែលលោកនៅយាមខាងក្រៅ ដែលលោកនិយាយថា យាមទ្វារច្រកចេញចូលនៃមន្ទីរស-២១ហ្នឹង តើលោកមានឃើញនូវការបញ្ជូនចេញ បញ្ជូនចូល ។ ដូចជាការបញ្ជូនអ្នកទោសចូល ឬក៏ចេញដែរឬទេ?

**ឆ៖** ឃើញគេបញ្ជូននិងបញ្ជូនចូល ដែលពេលដែលវេនខ្ញុំយាម ចួនកាលក៏ឃើញទៅ ។ ពេលណាដែលខ្ញុំយាមចួនកាលក៏អត់ទៅ មិនមែនថាចេញរាល់ថ្ងៃ ឬមួយ-- ហ្នឹងទេ ។ ព្រោះថា ចួនកាលក៏គេនាំចេញទៅ ចួនកាលក៏អត់ ។ ពេលខ្ញុំអត់បានឃើញ ។

**ស៖** កាលដែលលោកឃើញគេនាំចូល នាំអ្នកទោសចូលមកក្នុងមន្ទីរស-២១ គេនាំដោយមធ្យោបាយអី? ដឹកជញ្ជូនដោយរថយន្ត? ឬក៏ដឹកជញ្ជូនដោយអ្វីផ្សេងពីរថយន្ត ឬក៏ការនាំចូលមកដោយឲ្យអ្នកទោសដើរ បណ្តើរអ្នកទោសចូលមកក្នុងមន្ទីរស-២១?

**ឆ៖** ពេលដែលខ្ញុំយាមនៅ-- ចួនឃើញៗគេយកមក ឃើញជិះឡានៗឡើងទៅលើអគារ មិនដឹងខាងលើ មិនដឹងគឺគេធ្វើរបៀបម៉េចនោះទេ ព្រោះខ្ញុំនៅតែខាងក្រោម ខ្ញុំមិនបានដឹងទេ ។

**ស៖** ចុះមនុស្សដែលលោកថា ឃើញគេនាំអ្នកទោសចេញ តើគេនាំអ្នកទោសចេញដោយប្រើមធ្យោបាយអ្វីដែរ?

**ឆ៖** គេនាំចេញ គេច្រើនយកឡាន យកទៅដាក់ ហើយគេយកអ្នកទោសពីលើមក គេដាក់ក្នុងឡាន ហើយគេបើកទៅ តែមិនដឹងគេបើកទៅនៅទី នៅកន្លែងណានោះទេ ។

**ស៖** ក្រៅពីគេចាត់ឲ្យលោកយាមអ្នកទោសនៅមន្ទីរស-២១ តើគេឲ្យលោកធ្វើការងារនៅកន្លែងណាទៀតដែរឬទេ?

**ឆ៖** ខ្ញុំឆ្ងល់នឹងសំណួរធ្វើការនៅកន្លែងណាទៀត ធ្វើក្នុងនុំងឬក៏ធ្វើក្រៅពីនុំង ។

**ស៖** ក្រៅពីកិច្ចការដែលលោកធ្វើជាអ្នកយាមខាងក្នុង ហើយនិងក្រោយមកលោកថាអ្នកយាមខាងក្រៅ តើគេចាត់ឲ្យលោកធ្វើកិច្ចការណាផ្សេងទៀត? ហើយនៅកន្លែងណា នៅក្នុងអំឡុងពេលដែលទៅធ្វើការនៅមន្ទីរស-២១ នោះ?

**ឆ៖** ចួនកាលគេចាត់តាំងឲ្យនៅខាងក្រៅ ចួនកាលគេចាត់តាំងឲ្យនៅខាងក្នុង ហ្នឹងថាការងារបន្តដែលផុតពីខ្ញុំធ្វើ គឺមានតែប៉ុណ្ណឹងទេ ។

**ស៖** លោកស្គាល់វាលពិឃាដជើងឯកដែរឬទេ?

**ឆ៖** បឹងវាលជើងឯក ខ្ញុំបាទស្គាល់ ។

**ស៖** លោកដែលត្រូវគេចាត់ឲ្យទៅធ្វើការនៅបឹងជើងឯកដែរឬទេ?

**ឆ៖** មានគេៗចាត់តាំងឲ្យទៅ ។

**ស៖** លោកចងចាំទេ ថាលោកទៅធ្វើការបឹងជើងឯកហ្នឹង នៅក្នុងឆ្នាំណាដែរ?

**ឆ៖** ចេញទៅធ្វើការនៅបឹងជើងឯក បើតាមគិតឆ្នាំខ្ញុំមិនបានចងចាំទេ តែចេញប្រហែលជា៧៩។

**ស៖** លោកធ្វើការនៅបឹងជើងឯកបានប្រហែលជាប៉ុន្មាន រយៈពេលប៉ុន្មានដែរ បានដល់ថ្ងៃរំដោះ ៧ មករា ៧៩?

**ឆ៖** តាមការវាស់វែងនៃកំណត់ថ្ងៃ ខ្ញុំមិនបានចាំទេ ។

**ស៖** អ្នកណាជាអ្នកបញ្ជូនលោកទៅធ្វើការនៅកន្លែងបឹងជើងឯក?

**ឆ៖** ពីរឿងបញ្ជូនខ្ញុំទៅនៅបឹងជើងឯក ខ្ញុំមិនបានស្គាល់ថា ពីណាមួយទេ ប៉ុន្តែឮគេថាថ្នាក់លើៗ ដកកម្លាំងមួយចំនួនយកទៅធ្វើស្រែ ហើយក៏គេចាត់តាំងខ្ញុំឲ្យទៅនៅទីនោះទៅ ។

**ស៖** នៅបឹងជើងឯកហ្នឹង លោកគេឲ្យលោកទៅធ្វើការងារអ្វីដែរនៅបឹងជើងឯក?

**ឆ៖** គេបញ្ជូនឲ្យទៅនៅបឹងជើងឯកចួនកាលធ្វើស្រែទៅ ចួនកាលដាំបន្លែ ដាំបន្លប់អីអ៊ីចឹងទៅ។

**ស៖** លោកស្គាល់កន្លែងសម្លាប់មនុស្សនៅជើងឯកដែរឬទេ?

**ឆ៖** ខ្ញុំបាទស្គាល់ ។

**ស៖** លោកដែលទៅធ្វើការនៅទីនោះដែរឬទេ?

**ឆ៖** ខ្ញុំបាទទៅ គេចាត់តាំងឲ្យទៅចំនួនមួយដង ។

**ស៖** លោកនិយាយរៀបរាប់មើលអំពីកាលដែលលោករស់នៅ និងធ្វើការនៅកន្លែងពិឃាដមនុស្ស នៅបឹងជើងឯកនោះ តើលោកត្រូវគេចាត់ការឲ្យៗទៅនៅទីនោះ លោករស់នៅយ៉ាងម៉េច? ហើយធ្វើការ ជាមួយនឹងអ្នកណាខ្លះនៅទីនោះ? ហើយការងាររបស់លោកដែលលោក គេចាត់ឲ្យធ្វើហ្នឹង តើគេឲ្យ ចាត់ឲ្យលោកធ្វើអ្វីខ្លះ?

**ឆ៖** តាមខ្ញុំចេញពីហ្នឹងទៅនៅឯបឹងជើងឯក ចាត់តាំងឲ្យគ្រាន់តែធ្វើស្រែ ហើយនិងដែលផាក់ទឹកដាក់ស្រូវប្រាំង ស្រូវអីហ្នឹង ហើយទៅដល់ពេលការងារដូចថា មានផែនការអង្គការគេថាចាត់តាំងៗ ហ្នឹង មកធ្វើការហ្នឹងគេហ្នឹងបានចំនួនមួយដង ។

**ស៖** មួយដងហ្នឹងគេចាត់ឲ្យលោកទៅកន្លែងសម្លាប់មនុស្សហ្នឹងមួយដងហ្នឹងគេឲ្យទៅធ្វើការងារអ្វី?

**ឆ៖** ពេលដែលគេប្រើទៅហ្នឹង គេឲ្យយើងទៅកប់សាកសពដែលគេបានសម្លាប់ ។

**ស៖** លោកបានកប់សាកសពដែលគេបានសម្លាប់ហ្នឹង តើលោកកប់ធ្វើនៅពេលថ្មើរណា? ហើយលោកបានកប់សាកសពបានប៉ុន្មានរណ្តៅដែរ?

**ឆ៖** កប់បានដែលគេសម្លាប់ចោលអស់ គេចាត់តាំងឲ្យទៅហ្នឹងបានចំនួនតែមួយរណ្តៅទេ ។

**ស៖** ហើយលោកកាយដីកប់សាកសពហ្នឹងនៅប្រព្រឹត្តនៅពេលថ្មើរណា? ប្រហែលជាម៉ោងប៉ុន្មាន?

**ឆ៖** ប្រហែលជាម៉ោងប្រាំ ម៉ោងប្រាំមួយ ។

**ស៖** ម៉ោងប្រាំ ម៉ោងប្រាំមួយព្រឹក ឬក៏ម៉ោងប្រាំ ម៉ោងប្រាំមួយល្ងាច ព្រលប់ៗ?

**ឆ៖** ម៉ោងប្រាំមួយល្ងាច ។

**ស៖** មុនពេលលោកកាយដីកប់សាកសពហ្នឹង តើលោកពិនិត្យឃើញសាកសពនៅក្នុងរណ្តៅដែលលោកកាយដីកប់ហ្នឹង មានសាកសពចំនួនប្រហែលជាប៉ុន្មាន ហើយស្ថានភាព ឬទិដ្ឋភាពសាកសពទាំងនោះលោកកត់សម្គាល់ឃើញដូចម្តេចដែរ?

**ឆ៖** ឃើញសាកសពមានសម្បុរតែប្រុសៗ ។

**ស៖** មានចំនួនច្រើនទេ? លោកឃើញហ្នឹងមានចំនួនច្រើនទេ សាកសពដែលនៅក្នុងរណ្តៅដែលលោកកាយដីកប់នោះ?

[១១:១៥:០២]

**ឆ៖** ប៉ាន់ប្រមាណមិនត្រូវ ច្រើន ថាច្រើនទៅ ក្រែងលោវាច្រើន តិចទៅក្រែងលោវាតិច ។

**ស៖** ប្រហែលជាប៉ុន្មាននាក់លោកគិតមើលទៅ ហើយរណ្តៅហ្នឹងបើទំហំប៉ុនណា? រណ្តៅដែលថាលោកកាយដីកប់សាកសពហ្នឹងរណ្តៅប៉ុនណាទៅ? ទទឹងប៉ុន្មានម៉ែត្រ បណ្តោយប្រហែលប៉ុន្មានម៉ែត្រ?

**ឆ៖** ប្រហែលជាបណ្តោយបីម៉ែត្រ ទទឹងពីរម៉ែត្រ ប៉ុណ្ណឹងអី ។

**ស៖** លោកឃើញសាកសពហ្នឹងពេញរណ្តៅហ្នឹងដែរឬទេ?

**ឆ៖** សាកសពមិនពេញ ហើយក៏មិនកន្លះប៉ុន្មានដែរ ថាវាម៉ាល្មម ម៉ាគេឲ្យលប់ដី ។

**ស៖** លោកឃើញឈាម ឬក៏ឃើញស្លាកស្នាមនៅលើរាងកាយនៃសាកសពហ្នឹងយ៉ាងដូចម្ដេចដែរ មុនពេលលោកកាយដីកប់?

**ផ៖** ខ្ញុំមិនបានពិនិត្យមើលទេ ទៅដល់គេឲ្យកាយកប់ហ្នឹងទៅ ក៏ចេះតែកាយទៅ ព្រោះថាទៅវាល្ងាចដែលហើយ គេឲ្យធ្វើកប់ឲ្យរហ័សហ្នឹង ចេះតែកប់ទៅអត់សួរ-- ខ្ញុំមិនបានពិនិត្យមើលច្បាស់លាស់ទេ ។

**ស៖** មានឃើញឈាមទេ ឃើញស្នាមឈាម ឬក៏ស្នាមរំរើដំអី ឬក៏កាប់ចាក់អី ឬក៏បាញ់នៅលើរាងកាយសាកសពដែរឬទេ? ស្លាកស្នាមរបួស ឬក៏ស្លាកស្នាមហើមប៉ោងនៅលើរាងកាយសាកសពដែរឬទេ?

**ផ៖** ខ្ញុំមានឃើញឈាម ឃើញអីអ៊ីចឹងដែរ ប៉ុន្តែបើថាខ្លះមានដូចថាហើមត្រង់ណេះ ហើមកហើមអីអ៊ីចឹងទៅ ។ ចួនកាលទៅមានខ្លះឈាមមាត់ ឈាមអីអ៊ីចឹងដែរ ។ ហ្នឹងខ្ញុំពិនិត្យមើលឃើញតែប៉ុណ្ណឹង ។

**ស៖** ហើយសាកសពទាំងនោះមានសម្លៀកបំពាក់ មានសម្លៀកបំពាក់ដែរឬទេ? បានន័យថាមានខោ មានស្លៀកខោ មានពាក់អាវ ដែរឬទេ? ឬក៏ដងខ្លួនទទេ?

**ផ៖** នៅពេលនោះ ដែលគេអ្នកធ្វើការរួច ដែលគេចាត់តាំងខ្ញុំបាទឲ្យទៅ ហ្នឹងគឺគេសម្រាតអស់។

[១១:១៨:០៩]

**ស៖** លោកកាយដីកប់នៅសាកសពមួយរណ្ដៅ តើលោកធ្វើមានគ្នាប៉ុន្មាននាក់? ហើយចំណាយពេលវេលាអស់ប្រហែលរយៈពេលប៉ុន្មានដែរ?

**ផ៖** គេចាត់តាំងឲ្យទៅមានចំនួនគ្នាមួយក្រុម ។

**ស៖** កាលដែលកាយដីកប់រណ្ដៅសពមួយនេះ លោកចំណាយពេលវេលា ក្រុមរបស់លោកចំណាយពេលវេលាអស់ប្រហែលជាប៉ុន្មាន? មួយម៉ោង កន្លះម៉ោង ឬក៏ពីរម៉ោង បីម៉ោង?

**ផ៖** ប្រហែលជាមួយម៉ោងកន្លះ ឬមួយពីរម៉ោងប៉ុណ្ណឹង ។

**ស៖** ក្រៅពីកាយដីកប់សាកសពរួមមួយរណ្ដៅនៅបឹងជើងឯក តើលោកបានធ្វើការជីករណ្ដៅសម្រាប់កប់សពដែរឬទេ?

**ផ៖** ខ្ញុំមិនបានជាអ្នកជីកនោះទេ ។

**ស៖** យើងរំឭកឡើងវិញនូវចម្លើយរបស់លោកដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានសួរលោកកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ វេលាម៉ោងប្រាំបីព្រឹក នៅខេត្តកំពង់ឆ្នាំង លោកបានឆ្លើយដូច្នេះ៖

"សំណួរ៖ ហេតុអ្វីបានគេដឹងថាគេសម្លាប់មនុស្សនៅបឹងជើងឯក?

ឈុន ផល៖ ប្រហែលមួយខែមុនថ្ងៃ៧ មករា ខ្ញុំបានទៅបឹងជើងឯកដើម្បីធ្វើស្រែ ។ ថ្ងៃមួយនោះ ឈ្មោះ សើ ប្រធានក្រុមខ្ញុំនៅបឹងជើងឯក បានឲ្យខ្ញុំទៅជីករណ្តៅចំនួនពីរទៅបីរណ្តៅ ។ ខ្ញុំមិនឃើញរណ្តៅផ្សេងៗនៅជិតនោះទេ ហើយក៏មិនធុំក្លិនស្អុយអ្វីដែរ ។ យប់មួយនោះ ឈ្មោះ សើ បានឲ្យខ្ញុំទៅកប់ខ្មោចនៅជើងឯកដែលទើបតែត្រូវបានសម្លាប់រួចហើយ ។"

នេះជាចម្លើយរបស់លោកដែលបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងអំឡុងពេលស៊ើបអង្កេតកាលពីដើមឆ្នាំ២០០៨ កន្លងមក ។ លោកនៅចងចាំទេ នូវចម្លើយដែលលោកបានឆ្លើយ ដូចដែលយើងបានអានចម្លើយរបស់លោកអម្បាញ់មិញនេះ?

**ឆ៖** ខ្ញុំមិនបានចាំគឺមានភ្លេច ។

**ស៖** ឥឡូវនេះលោករកនឹកមើល តើលោកមានត្រូវបានប្រធានក្រុមរបស់លោកបង្គាប់បញ្ជា ឬក៏ប្រើលោកឲ្យជីករណ្តៅចំនួនពីរទៅបីរណ្តៅ ដែលជារណ្តៅនៅកន្លែងសម្លាប់មនុស្សនៅបឹងជើងឯកដែរឬទេ មុនពេលលោកត្រូវបានប្រធានក្រុមរបស់លោកប្រើឲ្យលោកទៅកាយដីកប់សាកសព ដែលត្រូវបានគេទើបតែសម្លាប់រួច ។ ដែលលោកបានឆ្លើយរួចហើយអម្បាញ់មិញនេះ ។

**ឆ៖** រឿងខ្ញុំទៅកប់ គឺគេបានចាត់តាំងមែន ។

[១១:២៣:១២]

**ស៖** យើងសួរលោកមិនមែនរឿងកប់ទេ សួរលោករឿងជីករណ្តៅសម្រាប់កប់សាកសព ដែលគេនាំទៅសម្លាប់ ។ តើលោមានបានជីករណ្តៅដូចអ្វីដែលលោកបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតដែរឬទេ? គឺជីករណ្តៅពីរទៅបីរណ្តៅ តាមការដែលលោកប្រធានក្រុមរបស់ឈ្មោះ សើ ដែលជាប្រធានក្រុមរបស់លោកប្រើឲ្យទៅជីក ។ តើលោមានបានជីករណ្តៅសម្រាប់កប់សពចំនួនពីរទៅបីរណ្តៅដែរឬទេ នៅទីនោះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ។

**លោក គង់ សំអុន៖**

ខ្ញុំបានសូមអនុញ្ញាតជួបជាមួយសាក្សីបន្តិច ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

*[មេធាវីប្រឹក្សាយោបល់ជាមួយសាក្សី]*

[១១:២៨:១៤]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកនៅចងចាំទេ ថាតើប្រធានក្រុមរបស់លោកដែលចាត់តាំងលោកឱ្យទៅជីករណ្តៅសម្រាប់កប់សពនៅបឹងជើងឯកដែរឬទេ?

**ឆ៖** ខ្ញុំបាទមានការដូចថាភ្លេចរកនឹកមិនឃើញ ។ កាលណោះខ្ញុំបានទៅធ្វើ ដូចបានសួរមែន ។

**ស៖** ពេលដែលលោកទៅធ្វើការងារនៅទីនោះ នៅជីករណ្តៅនោះនៅពេលយប់ ឬក៏ពេលថ្ងៃ?

**ឆ៖** ជីកនៅពេលថ្ងៃ ។

**ស៖** លោកនៅចងចាំទេ ថារណ្តៅដែលគេចាត់ឱ្យលោកជីកហ្នឹង សម្រាប់កប់ខ្មោច កប់សពហ្នឹងមានទំហំទទឹងប៉ុន្មានម៉ែត្រ បណ្តោយប៉ុន្មានម៉ែត្រ ហើយជម្រៅប៉ុន្មានម៉ែត្រដែរ ដែលគេតម្រូវបង្គាប់ឱ្យលោកធ្វើការជីករណ្តៅនោះ?

**ឆ៖** ការដែលជីករណ្តៅនោះ ខ្ញុំមិនបានវាស់ មិនបានវែងទេ គ្រាន់តែមេក្រុម មេអី គេអ្នកវាស់អ្នកអីទៅ ខ្ញុំគ្រាន់តែជីកទេ ។

**ស៖** លោកអ្នកជីកហ្នឹងហើយ ប៉ុន្តែលោកចងចាំទេ ជីក ឥឡូវគិតថាជម្រៅចុះ ជម្រៅប្រហែលជាប៉ុន្មានម៉ែត្រដែរ ដែលគេតម្រូវឱ្យយើងជីកនោះ? ហើយការជីកហ្នឹង គឺមនុស្សទាំងមួយក្រុមរបស់លោកតែម្តង ដែលមានគ្នាដប់ពីរហ្នឹង ឬក៏យ៉ាងម៉េច? ឬក៏លោកតែម្នាក់ឯងទេ?

**ឆ៖** ការជីកវាមានគ្នាច្រើន គេចាត់តាំងជាក្រុម ។

**ស៖** ហើយរណ្តៅជីករួចនោះប្រហែលជាជម្រៅប៉ុនណាដែរ ប្រហែលជាត្រឹមក្បាលលោកដែរទេនៅពេលដែលចុះទៅ?

**ឆ៖** រណ្តៅប្រហែលជា បើជម្រៅចុះក្រោមប្រហែលជា បើយើងចុះប្រហែលជាត្រឹមក ត្រឹមអី។

**សះ** ត្រឡប់ទៅពេលដែលលោក ក្រុមលោកកាយដីកប់សាកសពវិញ សំណួរសួរថា ពេលដែលលោកធ្វើនៅពេលព្រលប់ៗរហូតដល់ពេលយប់ហ្នឹង តើលោកធ្វើទាំងងងឹត ឬក៏មានភ្លើងអគ្គិសនីដែលគេបញ្ចេះអំពូលភ្លើងដែរ នៅពេលដែលលោកកាយ ក្រុមលោកកាយកប់សាកសពនោះ?

**ឆះ** គឺមានភ្លើងម៉ាស៊ីន ។

**សះ** លោកចងចាំទេ នៅទីនោះ កន្លែងដែលលោកជីករណ្តៅសម្រាប់កប់សាកសព ឬក៏ដូចជាកន្លែងដែលលោក ក្រុមលោកដែលគេប្រើឲ្យទៅកាយដីសម្រាប់កប់ ដើម្បីកប់សាកសពដែលគេបានសម្លាប់រួចនុំង សួរថាទីកន្លែងនុំងជាវាលស្រែអតីត ឬក៏ជាវាលស្រែ? ឬក៏ជាទីទួល? ឬក៏ជាដីវត្តអីជាដើម? ទីកន្លែងនុំងពីដើមគេធ្វើអ្វីដែរពីសង្គមមុនមក?

**ឆះ** កាលដែលខ្ញុំឃើញ ខ្ញុំនៅចងចាំបាន កន្លែងនោះគឺកន្លែងម៉ុងចិន ។

**សះ** ក្រោយពីកិច្ចការដែលលោកធ្វើ តើលោកបានទៅជួបប្រទះ និងឃើញទិដ្ឋភាពអ្វីផ្សេងទៀតដែល អំឡុងពេលដែលលោកទៅធ្វើការ ដែលគេប្រើឲ្យលោកទៅធ្វើការនៅទីនោះ? ដូចជាផ្ទះនៅទីនោះ ឬក៏រថយន្ត ឬក៏មធ្យោបាយផ្សេងៗដែលគេប្រើប្រាស់នៅទីនោះ លោកដែល លោកបានឃើញអ្វីខ្លះទៅ?

**ឆះ** ខ្ញុំរយៈពេលក្រោយមក ខ្ញុំគេលែងចាត់តាំងមកកន្លែង គេឲ្យធ្វើស្រែ គេធ្វើតែក្រុមគេខាងក្រោយៗទេ ។

**សះ** យើងមិនសួរពេលក្រោយមកទៀតទេ ។ យើងសួរពេលដែលលោកទៅដល់ ថ្ងៃគេប្រើលោកឲ្យទៅជីក ឬក៏ទៅកាយដីដើម្បីកប់សាកសពនុំង តើលោកក្រៅពីការងារអ៊ីចឹង តើលោកបានសង្កេតឃើញអ្វីខ្លះ? ដូចថាលោកទៅកាយសាកសពដែលគេទើបតែសម្លាប់ហើយ សំណួរសួរថា តើលោកបានជួបប្រទះនឹងក្រុមដែលសម្លាប់មនុស្សដែរឬទេ? ហើយលោកឃើញដូចជាមធ្យោបាយដឹក ជញ្ជូនរថយន្តដែលគេដឹកមនុស្សទៅសម្លាប់នៅក្បែរនោះដែរឬទេ?

**ឆះ** អត់បានឃើញទេ ព្រោះខ្ញុំទៅ គេទៅវិញអស់បាត់ហើយ ។

**សះ** នៅទីនោះ មានលោកមានឃើញផ្ទះ មានផ្ទះឬក៏មានអីទេ កន្លែងដែលគេធ្វើការងារនៅទីនោះ លោកមានបានឃើញទេ? កន្លែងបុគ្គលិកធ្វើការងារនៅកន្លែងវាលពិឃាដនុំង តើមានជារោង ឬក៏ជាផ្ទះដែរឬទេ? ឬក៏គេធ្វើការនៅកណ្តាលវាល?

**ឆះ** ខ្ញុំអត់បានឃើញផ្ទះ ឃើញ-- អត់បានឃើញផ្ទះ អត់បានឃើញ កន្លែងបុគ្គលិកទេ ពីព្រោះថាខ្ញុំ គេធ្វើកន្លែងណាមិនដឹងៗ ព្រោះខ្ញុំចូលមក គេប្រើមក ប្រើឲ្យដើរមកតាមផ្លូវនុំង ផ្លូវលិចនុំង ទៅ

វិញ ទៅលិចវិញបណ្ដោយ ។ កន្លែងគេធ្វើការខ្ញុំអត់បានចូលទេ ។

**ស៖** តើលោកបានចាកចេញពីកន្លែងធ្វើស្រែនៅព្រៃស នៅថ្ងៃខែឆ្នាំណាដែរ តាមលោកចងចាំ?

**ឆ៖** ខ្ញុំចេញពីព្រៃសទៅ ខ្ញុំមិនបានកំណត់ចាំបាន ។

[១១:៣៥:២៣]

**ស៖** សំណួរចុងក្រោយថា នៅក្នុងអំឡុងពេលដែលលោកត្រូវបានអង្គការចាត់តាំងលោកមកធ្វើការងារជាហូរហែមកដល់រៀននៅតាខ្មៅ ហើយមកធ្វើការនៅស្រែ នៅព្រៃស រួចបញ្ជូនលោកមកធ្វើការងារនៅមន្ទីរស-២១ ដែលលោកហៅថា ទួលស្លែង ហើយក្រោយមកបញ្ជូនមកធ្វើការងារធ្វើស្រែនៅបឹងជើងឯក ហើយរហូតដល់លោកត្រូវបានចាកចេញទីនោះ ដែលលោកនិយាយអំមិញ ថាមិនដឹងមិនចាំថ្ងៃ ក្នុងអំឡុងពេលដែលលោកមក ។ អ៊ីចឹងតើលោកបានមានឱកាសបានចាកចេញពីមន្ទីរ ពីអង្គភាពទៅឆ្ងាយ ដូចជាទៅលេងផ្ទះ សួរសុខទុក្ខឪពុកម្ដាយ ឬក៏ទៅទីផ្សេងៗឆ្ងាយពីកន្លែងធ្វើការដែរឬទេ?

**ឆ៖** រយៈពេលនោះ ដូចជាខ្ញុំដឹងថា អត់មានបានដែលថាមកលេងផ្ទះ ចេញពីផ្ទះម៉ោងណា គឺរហូតទាល់តែយួនចូលស្រុក រត់បណ្ដោយ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វី ត្រូវសួរដល់សាក្សីរូបនេះដែរឬទេ?

បើមិនមានទេ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរសំណួរដល់សាក្សីរូបនេះ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា៖**

**សួរដោយលោក តាន់ សេណារ៉ុង៖**

សូមអរគុណ លោកប្រធានអង្គជំនុំជម្រះ និងសូមស្វាគមន៍លោក ឈុន ផល ។ នៅព្រឹកនេះលោកបានជម្រាបជូនអង្គជំនុំជម្រះរួចមកហើយដែរថាលោកធ្លាប់បានយាមអ្នកទោសនៅខាងក្នុងមន្ទីរស-២១ ដែលគេហៅថា ទួលស្លែងនោះ ។

**ស៖** នៅក្នុងពេលលោកយាម សំណួរសួរថា នៅពេលដែលលោកយាមខាងក្នុងនុំង តើលោកដែលធ្លាប់ឃើញមានស្លាកសញ្ញាវិន័យសន្តិបាលទេលោក?

**លោក តាន់ សេណារ៉ុង៖**

ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះដើម្បីនឹងបង្ហាញនូវឯកសារស្លាកវិន័យសន្តិបាល

ហ្នឹង ដែលមានលេខ 00181448 ដើម្បីជាជំនួយនៅក្នុងការចងចាំដល់សាក្សីលោក ឈុន ផល នោះបាទ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីផ្នែកខាងសោតទស្សន៍បង្ហាញឯកសារដែលមានលេខ ERN ដូចការបង្ហាញរបស់សហព្រះរាជអាជ្ញានៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** លោក ឈុន ផល នេះគឺជាវិន័យសន្តិបាលដែលយើងរកបាននៅសារមន្ទីរទួលស្លែងដែលគេហៅថាមន្ទីរស-២១ហ្នឹង ។ នៅក្នុងរយៈកាលដែលលោកបានយាមនៅខាងក្នុងមន្ទីរស-២១នុ៎ង តើលោកមានការចងចាំទេ ថាតើនៅតាមបន្ទប់នីមួយៗ និងអគារនីមួយៗហ្នឹង លោកដែលធ្លាប់ឃើញវិន័យសន្តិបាល គេបានសរសេរ និងបិទនៅតាមអគារ និងតាមបន្ទប់របស់អ្នកទោសហ្នឹងទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ មេធាវីប្រឹក្សាយោបល់ជាមួយសាក្សី ។

**លោក គង់ សំអុន៖**

ខ្ញុំបាទសូមជម្រាបជូនតំណាងសហព្រះរាជអាជ្ញាថា ដោយសាររូបនេះគាត់អត់ចេះអក្សរផងដូច្នេះប្រហែលជាមានការលំបាកក្នុងការចងចាំ សូមលោកចៅក្រម លោកប្រធាន មេត្តាអាចឲ្យតំណាងសហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ផ្សេង ឬក៏មានវិធីអីផ្សេង ដើម្បីធ្វើឲ្យសាក្សីចងចាំជាលក្ខណៈរូបភាព រូបសញ្ញានៃអក្សរនេះ វាអាចមានលក្ខណៈប្រសើរជាជាងខ្លឹមសារនៃវិន័យសន្តិបាលនេះ ។ ហើយសាក្សីប្រហែលជាមិនយល់ផងថា តើវិន័យសន្តិបាលនោះជាអ្វី? សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវីប្រឹក្សាយោបល់សាក្សី ។ ហើយការកត់សម្គាល់នេះឃើញថាវាជាការល្អ។ ដូច្នេះតំណាងសហព្រះរាជអាជ្ញាជាតិសូមមានការចាប់អារម្មណ៍ថាសាក្សីរូបនេះមិនអក្សរទេ ហើយសូមសម្រួលនូវសំណួរយ៉ាងម៉េចដើម្បីឲ្យគាត់បានយល់នូវបំណងនៃការសួររបស់លោកទៅតាមកម្រិតនៃការយល់ដឹងរបស់សាក្សីរូបនេះ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ ។

**ស៖** លោក ឈុន ផល វិន័យសន្តិបាលនេះគឺបទបញ្ជាសម្រាប់ អ្នកទោសដែលយើងបានឃុំឃាំងនៅក្នុងមន្ទីរស-២១ហ្នឹងណា វិន័យហ្នឹងគេមានសរសេរដាក់នៅក្តារខៀន វាអាចមានបិទជាក្រដាស ក្នុងនោះគេមានសរសេរថា សួរអីឆ្លើយនឹង មិនបង្វែងសំណួររបស់អញ ។ អានេះគឺជាសំណួរទីមួយមិនឱ្យដោះស្រាយ យកលេសនេះលេសនោះ អានេះគ្រាន់តែឃើញថា លោកធ្លាប់ដែលឃើញថាមានស្លាក ឬក៏អក្សរស្អីដែលគេបិទជាសម្គាល់ថា បើលោកមិនចេះអក្សរក៏លោកធ្លាប់ឃើញគេបានបិទជាក្រដាសនៅតាមបន្ទប់ ឬក៏មានសរសេរជាក្តារខៀន ប៉ុណ្ណឹងក៏បានដែរ បើសិនលោកមានការចងចាំ ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាដូរសំណួរ ហើយរំឮកថាតំណាងសហព្រះរាជអាជ្ញាមានពេលដប់នាទីទៀតតែប៉ុណ្ណោះ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** សំណួរបន្ទាប់ជូនលោក ឈុន ផល នៅពេលដែលលោក លោកធ្លាប់បានជម្រាបជូនអង្គជំនុំជម្រះរួចមកហើយថាលោកធ្លាប់បានយាមនៅខាងក្រៅអគារ ហើយនិងមុខរបស់សារមន្ទីរស-២១នុ៎ង ថាតើលោកមានការកត់សម្គាល់ទេថាឡានដែលដឹកអ្នកទោសចេញ និងចូលហ្នឹងមានស្លាកសញ្ញាដែរទេលោក? ស្លាកសញ្ញាហ្នឹងមានអក្សរអ្វីជាសម្គាល់ថាជាឡានរបស់អង្គភាពណាមួយទេ?

[១១:៤២:៤៥]

**ឆ៖** តាមខ្ញុំសង្កេតមើលទៅតាមឡាន ឃើញដាក់លេខជាអក្សរ ហើយនិងលេខដាក់ថា ស-២១ លេខដាក់មុខឡាន ហើយនិងក្រោយឡាន ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក ឈុន ផល ។ ខ្ញុំដោយមានពេលវេលាតិច ខ្ញុំនឹងបង្វែរសំណួរបន្ទាប់ទៅជូនសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីសួរបន្តទៀត ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក អានីស អះមេដ៖**

**ស៖** លោក ឈុន ផល ចៅក្រមសួរច្រើនហើយដូច្នេះខ្ញុំមិនមានសំណួរច្រើនសួរលោកទេ ។ ខ្ញុំសូមសួរលោកអំពីចម្លើយដែលលោកឆ្លើយឱ្យអ្នកស៊ើបអង្កេតរបស់តុលាការនេះ ។ ចៅក្រមជម្រាប

លោក ថាលោកបានឆ្លើយជូនអ្នកស៊ើបអង្កេតរបស់តុលាការនេះនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨ ។ នៅពេលដែលគេកត់ត្រាចម្លើយនោះលោកបានប្រាប់អ្នកស៊ើបអង្កេតថា លោកអាចអាន សរសេរ ហើយ និងយល់ ភាសាខ្មែរ តើលោកបាននិយាយដូច្នោះដែរឬទេ?

**ឆ៖** ខ្ញុំពីនៅក្នុងសម័យនោះខ្ញុំមិនពី សម័យប៉ុលពតនោះ ខ្ញុំនៅវ័យក្មេងផង ហើយខ្ញុំមានការសិក្សាវា តិចផងម្ល៉ោះហើយខ្ញុំអាចស្គាល់បានតែបន្តិចបន្តួច ។ ប៉ុន្តែមកដល់រាល់ថ្ងៃព្រោះខ្ញុំអត់បានសិក្សាប៉ុន្មានដែរ អក្សរខ្មែរ អាចចេះបានមួយចំនួនតូចមិនឲ្យគ្រប់គ្រាន់ពេកនោះទេ ។

**ស៖** នៅពេលដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតលោកជម្រាបថាលោកដឹងថាមានការរំលោភផ្លូវភេទនៅស-២១ តើលោកបានចាំថានិយាយដូច្នោះជូនចៅក្រមអង្កេតដែរឬទេ?

**ឆ៖** បាទ, បាននិយាយជាមួយអ្នកសង្កេត ។

**ស៖** ថាតើលោកឃើញអ្នកដែលត្រូវគេរំលោភផ្លូវភេទនៅស-២១ដែរឬទេ? ឬក៏លោកធ្លាប់ឃើញអ្នកណាគេដែលជាអ្នករំលោភទៅលើជនរងគ្រោះនោះ ។ បើសិនជាលោកឃើញនោះ សូមលោកជួយជម្រាបជូនអង្គសវនាការ ។

**ឆ៖** ខ្ញុំមិនបានដែលឃើញការរំលោភទេ ។

[១១:៤៦:៤៨]

**ស៖** ខ្ញុំចង់សួរថា តើលោកស្គាល់អ្នកដែលត្រូវបានគេរំលោភផ្លូវភេទនៅស-២១ ដែរឬទេ?

**ឆ៖** ខ្ញុំមិនឃើញទេ ។

**ស៖** តើលោកដឹងថា មានការរំលោភផ្លូវភេទយ៉ាងម៉េចនៅស-២១ បើសិនលោកអត់បានឃើញផងនោះ?

**ឆ៖** ខ្ញុំមិនបានឃើញ ខ្ញុំនិយាយអត់កើត ។

**ស៖** អ៊ីចឹងតើតាមការឆ្លើយរបស់លោកទៅសហចៅក្រមស៊ើបអង្កេតថាមានការរំលោភផ្លូវភេទនៅស-២១នោះលោកដឹងមកពីណា? លោកផ្អែកលើអ្វីទើបលោកបានជានិយាយដូច្នោះ? ថាតើអ្នកយាមដែលយាមជាមួយលោកនោះប្រាប់លោកថា មានការរំលោភនៅស-២១ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនបានឃើញផ្ទាល់ទេ ឮតែគេ ឮតែមេក្រុមមេអីគេប្រាប់អ៊ីចឹងខ្ញុំក៏គ្រាន់តែថា វាមានបានដូចថាគាត់និយាយអ៊ីចឹងនោះ ។

**ស៖** តើមេក្រុមរបស់លោកប្រាប់លោកថាម៉េច? ថាតើគាត់ប្រាប់ថា អ្នកយាមជាអ្នករំលោភអ្នកទោសនៅស-២១ ឬក៏យ៉ាងម៉េច?

**ឆ៖** គាត់បានថា អ្នកយាមរំលោភអ្នកទោសត្រូវគេចាប់ដាក់ទោសដូចតែគ្នាដែរ ។ ពេលនោះខ្ញុំបាននិយាយថា បើអ្នកយាមរំលោភអ្នកទោសត្រូវគេចាប់ដាក់ទោសដាក់គុកដូចគ្នា ។

**ស៖** ថាតើមេក្រុមរបស់លោកមានប្រាប់លោកដែរឬទេថា គេចាប់អ្នកយាមមួយចំនួនដោយសារអ្នកយាមទាំងអស់នោះបានរំលោភផ្លូវភេទទៅលើអ្នកទោស ។ តើគាត់មានប្រាប់អ៊ីចឹងទេ?

**ឆ៖** គាត់បានប្រាប់តែខ្ញុំមិនឃើញច្បាស់ ។

**លោក អានីស អះមេដ៖**

ខ្ញុំនៅសល់ពីរសំណួរទៀតលោកប្រធាន ។ ហើយនៅពេលនេះខ្ញុំសូមដាក់ឯកសារជូនសាក្សីនេះគឺលេខ 00053798 ។ លោកប្រធានសុំឲ្យខាងសោតទស្សន៍បញ្ចាំងទៅលើឯកសារនេះ ហើយខ្ញុំនៅមានសំណួរពីរសួរទៅលើឯកសារនេះបន្ទាប់មកនឹងបញ្ចប់ការសួររបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍សូមបង្ហាញឯកសារដែលមានលេខ ERN00053798 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក អានីស អះមេដ៖**

**ស៖** លោក ឈុន ផល លោកធ្វើការយូរនៅស-២១ លោកជាអ្នកយាមហើយបន្ទាប់មកលោកទៅធ្វើការនៅជើងឯក ។ ថាតើគេធ្វើប្រវត្តិរូបរបស់លោកនៅពេលដែលលោកចូលធ្វើការនៅស-២១ អ៊ីចឹងមែនដែរឬទេ?

[១១:៥១:៤៩]

**ឆ៖** មែន ។

**ស៖** លោកក៏បានប្រាប់ដែរថា លោកអាចអានឈ្មោះលោក ហើយលោកអាចឈ្មោះតិចតួចដែរដូច្នេះហើយសូមឲ្យលោកពិនិត្យឯកសារនេះថាតើវាជាប្រវត្តិរូប ហើយជាឈ្មោះរបស់លោកមែនដែរឬទេ?

(សូមឲ្យខាងសោតទស្សន៍ធ្វើការបង្វិលឯកសារនេះចុះទៅក្រោមដើម្បីឲ្យយើងអាចមើលឃើញដល់ចប់តែម្តងនូវឯកសារទាំងអស់នេះ?) ថាតើនេះជាប្រវត្តិរូបរបស់លោកដែលគេធ្វើ នៅ ស-២១

តើមែនដែរឬទេ?

**ឆ៖** ខ្ញុំមិនប្រាកដដែរព្រោះមេក្រុមគេធ្វើ គាត់យកទៅបាត់ទៅ ខ្ញុំអត់ដែលបានមើលប្រវត្តិរូបខ្លួនឯង ។

**អ្នកបកប្រែ៖**

សូមអនុញ្ញាតលោកប្រធានឱ្យសហព្រះរាជអាជ្ញាបើកមីក្រូហ្វូន ។

**ប្រធានអង្គជំនុំ៖**

ឈប់ៗ មេធាវីប្រឹក្សាតើមានបញ្ហាអ្វីទៅ? បើកមីក្រូហ្វូន ។

**លោក គង់ សំអុល៖**

ខ្ញុំធ្វើការកត់សម្គាល់បន្តិចទៅលើតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែលលោកមានប្រសាសន៍ថា គាត់លើកយកចម្លើយប្រហែលជាភាសាអង់គ្លេសដែលមានការបកប្រែជាភាសាខ្មែរថា សាក្សី ចេះសរសេរ និងអានភាសា ។ ក៏ប៉ុន្តែ នៅក្នុងតាមច្បាប់ដើមជាភាសា ឯកសារ D28/15 ក្នុងទំព័រ២ បានបញ្ជាក់ថាជននេះប្រកាសថាខ្លួន មិនចេះអាន និងសរសេរភាសា ។ ប៉ុន្តែ ក្នុងនេះក៏មិនបានបញ្ជាក់ ថាតើភាសាអ្វីតទៅទៀតដែរ ។ ប៉ុន្តែ ជាទូទៅប្រហែលជាភាសាខ្មែរ ហើយច្បាប់ដើមនេះត្រូវកំណត់ថា ត្រូវសរសេរជាភាសាខ្មែរ ។ ដូច្នេះ ការដាក់រូបភាពដែលមានលក្ខណជាងអក្សរឱ្យសាក្សីពិនិត្យ គឺសាក្សីមិនអាចឆ្លើយទៅនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាបានទេ ។ ដូច្នេះ ការឆ្លើយក៏វាអាចធ្វើឱ្យមានការច្រឡំដល់អង្គសវនាការទាំងមូលផងដែរ ។ ហើយជាពិសេសខ្ញុំសូមរំឭកជូនទៅអស់លោក ដែលត្រូវតាំងសំណួរគួរតែចៀសវាងការដាក់ឱ្យ សាក្សីអាននូវអត្ថបទទាំងឡាយណាដែលសាក្សីមិនអាចធ្វើការបញ្ជាក់បាន ។ សូមអរគុណ ។

[១១:៥៥:00]

**ប្រធានអង្គជំនុំ៖**

អរគុណនូវការកត់សម្គាល់នេះ ។ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គួរតែមានការប្រយ័ត្នប្រយែងក្នុងការតាំងសំណួរ ឬក៏ដាក់ឯកសារផ្សេងៗនេះមានការចាប់អារម្មណ៍បន្តិច ដោយសារគាត់មានការយល់ដឹង ឬក៏ការចេះអក្សរខ្មែរហ្នឹងតិចតួចណាស់ ។ នេះជាបញ្ហា ។ បើសិនជាដាក់ឯកសារដែលមានលក្ខណៈអក្សរច្រើនវែង ហើយមានការសាំញ៉ាំដូច្នេះ គួរតែអាចត្រូវបានសួរឱ្យគាត់អាននូវឃ្លាណាមួយជាក់លាក់ទៅ ។ តើគាត់ចេះអានឬអត់? បើគាត់អត់ចេះអានផង យើងសួរសំណួរដែលមាន

លក្ខណៈសាំញ៉ាំឲ្យគាត់យល់ដឹង។ ដូច្នេះអាចមានបញ្ហាដូចអ្វីដែលមេធាវីប្រឹក្សាយោបល់សាក្សីគាត់បានកត់សម្គាល់អ៊ីចឹងជាបញ្ហាមួយល្អ ហើយគួរតែចៀសវាងប្រសិនបើកម្រិតនៃការយល់ដឹងផ្នែកខាងអក្សរសាស្ត្ររបស់គាត់ហ្នឹងមានកម្រិតទាបដូច្នេះនោះ ។

**លោក អានីស អះមេដៈ**

ខ្ញុំឆ្លើយតបរយៈពេលមួយនាទីចំពោះមេធាវីជំនួយសាក្សី ។ ខ្ញុំអានឯកសារអង់គ្លេសនៃឯកសារនោះ ហើយខ្ញុំបានយល់ថាវាបានកត់ត្រាជាភាសាខ្មែរគឺភាសាដើម ។ មេធាវីជំនួយសាក្សីគាត់អានប្រយោគទីពីរថា ជននេះមិនបានប្រកាសថាខ្លួនមិនចេះអាននិងសរសេរភាសា។ ប៉ុន្តែ នៅលើប្រយោគហ្នឹង យើងឃើញមានប្រយោគសរសេរមួយទៀត ដែលបានលើកឡើងថាជននេះបានប្រកាសថាខ្លួនចេះអានសរសេរនិងយល់ភាសាខ្មែរ ។

ដូច្នេះហើយឯកសារដើមនៃឯកសារនេះគឺបានកត់ត្រាជាភាសាខ្មែរ ។ ដូច្នេះ ខ្ញុំសូមលើកឡើងដោយគោរពថា យើងដឹងអំពីភាពចេះដឹងរបស់សាក្សី ហើយយើងប្រយ័ត្នប្រយែងណាស់នៅពេលដែលយើងសួរសំណួរ ហើយខ្ញុំយល់អំពីប្រយោគនេះ ដូច្នេះហើយគឺខ្ញុំសួរសំណួរសាមញ្ញដល់សាក្សី ។

ដូច្នេះ ដោយសារតែពេលវេលាខ្ញុំអស់ហើយ ខ្ញុំសូមស្នើសុំឲ្យលោកប្រធានធ្វើការទទួលយកចម្លើយរបស់សាក្សីនេះដែលបានផ្តល់នៅសហចៅក្រមស៊ើបអង្កេតដាក់ជាឯកសារ ហើយអាចអាននៅពេលណាមួយសមស្រប ដែលលោកលោកស្រីចៅក្រមគិតថាជាការគួរសម ។ ដូច្នេះហើយ ខ្ញុំសូមអរគុណច្រើន ចំពោះចំណុចទាំងអស់នេះ ។ សូមអរគុណ ។

[១១:៥៧:៣៤]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះឃើញថា ពេលវេលាដល់ពេលត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ហើយអង្គសវនាការនឹងចាប់បន្តនៅវេលាល្ងាច គឺនារសៀលចាប់ពីម៉ោងមួយសាមសិបនាទី ។

មន្ត្រីតុលាការ សម្របសម្រួលដល់សាក្សីរូបនេះ ដើម្បីបានទទួលកន្លែងសម្រាកសមរម្យ ហើយឲ្យនាំគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលនេះ ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់សាលសវនា-ការឲ្យបានមុនម៉ោងមួយកន្លះនៅរសៀលនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១១:៥៩នាទី ដល់ម៉ោង ១៣:៣០នាទី ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្ម សាក្សី ឈុន ផល ។ ជាបន្តនេះសូមប្រគល់វេទិកាទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីអាចឡើង សួរនូវសំណួរពាក់ព័ន្ធនឹងសាក្សីរូបនេះ ដោយក្នុងមេធាវីមួយក្រុមៗមានពេលវេលាប្រាំមីនុត ហើយសរុប គឺមានពេលវេលាម្ភៃមីនុតសម្រាប់មេធាវីទាំងបួនក្រុម ។

សូមអញ្ជើញ ។ ហើយឡើងមកគឺជំនួសឲ្យមេធាវីទាំងបួនក្រុម ឬយ៉ាងម៉េចលោកមេធាវីហុង គឹមសួន?

**លោក ហុង គឹមសួន៖**

សូមអរគុណ និងសូមគោរពលោកប្រធាន ។ ខ្ញុំបាទនឹងជំនួសនឹងឲ្យមេធាវីទាំងបួនក្រុម ប៉ុន្តែបើ នៅសល់ពេលវេលា ខ្ញុំបាទនឹងសូមឲ្យមេធាវីក្រុមដទៃបន្ថែមបង្គ្រប់ ។

ខ្ញុំបាទសូមគោរពលោកប្រធានម្តងទៀត និងសូមគោរពលោកស្រី លោកចៅក្រមនៅក្នុងអង្គជំនុំ ជម្រះក្នុងតុលាការកម្ពុជា ។ តទៅនេះ ខ្ញុំបាទសូមតាំងសំណួរសួរដល់សាក្សី ឈុន ផល ។

**ការតាំងសំណួរដោយក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

**សួរដោយលោក ហុង គឹមសួន៖**

ជម្រាបសួរលោក ឈុន ផល ។ ខ្ញុំមេធាវី ហុង គឹមសួន ជាមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជារងគ្រោះក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំមានសំណួរខ្លះសួរបន្ថែម បើសិនជាលោក មិនច្បាស់ លោកឆ្លើយមកខ្ញុំថាមិនច្បាស់ ។

**ស៖** ជាដំបូង ខ្ញុំសូមសួរលោកអំពីសំណួររបស់លោកប្រធានព្រឹកមិញ សួរទៅលោកថា កាល លោកចេញពីព្រៃសមកដល់មន្ទីរទួលស្លែង ព្រោះលោកឆ្លើយថាមកទួលស្លែង ។ អ៊ីចឹងលោកប្រធាន សួរលោក តើគេហៅឈ្មោះអ្វីខ្លះក្រៅពីទួលស្លែង? លោកអត់ទាន់បានឆ្លើយទេ ។ អ៊ីចឹង ខ្ញុំគ្រាន់សួរថា តើពេលនោះលោកមកដល់ទួលស្លែងនោះ គេហៅឈ្មោះ “ទួលស្លែង” ជាទូទៅ ឬលោកដឹងក្រោយ គេ

ហៅថា “ទួលស្លែង” ?

[១៣:៣៣:៥០]

**ឆ៖** ដឹង ខ្ញុំដឹងក្រោយ-- មិនដឹងក្រោយទេ ខ្ញុំដឹងមុនដោយសារដែលខ្ញុំចូលទៅដល់គេប្រាប់ថា នេះសាលារៀន គេហៅថា “សាលារៀនទួលស្លែង” គឺខ្ញុំបានស្តាប់គេនិយាយអ៊ីចឹង ខ្ញុំក៏ជឿគេថា “សាលាទួលស្លែង” ទៅ ។

**ស៖** សូមអរគុណ ។ លោកថាការងាររបស់លោកនៅមន្ទីរស-២១ ឬសព្វថ្ងៃនេះដែលគេហៅថា “សារមន្ទីរទួលស្លែង” ដែរនោះ ។ លោកជាអ្នកយាម យាមទាំងខាងក្នុងបរិវេណនៃមន្ទីរស-២១ និងពេលខ្លះយាមខាងក្រៅ ។ តើការយាមនៅក្នុងបរិវេណស-២១ ភ្នំពេញ ឬក៏សាលាទួលស្លែងនេះ លោកមានកាន់កាំភ្លើងដែរឬទេ?

**ឆ៖** យាម បើសិនជាយាមខាងក្នុងមិនមានអាវុធទេ បើយាមខាងក្រៅគេអាចបំពាក់ជាអាវុធ។

**ស៖** សូមអរគុណ ។ ពីព្រឹកលោកបានឆ្លើយនឹងលោកប្រធានអំពីការយាមនៅតាមបន្ទប់ មានបន្ទប់តូចៗ ឃុំអ្នកទោសដាច់ដោយឡែក និងបន្ទប់ឃុំខ្លួនរួម ។ លោកដើរកណ្តាល ហើយលោកមើលតាមចន្លោះប្រហោងដែលគេទុកឲ្យមើលទៅលើអ្នកទោសក្រែងលោមានរួចខ្នោះជើងខ្នោះដៃ ។ សំណួរខ្ញុំសួរថា នៅតាមយ៉ដែលលោកដើរនោះ ពីខាងមុខយ៉ មានន័យថាបែរមកខាងក្រៅនៃអគារដែលលោកយាម គេមានដាក់បន្លែមបន្លាលួសថែមទៀតដែរឬទេ?

**ឆ៖** មាន ។

**ស៖** សូមអរគុណ ។ លោកបានជម្រាបអង្គសវនាការអំពីការបង្គាប់ពីមេ ឬក៏ប្រធានក្រុមរបស់លោកឲ្យការពារកុំឲ្យអ្នកទោសរត់រួច ឬចងកធ្វើអត្តឃាត ។ សំណួរខ្ញុំសួរថា អ្នកទោសនៅក្នុងបន្ទប់រួម តើមានប្រើក្រមាឬទេ?

**ឆ៖** នៅក្នុងបន្ទប់រួមតាមខ្ញុំបានដឹងមិនមានឲ្យប្រើទេ ។

**ស៖** សូមអរគុណ ។ ក្នុងកំឡុងលោកជាអ្នកយាមនៅតាមបន្ទប់អ្នកទោស ទោះបន្ទប់ដាច់ដោយឡែក ឬបន្ទប់រួមក៏ដោយ សហភាព ឬក៏យើងនិយាយថាខ្លួនប្រាណរបស់ទោស ។ តើសក់គេយ៉ាងម៉េច ពុកមាត់គេយ៉ាងម៉េច? នៅពេលនោះលោកចំណាំបានទេមកដល់ពេលនេះថាយ៉ាងម៉េចដែរពេលនោះ?

**ឆ៖** ខ្ញុំមិនបានចំណាំថាអ្នកទោសនោះឈ្មោះអ្វីទេ ព្រោះអ្នកទោសវាច្រើនដែរ ។

**ស៖** ប្រហែលជាលោកស្តាប់មិនទាន់ ខ្ញុំសួរថាក្នុងពេលដែលជាអ្នកយាមនៅតាមអគារដាក់អ្នកទោស តើអ្នកទោសទាំងអស់នោះ ខ្ញុំមិនសួរឈ្មោះទេណ៎ា លោកចំណាំ ឬក៏លោកចងចាំបានទេថា សភាពដងខ្លួនរបស់គេ សក់គេវែងកន្ទ្រើង ឬក៏ដុះពុកមាត់លុបហាក់ដូចជាមនុស្សព្រៃភ្នំមិនដែលស្គាល់កាត់សក់ដែរឬទេ?

[១៣:៣៨:១៣]

**ឆ៖** លោកសួរថា សំណួរសួរថា តើមានសក់ ឬមួយក៏មានរូបរាងស្គមនោះ គឺមាន ។ សក់កន្ទ្រីងកន្ទ្រើង ពុកមាត់ ចង្ការវែងអីគឺមាន ។

**ស៖** សូមអរគុណ ។ ព្រឹកមិញលោកបានជម្រាបអង្គសវនាការដែរ អំពីរឿងថា អ្នកទោសទោះក្នុងបន្ទប់ធំ បន្ទប់រួមក៏ដោយ ឬក៏បន្ទប់ដាច់ដោយឡែកតូចៗក៏ដោយ អ្នកទោសមានតែខោស្លៀក ខ្លះស្លៀកខោស្តើងអាចរូតចេញតាមកងពេលងូតទឹក អ្នកខ្លះអត់មានអាវពាក់ទេ ។ សំណួរសួរថា នៅពេលដែលលោកយាមអ្នកទោសពេលយប់ តើនៅក្នុងអគារ ឬក្នុងបរិវេណមន្ទីរស-២១ នោះមានមូសច្រើនឬទេ?

**ឆ៖** បាទ, ប្រាកដជាមានមូស ។

**ស៖** អ៊ីចឹងមានន័យថាអ្នកទោសមានមុង ឬក៏អត់មុង ហើយបើអត់មុង មូសខាំពេញខ្លួនមែនឬទេ?

**ឆ៖** នេះគឺ-- សំណួរនេះគឺមែន ។

**ស៖** សូមអរគុណ ។ តាមដែលលោកមានប្រសាសន៍ព្រឹកមិញលោកថាអត់សូវចងចាំពីពេលវេលាថ្ងៃខែឆ្នាំទេ ។ ប៉ុន្តែ នៅក្នុងឯកសារបានកត់ត្រាអំពីចម្លើយរបស់លោកថា លោកចូលធ្វើការនៅមន្ទីរស-២១ ឬសារមន្ទីរទួលស្លែងដែលហៅសព្វថ្ងៃនេះពីដើមឆ្នាំ១៩៧៦ រហូតដល់ចុងឆ្នាំ១៩៧៨ ។ អ៊ីចឹងនៅក្នុងនាមជាអ្នកយាម ពេលនោះនៅក្នុងបរិវេណនៃស-២១ មានពេទ្យ ទោះពេទ្យចាក់ថ្នាំក៏ដោយ ឬពេទ្យដើរចែកថ្នាំក៏ដោយ ។ តើមានបុគ្គលិកពេទ្យដែរ ឬទេពេលនោះ?

**ឆ៖** បាទ ពេលនោះបុគ្គលិកពេទ្យ គឺមាន ។

**ស៖** បើសិនជាមានបុគ្គលិកពេទ្យគេនៅសល់ ឬក៏គេមកបង្ហាញខ្លួន លោកអាចចំណាំគេបានដែរទេ?

[១៣:៤១:៣០]

**ឆ៖** ខ្ញុំមិនអាចចំណាំបានទេ ព្រោះវាយូរឆ្នាំណាស់មកហើយដែរ ។

**ស៖** ពាក្យថាចំណាំមិនបានទេនោះ មានន័យថាមិនចំណាំទាំងអស់ ឬលោកអាចចាំបានខ្លះដែរទេ?

**ឆ៖** ខ្ញុំបាទគ្រាន់តែដឹងថាមានពេទ្យគេដើរចែកថ្នាំ ចែកអីអ្នកទោសអ៊ីចឹងមែន ។

**លោក ហុង គីមសួន៖**

សូមអរគុណ ។ សូមអនុញ្ញាតលោកប្រធាន ដើម្បីឲ្យអស់ការសង្ស័យ ខ្ញុំបាទសូមអនុញ្ញាតបង្ហាញដើមបណ្ដឹងជាសាក្សីបានឆ្លើយពីមុនឈ្មោះ ណាំ ម៉ុន ឲ្យសាក្សី ឈុន ផល គាត់មើល តើបានឬទេបាទ? ថាតើគាត់នៅចំណាំបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** សូមអនុញ្ញាត ណាំ ម៉ុន អញ្ជើញដើរទៅខាងមុខនេះ ហើយសូម-- សូមសាក្សីលោក ឈុន ផល ក្រឡេកមើលមកខាងមុខ ។ ដើរទៅមុខតិចទៀត ។ មើលមកអ្នកស្រីនេះ តើលោកអាចចំណាំថាគាត់នេះជាអ្នកណាទេ?

**ឆ៖** ខ្ញុំអត់បានចំណាំទេ រឿងស្រីធ្លាប់ឡើងទៅលើអត់ដែលមានស្រី មានតែពេទ្យដែលប្រុសគេដើរចែកខាងលើ ហ្នឹងខ្ញុំបានជួប បើបងខាងស្រីណោះ ខ្ញុំអត់ដែលបានឃើញទេ ។

**លោក ហុង គីមសួន៖**

សូមអរគុណ ។ សូមអញ្ជើញលោកស្រីត្រលប់មកវិញ ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** សំណួរសួរបន្ត តើបុគ្គលិកនៅក្នុងមន្ទីរស-២១ ពេលនោះ ទាំងអ្នកយាម ទាំងពេទ្យស្លៀកពាក់ខោអាវខ្មៅដូចគ្នាមែនដែរទេ?

**ឆ៖** គឺមែន ។

**ស៖** សូមអរគុណ ។ សំណួរតទៅទៀតទាក់ទងជាមួយនឹងការងូតទឹកទៅឲ្យអ្នកទោស លោកបានជម្រាបអង្គសវនាការព្រឹកមិញថា ដោយសារអ្នកទោសបន្ទប់រួមជាមនុស្សប្រុស ហើយអ្នកយាមក៏ជាប្រុស ។ អ៊ីចឹង វាគ្មានខោអាវណានឹងផ្លាស់ប្ដូរគឺងូតទឹក ដោយបាញ់ទឹកទៅស្រោតទាំងអស់គ្នាឬអ្នកខ្លះ

ដោះខោត្រឹមជង្គង់ ។ សំណួរខ្ញុំសួរថា តើដែលមាននិយាយលេងសើចថា ដូចសាក្សីមុនបាននិយាយថា ដូចសាក្សីមុនបាននិយាយថា ពេលស្រាតអស់ បាញ់ទឹកទៅថា អ្នកនេះប្រដាប់តូចខ្លួនធំ អ្នកនេះប្រដាប់ធំខ្លួនតូចអ៊ីចឹងដែរទេ?

[១៣:៤៥:០៦]

**ឆ៖** នេះត្រង់ខ្ញុំមិនដែលបានថាទេ ក្រែងលោតែវេនគេផ្សេងគេថាទេដឹង ។

**ស៖** សូមអរគុណ ។ ក្នុងនាមលោកអ្នកយាមដដែល សំណួរខ្ញុំសួរថា បន្ទាប់ពីលោកប្រធានព្រឹកមិញនេះ លោកមិនទាន់បានឆ្លើយឲ្យបានច្បាស់លាស់អំពីថា លោកបានដឹងអំពីការរំលោភផ្លូវភេទទៅលើស្ត្រី តើលោកនៅចាំបានថាមេរបស់ឈ្មោះអ៊ីដែលនិយាយប្រាប់លោក?

**ឆ៖** ក្រុមឈ្មោះ គន គាត់បាននិយាយអអ៊ីចឹង ប៉ុន្តែរឿងពិតមិនពិតនឹងគាត់-- ខ្ញុំស្តាប់តែសម្តីរបស់គាត់និយាយទេ ។

**ស៖** ដើម្បីឲ្យច្បាស់លាស់ តើលោកអាចសង្ខេប ឬក៏និយាយខ្លីៗវិញថាមេក្រុមឈ្មោះ គន ហ្នឹងគាត់និយាយអ្វីខ្លះប្រាប់លោកអំពីរឿងរំលោភ ។ មានន័យថា និយាយរឿងប្រាប់យ៉ាងម៉េចខ្លះដែរទេ?

**ឆ៖** រឿងគាត់និយាយប្រាប់ថា តែប៉ុណ្ណឹងទេ ។ គាត់ថាអ្នកដែលរំលោភផ្លូវភេទគេ ត្រូវបានគេចាប់ដាក់គុក ។ គ្រាន់តែប៉ុណ្ណឹងទេ ខ្ញុំអត់មានបានដឹងទេ ។ គាត់និយាយតែប៉ុណ្ណឹងទេ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមសួរតទៅទៀតទាក់ទងជាមួយនឹងអ្នកទោសដែលយកមកឃុំខ្លួននៅបន្ទប់តូចៗ ឬបន្ទប់រួមលោកដែលស្គាល់មនុស្សដែលនៅក្នុងកងរបស់លោក ឬនៅស្រុកភូមិរបស់លោកដែរឬទេ ពេលនោះ?

[១៣:៤៧:២២]

**ឆ៖** នៅក្នុងពេលនោះខ្ញុំមិនបានដែលស្គាល់នៅក្នុងស្រុកក្នុងភូមិទេ ឃើញតែអ្នកដដៃ ភូមិនានាខេត្តនានា ហើយអ៊ីក៏ខេត្តជាមួយដែរដឹង ប៉ុន្តែមិនដែលស្គាល់គ្នា ។

**ស៖** សូមអរគុណ ។ ទាក់ទងជាមួយនឹងម្ហូបអាហារចែកដល់អ្នកទោស លោកថា មានអ្នកផ្សេងទេ គេអ្នកយកទៅឲ្យ ប៉ុន្តែសួរថា លោកបានឃើញទេថាបបរដែលយកទៅចែកឲ្យអ្នកទោសមួយចានឬមួយៗការកំប៉ុងនោះ តើបបរលាយជាមួយនឹងអ្វី?

**ឆ៖** តាមខ្ញុំសង្កេតឃើញដែលខ្ញុំនៅឃើញគេដាក់ដូចថា បបរសអ៊ីចឹងទៅក៏មាន បបរលាយស្ពីៗខ្ញុំអត់បានដឹងទេ ។

**ស៖** សូមអរគុណ ។ ពីព្រឹកមិញលោកបានជម្រាបលោកប្រធាន និងអង្គសវនាការអំពីលោកថាបានឃើញឈ្មោះ ហ៊ា ឈ្មោះ ប៉េង ឈ្មោះហើយលោកមិនដឹងថា អ្នកណាធំជាងហ៊ា ហ្នឹង ប៉េងទៀតទេ ។ សំណួរខ្ញុំសួរថា តើលោកធ្លាប់ឮ ខ្ញុំមិនថាឃើញទេ! ធ្លាប់ឮឈ្មោះ ឌុច ឬបងខាងកើតដែរឬទេកាលនៅក្នុងស-២១?

[១៣:៤៩:២០]

**ឆ៖** ខ្ញុំមិនបានដែលឮទេ ។

**ស៖** សូមអរគុណ ។ នៅក្នុងចម្លើយនៅក្នុងសហាចៅក្រមស៊ើបអង្កេត លោកបាននិយាយថាលោកបានចូលរៀនវគ្គរៀនសូត្រនយោបាយ វាគ្មិនដែលលោកមិនធ្លាប់ស្គាល់ ។ អ៊ីចឹង កន្លែងសាលានយោបាយនោះគេបង្រៀនលោក ឬក៏គេប្រាប់លោក និងបង្គាប់បញ្ជាឲ្យលោកធ្វើអ្វី?

**ឆ៖** កាលបង្គាប់ឲ្យរៀនឲ្យសូត្រទៅតាមក្បួនយុទ្ធិសាស្ត្រឲ្យរៀនពីកម្មវិធីដូចថា ធ្វើទាហានក្បាច់ក្បួនវ៉ៃទាហាន វ៉ៃអីហ្នឹងជាការហាត់ដំ គេបទបញ្ជាឲ្យធ្វើតាមប៉ុណ្ណឹងគឺធ្វើតែប៉ុណ្ណឹងទេ ។

**ស៖** សំណួរខ្ញុំមិនសួរអំពីសាលាយោធា បច្ចេកទេសយោធាទេ ។ ខ្ញុំសួរអំពីសាលនយោបាយនៅក្នុងស-២១ ដែលលោកបានចូលរៀនសូត្រ ឬចូលបំពាក់បំប៉ននយោបាយ ។ អ៊ីចឹងការរៀនសូត្រនយោបាយអង្គការ ឬមេកើយនឹងបានដាក់ទិសឲ្យលោកធ្វើអ្វី?

**ឆ៖** គឺមេកើយ-- មេបានដាក់បញ្ជាក់ថា យាមអ្នកទោសកុំឲ្យរត់រួច ។

**ស៖** បាទសូមអរគុណ ។ សំណួរខ្ញុំសួរទាក់ទងទៅដល់វាលពិឃាដជើងឯកម្តងទៀត ។ ព្រឹកមិញលោកបានឆ្លើយនឹងសំណួររបស់លោកប្រធានអំពីសភាពសាកសពដែលលោកបានកប់ មេប្រើលោកឲ្យទៅកប់ ។ អ៊ីចឹងទាក់ទងនឹងសភាពដូចគ្នាដែរ គ្រាន់តែសួរថា តើលោកកប់សាកសពនោះឃើញសាកសពជាចំណងដៃទាំងពីរទៅក្រោយ ឬចងបិទមុខដែរឬទេ?

**ឆ៖** ពេលដែលខ្ញុំបាទទៅ-- គេចាត់តាំងឲ្យទៅកប់ខ្មោចនៅពេលនោះឃើញមានខ្នោះដៃ ខ្នោះអីតែអ្នកដែលគេដោះ គេដោះទៅខ្ញុំគ្រាន់តែកាយដែកប់តែប៉ុណ្ណឹង ។

**ស៖** សំណួរចុងក្រោយសួរថា តាំងពីលោកចូលធ្វើការជាអ្នកយាមនៅមន្ទីរស-២១ ភ្នំពេញ ឬសាលាទួលស្លែងនេះ ។ តើបុគ្គលិកដែលធ្វើការជំនាន់លោកត្រូវបានចាប់ខ្លួនយកទៅស្លាប់ច្រើនដែរឬទេ?

**ឆ៖** តាមការយក ចាប់យកទៅសម្លាប់ខ្ញុំមិនបានដឹង ក៏ប៉ុន្តែមានដូចថា មេក្រុមខ្ញុំអីហ្នឹងមានគេចាប់ដាក់ក្នុងនុ៎ងដែរ ។

[១៣:៥៣:១៦]

**ស៖** តើលោកមានស្គាល់សាស្ត្រាចារ្យ ឬបញ្ញវន្តពីជំនាន់ លន់ នល់ ត្រូវបានគេឃុំខ្លួនបន្ទប់ដែលលោកយាមដែរឬទេ? សូមអរគុណលោកប្រធានសូម-- បើសល់ពេលសុំអនុញ្ញាតឲ្យមេធាវីខាងបរទេសបន្តទៀត ។

**ប្រធានអង្គជំនុំ៖**

មិនត្រឹមតែសល់ទេ ឥឡូវចាយលើសហើយ ។ ជាបន្តសូមប្រគល់វេទិកាទៅមេធាវីការពារក្តីបើមានសំណួរចង់សួរដល់សាក្សីរូបនេះសូមអញ្ជើញ។ លោកមេធាវីការពារក្តីមានពេលម្ភៃនាទី ។

**ការតាំងសំណួរដោយមេធាវីការពារក្តី៖**

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន និងសូមគោរពលោកប្រធាន សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ និងសូមគោរពអង្គសវនាការទាំងមូល ។

**ស៖** លោក ឈុន ផល ព្រឹកមិញលោកបាននិយាយថា លោកស្គាល់ឈ្មោះ សើ ។ ថាឈ្មោះ សើ នេះបានឲ្យលោកទៅកប់ខ្មោចនៅជើងឯក ។ តើឈ្មោះ សើ ជាពួកមកពីទឹកផុសជាមួយលោក ឬក៏មកពីស្អាងកោះធំ សូមលោកបញ្ជាក់?

**ឆ៖** ត្រង់ថាមកពីខេត្តជាមួយខ្ញុំ ខ្ញុំមិនក៏ខ្ញុំមិនដឹង ។ គាត់មកពីខេត្តណាក៏ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំអត់បានមើលប្រវត្តិ អត់បានដឹងរឿងគាត់នៅឃុំណា ខេត្តណានោះទេ ។

**ស៖** សូមអរគុណលោក សូមលោកជួយបញ្ជាក់ថែមទៀត តើឈ្មោះ សើ នោះគាត់វាមានកម្ពស់ហ្នឹងវាខ្ពស់ឬទាប? គាត់អាយុប្រហែលជាប៉ុន្មានកាលគេប្រើលោកនោះ? ហើយតើសម្បុរគាត់នុំងសឬខ្មៅ សូមលោកជួយបញ្ជាក់?

[១៣:៥៥:៤៨]

**ឆ៖** សម្បុរគាត់មិនស មិនខ្មៅទេ តែគ្រាន់កណ្តាល ប៉ុន្តែថាខ្ញុំមើលមិនចំណាំបានទេ មកដល់បច្ចុប្បន្ននេះ ។

**ស៖** សូមអរគុណ សូមលោកបញ្ជាក់ថែមទៀត តើអ្នកយាមៗដូចលោកអអ៊ីចឹង មានសិទ្ធិវាយអ្នកទោសឬទេ?

**ឆ៖** អ្នកយាមមានសិទ្ធិអ្នកទោសទាល់តែមានបទបញ្ជាពីមេក្រុមបានវ៉ៃ បានធ្វើបានវ៉ៃគាត់បាន។

**សៈ** សូមអរគុណ នៅក្នុងចម្លើយរបស់លោកដែលឆ្លើយនៅចៅក្រមអង្កេត លោកបាននិយាយថា បើអ្នកយាមវាយអ្នកទោសគេចោទថាក្បត់ អ៊ីចឹងមែនទេ?

**ឆៈ** មែន ។

**សៈ** សូមអរគុណ ។ នៅឯកសារលេខ D28/15 ERN00163808 លោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា លោកមាននាទីបាញ់ទុយោទឹកឱ្យអ្នកទោសងូតទឹក តែពេលសវនាការនេះ លោកបានជម្រាបតុលាការថា លោកហុចទុយោទឹកឱ្យអ្នកទោសងូតទៅបន្តៗគ្នា ។ អ៊ីចឹង តើការពិតបាញ់ទុយោទឹកឱ្យអ្នកទោសងូត ឬក៏លោកហុចទុយោទឹកឱ្យអ្នកទោសងូតតៗគ្នា សូមលោកបញ្ជាក់ម្តងទៀត សូមឱ្យបានច្បាស់?

[១៣:៥៨:០៧]

**ឆៈ** នេះខ្ញុំចង់និយាយ ខ្ញុំគ្រាន់តែកាន់ទៅមិនបានបាញ់ទេ ។ គ្រាន់តែកាន់ទៅ គ្រាន់តែអូសពីមួយទៅឱ្យមួយប៉ុណ្ណោះទេ ។ មិនបានបាញ់ពីចម្ងាយដាក់អ្នកទោសនោះទេ ។

**សៈ** អ៊ីចឹង បានសេចក្តីថា លោកបដិសេធចម្លើយកាលឆ្លើយនៅជាមួយអ្នកអង្កេតអ៊ីចឹង? ព្រោះអង្គាល់នៅអ្នកអង្កេតលោកឆ្លើយថា លោកបាញ់ទុយោទឹកហ្នឹងឱ្យអ្នកទោសងូត ហើយនៅពេលសវនា-ការនេះ លោកបានជម្រាបតុលាការថា ហុចទុយោ ដូចលោកជម្រាបអំមិញអ៊ីចឹងឱ្យអ្នកទោសងូតតៗ។ អ៊ីចឹងលោកបដិសេធចម្លើយកាលអ្នកអង្កេត ឬមិនបដិសេធ?

**ឆៈ** រឿងនេះ ដូចជាខ្ញុំបាននិយាយអំមិញថា ខ្ញុំមិនបដិសេធទេ រឿងកាលដែលខ្ញុំនិយាយខ្ញុំកាន់ ខ្ញុំកាន់ឱ្យអ្នកពីមួយទៅមួយៗចួនកាលទៅក៏បាញ់ខ្លះអីខ្លះអ៊ីចឹងទៅ មិនមែនបាញ់រហូតទេ។ ហ្នឹងខ្ញុំបញ្ជាក់គ្រាន់តែប៉ុណ្ណឹងទេ ។ ខ្ញុំមិនមែនថា យកទៅកាន់បាញ់ឱ្យងូតគ្រប់ៗគ្នាក៏ខ្ញុំអត់ថាដែរ អានេះក្នុងលក្ខណៈថា ខ្ញុំចួនកាលបាញ់ឱ្យងូតទៅ ហើយខ្លះទៅក៏ឱ្យងូតទៅ ។ ខ្ញុំចង់និយាយថាអ៊ីចឹង ។ រឿងហ្នឹងវាតែប៉ុណ្ណឹងទេ ។

**សៈ** សូមអរគុណ ។ តើលោកដែលឃើញអ្នកយាមៗដូចលោក មិនមែនលោកទេ អ្នកយាមដូចលោកហ្នឹងឱ្យអ្នកទោសទៅងូតទឹកពាងខាងក្រៅ មានដែលឃើញទេ?

**ឆៈ** គឺខ្ញុំមិនដែលឃើញ ។

**សៈ** សូមអរគុណ ។ ពេលលោកយាម ឧបមាថា គេឱ្យលោកយាមបន្ទប់ណាមួយ ឬក៏កន្លែងណាមួយ តើលោកអាចដើរទៅកន្លែងផ្សេង ក្បែរហ្នឹងបានទេ?

**ឆ៖** ពេលដែលគេដាក់ឱ្យយាមនៅកន្លែងទីតាំងណា កន្លែងណា ព្រំប្រទល់ត្រឹមមាណ គឺបានត្រឹមហ្នឹងទេ ។ មិនអាចដើរហួសបាន ជាដាច់ខាត់ ទាល់តែមានការអនុញ្ញាតពីមេក្រុមបានដើរបាន ។

**សៈ** សូមអរគុណ ។ បើដើរ បើលោកមិនដើរទៅកន្លែងផ្សេងបាន ពេលលោកយាម ម៉េចបានលោកដឹងថា មានកន្លែងអ្នកយាមផ្សេងទៀត មានអ្នកទោសងាប់ អ្នកទោសស្លាប់ ។

**ឆ៖** នេះដឹងថាមាន បន្ទប់ កាលណាក្នុងតួនាទីរបស់ខ្ញុំ គឺខ្ញុំយាមតែបីបន្ទប់ ។ បន្ទប់ធំៗហ្នឹងមានអ្នកផ្សេងទៀត បីទៀតអ៊ីចឹងទៅ ។ ម្ល៉ោះហើយ កាលណាដើរទៅជួបគ្នាទៅ បកមុខបកក្រោយមក កាលណាអ៊ីចឹងពន្លឺតែមួយនិយាយទៅ វាអាចថាស្លាប់បាន ហើយវាអាចស្លាប់បាន ឬមួយក៏យើងមកដល់ក្រៅវិញទៅ មានការដូចថា ក្រុមជាមួយអី ជាមួយអ៊ីចឹងទៅ មានការនិយាយថា អ៎! អ្នកយាមនៅសាលនោះ មានអ្នកទោសត្រូវស្លាប់ ត្រូវអីអ៊ីចឹងទៅ ។ ខ្ញុំបញ្ជាក់ ខ្ញុំដែរបានដឹងច្បាស់តែប៉ុណ្ណឹងទេ ។

**សៈ** សូមអរគុណ ។ អ៊ីចឹង អ្នកយាមហ្នឹង ពេលដែលយាមហ្នឹង ដើរជួបគ្នានិយាយគ្នាបាន គេគ្មានឲ្យវិន័យតឹងតែងថា និយាយគ្នាមិនបានទេ? សូមលោកបញ្ជាក់មើល ។

**ឆ៖** ដើរជួបគ្នាអាចនិយាយគ្នាបាន ។ គ្មានការអី ដែលតឹកតែងនោះទេ ព្រោះថា ជួបគ្នាអាចនិយាយគ្នាបាន ។

**សៈ** សូមអរគុណ ។ សូមលោកបញ្ជាក់មួយចំណុចទៀត តើនៅស-២១ លោកដែលឃើញពេទ្យជាស្ត្រីទេ? ហើយមានពេទ្យជាកុមារទេ គេហៅថា កុមារនោះ? លោកមានដែលឃើញទេ? សូមលោកជួយបញ្ជាក់ ។

**ឆ៖** ខ្ញុំបានដឹងត្រង់ថា ពេទ្យស្រី ខ្ញុំអត់បានឃើញ ។ បើពេទ្យប្រុសជាកុមារដែរ ខ្ញុំអាចថាធ្លាប់បានឃើញមាន ដើរចែកថ្នាំ ចែកអីអ៊ីចឹងដែរ ។

**សៈ** សូមអរគុណ ។ ពេលលោកយាមខាងក្រៅ ក្បែរមាត់ច្រកចូលៗ គឺក្បែរផ្ទះពេទ្យ ។ តើលោកដែលឃើញពេទ្យបូមឈាមអ្នកទោសឬទេ? សូមលោកបញ្ជាក់ ។

**ឆ៖** ខ្ញុំយាមនៅខាងក្រៅ មិនអាចមើលឃើញពេទ្យធ្វើការនៅខាងក្នុងនោះទេ ។

**សៈ** សូមអរគុណ ។ នៅស-២១ ពេលដែលលោកនៅស-២១ គេចាត់តាំងលោកឱ្យយាមអ្នកទោស កុំឱ្យអ្នកទោសរត់រួច ។ តើពេលនោះ-- ខ្ញុំសួរពេលនុ៎ង តើលោកពេញចិត្តសប្បាយរីករាយនិងការងាររបស់លោកពេលនោះឬទេ?

**ឆ៖** ពេលនោះខ្ញុំបាននឹកក្នុងចិត្តថា ទោះបីសប្បាយ ឬមួយមិនសប្បាយ ខ្ញុំមិនដឹងជាគេចវេស រត់ទៅឯណារួចដែរ ព្រោះរបបនោះ គឺមានតែមួយ ។

**ស៖** អ៊ីចឹង ខ្ញុំសូមឲ្យលោកបញ្ជាក់ឡើងទៀតថា លោកទោះមិនសប្បាយ ឬវាទោះសប្បាយ ក៏មិនដឹងរត់ទៅឯណា? ចុះពេលនោះ ក្នុងរបបនោះ លោករត់ទៅណាអត់រួចទេ? សូមលោកបញ្ជាក់មើល បើចង់រត់ តើលោករត់រួចឬទេ?

[១៤:០៥:១២]

**ឆ៖** គឺរត់ៗ មិនរួច ជាការពិត ។

**ស៖** អ៊ីចឹង សូមលោកបញ្ជាក់បន្ថែមទៀត អ្នកណាក៏ដោយ ដែលមិនពេញចិត្តក្នុងរបបនោះគឺរត់មិនរួចអ៊ីចឹងតែម្ដង ឬយ៉ាងម៉េច?

**ឆ៖** គឺរត់អត់រួចមែន ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ លោកប្រធាន ។ សូមឲ្យសហមេធាវីអន្តរជាតិ សួរបន្ត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ សហមេធាវី-- មេធាវីការពារអន្តរជាតិ ។

**សួរដោយលោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

សូមលោកអរគុណ លោកប្រធាន ។

**ស៖** លោកសាក្សី សូមរំឭកប្រាប់យើង តើលោកធ្វើជាអ្នកយាមនៅស-២១ នោះ អស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** រឿងយាមនៅស-២១ ខ្ញុំបាទ មិនបានកត់ត្រា ឬមួយចំណាំឆ្នាំ ឬមួយខែ ឬមួយពេល បានទេ ព្រោះខ្ញុំមិនបានមានរបស់កត់ត្រាទេ ។

**ស៖** តើលោកអាចប៉ាន់ប្រមាណបានទេ ថាប៉ុន្មានខែ? ឬក៏ប៉ុន្មានឆ្នាំ? ខ្ញុំគិតថា តើលោកសាក្សីយល់សំណួរខ្ញុំដែរឬទេ? ឬក៏លោកស្តាប់ឮទេ សំណួរអម្បាញ់មិញនោះ?

**ឆ៖** សួរស្តាប់អត់បានទេ ។ សួរម្តងទៀត ។

**ស៖** លោកបានឆ្លើយសំណួរទីមួយរបស់ខ្ញុំ ប្រាប់ខ្ញុំថា លោកមិនអាចដឹងថារយៈពេលប៉ុនណាទេ? ដែលលោកយាមនៅទីនោះ មិនដឹងមានអីកត់ មិនបានកត់ ។ អ៊ីចឹង តើលោកអាចបញ្ជាក់បានទេ

ថាតើលោកប៉ាន់ប្រមាណបានទេ? ថាតើធ្វើការនៅកន្លែងនោះប៉ុន្មានខែ? ឬក៏ប៉ុន្មានឆ្នាំ? ជាការប៉ាន់ប្រមាណ ។

**ឆ៖** ខ្ញុំដូចបានបញ្ជាក់ថា កាត់ប៉ាន់ស្មាន គឺខ្ញុំកាត់មិនត្រូវទេ ។

**ស៖** អ៊ីចឹង គឺថាអាចរយ:ពេលមួយ ។ អ៊ីចឹង នៅក្នុងពេលដែលសួរតទល់គ្នា នៅថ្ងៃទី២៨ កុម្ភៈ ២០០៨ លោកប្រាប់ចៅក្រមស៊ើបអង្កេតថា លោកស្គាល់ជនជាប់ចោទ ប៉ុន្តែព្រឹកមិញនេះ លោកបានបញ្ជាក់ជូនអង្គជំនុំជម្រះថា ដោយធ្វើការបញ្ជាក់ថា លោកមិនដែលបានឃើញ ឬក៏មិនបានជួបគាត់ទេ ។ អ៊ីចឹង ខ្ញុំអាចសន្និដ្ឋានថា លោកក៏មិនបាមនិយាយជាមួយគាត់ដែរកាលណោះ តើខ្ញុំអាចនិយាយបានទេថា តាមពិត ឌុច មិនដែល ឬក៏ក្នុងករណីណាមួយ មិនដែលទៅអគារ ឬទៅអគារមួយចំនួន កន្លែងដែលលោកធ្វើការនោះទេ? តើអ៊ីចឹងមែនឬទេ?

**ឆ៖** គឺមែន ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំមិនមានសំណួរសួរទៅសាក្សីទៀតទេ ។

សូមអរគុណ ។

[១៤:០៩:៤៩]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះផ្តល់ឱកាសទៅជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់នូវសក្ខីកម្មរបស់សាក្សីរូបនេះ ប្រសិនបើ ជនជាប់ចោទមានបំណង ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ដំបូង ខ្ញុំសូមបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំទទួលស្គាល់មិត្ត ផល នេះជាបុគ្គលិករបស់មន្ទីរស-២១ ពិតប្រាកដ ។ មូលហេតុ គាត់នៅក្នុងចំណោមក្មេងជំទង់ ដែលខ្ញុំទៅសុំពីកំពង់ឆ្នាំងមក ។ ស្រុកគាត់ពីកំពង់ក្រឡាច អាយុគាត់តិចជាង១៦ឆ្នាំ គឺស្ថិតនៅក្នុងជម្រើសដែលយើងខ្ញុំទៅសុំពីមូលដ្ឋានពិតមែនហើយ ។ ហើយវណ្ណភាពគាត់ជាវណ្ណភាពកសិករក្រ ។ ម្ល៉ោះហើយ សមត្ថ-ភាពវប្បធម៌ក៏តិច ដូចអង្គសវនាការឃើញការឃើញស្រាប់ហើយ ប្រហែលជាអាចអានបានមួយម៉ាត់ពីរទាំងត្រដាប់ត្រដួសផង ។ នេះជាជម្រើសហើយ ដែលខ្ញុំទៅសុំយកពីមូលដ្ឋានមក ហើយអាយុ១៥, ១៦ នេះ ក៏ជាជម្រើសរបស់ខ្ញុំដែរ ខ្ញុំអត់ចង់បានបុគ្គលិកដែលមានអ្នកផ្សេងទៀត គេអប់រំរួចទៅហើយ

ទេ ។ ខ្ញុំចង់បានបុគ្គលិកដែលមានលក្ខណៈថ្នោងថ្មី ទាំងខាងនយោបាយ ទាំងខាងចាត់តាំង ។ នេះខ្ញុំសូមរៀបរាប់ប៉ុណ្ណេះ ។

ឯចំណែក ជំហរសតិអារម្មណ៍របស់មិត្ត ផល ក៏អង្គសវនាការឃើញហើយ ជាមនុស្សអត់ចង់មាន អត់ចង់បាន អត់ចង់ដឹង អត់ចង់ឮ អត់បានបុណ្យស័ក្តិអីទេ ។ សូម្បីតែមុខខ្ញុំ ដែលជាមេនៅទីនេះ ក៏គាត់អត់បានចង់ដឹង ចង់ឮ ចង់ឃើញដែរ ដោយសារទិដ្ឋភាពនេះហើយ ដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍ថាគាត់ប្រហែលជាបុគ្គលិករបស់មន្ទីរស-២១ មែន ។ ដល់គាត់និយាយថា មេរបស់គាត់ម្នាក់ឲ្យគាត់ទៅដឹកនៅជើងឯក ឈ្មោះ មិត្ត សើ ច្បាស់ ពិតជាបុគ្គលិករបស់មន្ទីរស-២១ ហើយ ។ មិត្ត សើជានីរសារទីមួយរបស់ខ្ញុំ ដែលខ្ញុំប្រគល់ទៅឲ្យមិត្ត ហ៊ី ឲ្យចូលក្នុងកងពិសេស ។ ដូច្នេះ អាការទៅខាងបឹងជើងឯកនេះ គឺការងាររបស់កងពិសេស ។

ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំអត់ប្រកែកទេ មិត្តផល ជាបុគ្គលិករបស់ខ្ញុំ ។ ដោយឡែក សក្ខីកម្មរបស់គាត់ មានធ្វើឲ្យច្របូកច្របល់ខ្លះ ក៏ពិតមែន ដូចជាគាត់និយាយថា ឡានរបស់ស-២១ មានស្លាក ។ សាលានយោបាយរបស់ខ្ញុំ ដែលខ្ញុំចាត់តាំងនោះ ក៏មានស្លាកសាលានយោបាយដែរ នេះច្របូកច្របល់បន្តិចហើយ ។ ហើយគាត់មានប្រសាសន៍ថា ចូលមកដំបូងទៅនៅតាខ្មៅ ធ្វើស្រែព្រៃកហូរ ។ ស-២១ អត់មានដីទៅព្រៃកហូរទេ។ ដូច្នេះ រឿងនេះវាខុសបន្តិចបន្តួច វាជារឿងកំប៉ិកកំប៉ុកដែលគាត់ចាំមិនបាន។ ក៏ប៉ុន្តែព្រឹកមិញមានប្រវត្តិរូបមួយឲ្យមកខ្ញុំដែរ ប្រវត្តិរូបមិត្ត ផល ។ ខ្ញុំសូមបញ្ជាក់ថាខ្ញុំសូមទុកពេលវេលាពិចារណាប្រវត្តិរូបនេះ បន្តិចសិន ទម្រង់នៃការធ្វើការប្រវត្តិរូប ។

ខ្ញុំសូមបញ្ជាក់ថាតាមខ្ញុំចាំ ក្រោយ១៧ មេសា ១៩៧៥ រហូតដល់ចប់ ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជា បានឲ្យគេចេញទៅត្រួតពិនិត្យប្រវត្តិរូបកម្មាភិបាល ។ សមាសភាព៧០៣ ដែលចូលមកស-២១ ណាត គាត់ឲ្យ យូ ប៉េងគ្រី ហៅ ប៉ុន ដើរទៅពិនិត្យតាមដានគ្រប់កន្លែង ។ ឯចំណែក ពួកមកពី ម-១៣ ខ្ញុំអត់ឲ្យអ្នកណាចេញទេ ព្រោះខ្ញុំធានាប្រវត្តិរូបរបស់មិត្តអស់ហ្នឹង ចំពោះមុខបក្ស ។ ដោយឡែក មកពីខាងកំពង់ឆ្នាំង បើថាប្រវត្តិរូបនេះ ធ្វើមុនចូលមកដល់ស-២១ អាហ្នឹងមែន ។ រួចដល់ប្រវត្តិរូបនេះ ធ្វើនៅឆ្នាំ១៩៧៧ ដូចដែរឯកសារឲ្យមក ខ្ញុំសម្តែងការចាប់អារម្មណ៍សង្ស័យ សុំទុកពេលពិនិត្យ តើលក្ខខណ្ឌនោះយ៉ាងម៉េច? បាន១ចេញអាប្រវត្តិរូបបែបនេះ រហូតដល់ឆ្នាំ១៩៧៧ ទៅហើយ ។ ខ្ញុំសូមបញ្ជាក់ថា របៀបរបបធ្វើប្រវត្តិរូបរបស់បក្សកុម្មុយនីស្តកម្ពុជា គឺយ៉ាងនេះ ។ ខ្ញុំជាកម្មាភិបាលបក្ស គឺជាបក្ខជនមួយរូប ពេលទៅរៀនសូត្រនយោបាយ រាល់ឆ្នាំគេឲ្យខ្ញុំធ្វើប្រវត្តិរូបបដិវត្តន៍ និងជីវទស្សនបដិវត្តន៍

ហើយគេឲ្យដាក់ខ្លួនឲ្យសម្ងហភាពកសាង ក្រែងលោកមានអ្នកណាលាក់ប្រវត្តិរូបត្រង់កន្លែងណា ខ្លួនឯងជំពាក់ជំពិននឹងខ្មាំងឲ្យអ្នកដែលដឹងឮ គេជួយមតិទៅវាបែក ។ ដូច្នេះ ប្រវត្តិរូប តាមពិតគេធ្វើរាល់ឆ្នាំនៅពេលទៅរៀន ជីវទស្សនៈបដិវត្តន៍ក៏គេធ្វើរាល់ឆ្នាំ ។ ឯចំណែកយុទ្ធជនធម្មតា ដូចមិត្ត ផល ខ្ញុំមិនជឿថា ធ្វើប្រវត្តិរូបអីវែងអន្លាយ ហើយដល់ទៅមានស៊ីញ៉េភូមិ ស៊ីញ៉េអីទៀត ។ ខ្ញុំសូមសម្តែងជាការចាប់អារម្មណ៍សង្ស័យចំពោះឯកសារមួយនេះ តើវាយ៉ាងម៉េច? ក៏ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ខ្ញុំនៅតែទទួលស្គាល់ថា មិត្តផល គឺពិតជាបុគ្គលិករបស់ ស-២១ ។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

លោក ឈុន ផល អង្គជំនុំជម្រះអរគុណលោកដែលបានអញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតាមការកោះហៅ ហើយអង្គជំនុំជម្រះក៏យល់ផងដែរថា ការដែលលោកមកធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ វាប្រឈមនឹងការលំបាកជាច្រើនសម្រាប់លោក ដូចជាលោកត្រូវឆ្លើយនូវសំណួរជាច្រើនពីភាគីនានា និងពីអង្គជំនុំជម្រះ ។ ហើយសំណួរនេះសោតក៏ជាសំណួរ ដែលមានចំនួនច្រើនសម្រាប់ពេលវេលាដែលលោកត្រូវធ្វើសក្ខីកម្ម ។ ម្យ៉ាងវិញទៀត ដោយរឿងហេតុដែលកើតឡើងអស់រយៈពេលជាងសាមសិបឆ្នាំមកហើយ ។ ដូច្នេះ កម្រិតនៃការចងចាំរបស់មនុស្ស គឺជាទូទៅ គឺលក្ខណៈធម្មជាតិតែងតែមានការភ្លេចភ្លាំង ពេលកាន់តែយូរ កម្រិតនៃការចងចាំកាន់តែតិចទៅ ឬក៏ភ្លេចពេលខ្លះក៏មិនចងចាំសោះ ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ គឺអង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោកបានធ្វើការអត់ធ្មត់ ហើយនិងព្យាយាមក្នុងការឆ្លើយតបទៅនឹងសំណួរ ទៅតាមកម្រិតយល់ដឹង និងទៅតាមអ្វីដែលលោកចងចាំ ។ ឥឡូវនេះ អស់សំណួរហើយ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកវិលត្រលប់ទៅកាន់លំនៅដ្ឋានរបស់លោកវិញ ។

មន្ត្រីតុលាការសម្របសម្រួលជូនសាក្សីរូបនេះទៅទាក់ទងជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីឲ្យគាត់ ខាងអង្គភាពនោះរៀបចំជូនដំណើរគាត់ត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ ។ ហើយបង្គាប់ឲ្យមន្ត្រីតុលាការអញ្ជើញសាក្សីមួយរូបទៀត ឈ្មោះ សោម ម៉េត ចូលមកកាន់បន្ទប់សវនាការ ។

*[សាក្សី សោម ម៉េត ចូលមកកាន់បន្ទប់សវនាការ]*

[១៤:១៩:៥៦]

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សាក្សី តើលោកឈ្មោះ សោម ម៉េត អ៊ីចឹងមែនដែរឬទេ?

**លោក សោម ម៉េត៖**

**ឆ៖** បាទ, លោក អ៊ីចឹងមែន ។

**ស៖** លោកដែលប្រើឈ្មោះអ្វីផ្សេងក្រៅពីឈ្មោះ ម៉េត ដែរឬទេ?

**ឆ៖** បាទ, លោក អត់មានទេ ។

**ស៖** តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ៥១ឆ្នាំ ។

**ស៖** តើលោកប្រកបមុខរបរអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** សព្វថ្ងៃធ្វើស្រែចម្ការ ។

**ស៖** តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការពីព្រឹកមិញថា លោកពុំមានចំណងជាញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីនៃរឿងក្ដីនេះទេ តើនេះជាការពិតដែរឬទេ?

**ឆ៖** ពិត ។

**ស៖** តើលោកបានស្បថរួចហើយឬនៅ? មុនពេលចូលមកនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** បានស្បថហើយ ។

**ស៖** ឥឡូវនេះយើងប្រាប់អំពីសិទ្ធិនិងករណីដល់លោក ក្នុងនាមលោកជាសាក្សី ដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដូចខាងក្រោម៖

លោក សោម ម៉េត ក្នុងនាមលោកជាសាក្សី លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏ការឲ្យធ្វើអំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនលោក គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬក៏អំណះអំណាងនាំឲ្យលោកត្រូវប្រឈមនឹងការចោទប្រកាន់ ។ ទន្ទឹមនឹងនេះ លោក សោម ម៉េត ក្នុងនាមលោកជាសាក្សី លោកមានករណីយកិច្ចនិយាយប្រាប់ដល់អង្គសវនាការ នូវការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញដោយផ្ទាល់ ដែលលោកត្រូវឆ្លើយតបទៅនឹងសំណួរ និងការដែលលោកឆ្លើយមិនគប្បីឆ្លើយជាសេចក្ដីសន្និដ្ឋាន

ផ្ទាល់ខ្លួនរបស់លោកនោះឡើយ ។

[១៤:២២:៤៨]

លោក សោម ម៉េត តើលោករស់នៅទីណា? ហើយលោកធ្វើអ្វីខ្លះនៅក្នុងចន្លោះឆ្នាំ១៩៧០ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩?

**ឆ៖** បាទ,លោក ឆ្នាំ១៩៧០ គឺខ្ញុំនៅក្នុងបន្ទុកគ្រួសារជាមួយឪពុកម្តាយ រហូតមកដល់ឆ្នាំ១៩៧២ ខ្ញុំបានចាកចេញពីម្តាយ ទៅរៀននៅសាលាវត្តព្រៃកស្តី ជាកូនសិស្សលោកផង ។ ដូច្នេះ ខ្ញុំរៀនបានតែមួយឆ្នាំទេ គឺបញ្ចប់ការរៀនសូត្របានថ្នាក់ទី១២ ។ រហូតមកដល់ខ្ញុំរួមរស់ជាមួយម្តាយខ្ញុំវិញ ដើម្បីធ្វើស្រែចម្ការ ។ ដល់ឆ្នាំ១៩៧៣ ដើមឆ្នាំ៧៣ គឺខ្ញុំ អង្គការបានចាត់តាំងឲ្យខ្ញុំធ្វើការនៅឃុំព្រៃកស្តី រហូតមកដល់ចុងឆ្នាំ១៩៧៣ដដែល គឺអង្គការបានចាត់តាំងឲ្យខ្ញុំធ្វើយោធាស្រុក១៨ ។ រហូតមកដល់ឆ្នាំ១៩៧៤ ខ្ញុំធ្វើយោធាដដែល អង្គការបានចាត់តាំងឲ្យខ្ញុំទៅវាយគ្នាជាមួយទាហាន លន់ នល់ នៅដងទន្លេមេគង្គ ។ រហូតមកដល់ឆ្នាំ១៩៧៥ គឺគេរំដោះទីក្រុងភ្នំពេញបានទាំងស្រុង ។ ក្រោយមក ខ្ញុំក៏បាននៅទីក្រុងភ្នំពេញបានតែកន្លះខែទេ ។ ដូច្នេះ អង្គការបានចាត់តាំងខ្ញុំ នីរសារតាមវរសេនាតូច វរសេនាធំចំនួនហាសិបនាក់ ដើម្បីយកមករៀននៅសាលាបច្ចេកទេសយោធាតាខ្មៅ ។ សរុបទាំងអស់ ទាំងអង្គភាព៧០៣ផង ជាងពីររយនាក់ ទាំងរៀននយោបាយ ទាំងរៀនបច្ចេកទេសយោធាផង ទាំងអស់ជាងប្រាំបីខែ ។ បញ្ចប់ការសិក្សានៅឆ្នាំ១៩៧៦ អង្គការក៏បានចាត់តាំងអង្គភាពនីរសារឲ្យទៅយាមអ្នកទោសនៅកន្លែងអគ្គសេនាធិការកងពល៧០៣ ជិតពេទ្យមុនីវង្ស កន្លែងនោះគេហៅថា “គុកដាំផេង” គឺប្រធាន គឺថាមានតែបងណាត ទេកន្លែងហ្នឹង អនុប្រធានខ្ញុំអត់បានដឹងដែរ ។ ប៉ុន្តែ ដែលខ្ញុំនៅនេះគឺថា បានឃើញដូចបង ឌុច, បងហ៊ឺ, បងចាន់, បងប៉ុន ក៏គាត់នៅទីហ្នឹងដែរ ។ ប៉ុន្តែបង ឌុច, បងចាន់ ហើយនិង បងប៉ុន ហ្នឹង គឺថាគាត់ទៅមកៗទេមិនដឹងកន្លែងគាត់នៅកន្លែងណាទេ ។ ហ្នឹងតាមខ្ញុំចាំ ហើយគឺថាពិតហើយដែលខ្ញុំនិយាយគឺថា ខ្ញុំអត់ពន្លើសទេ ។ រហូតមកដល់ឆ្នាំ១៩៧៧, ៧៨ អង្គការក៏បានចាត់តាំងអង្គភាពនីរសារឲ្យទៅយាមអ្នកទោសនៅមន្ទីរ ស-២១ គុកទួលស្លែង ។ ដូច្នេះ អង្គភាពនីរសារមួយចំនួនដែលចេះអក្សរ គឺគេដកទៅខាងផ្នែកកងសួរចម្លើយ ។ នីរសារមួយចំនួន គឺថាអត់ចេះអក្សរ គឺគេឲ្យយាមអ្នកទោស ។

ដូច្នេះ ដូចយើងខ្ញុំ គឺថាមិនបានយាមនៅក្នុងអគារក្នុងទេ យាមតាមផ្ទះថ្មនៅខាងត្បូងអគារ កន្លែងនោះគឺហៅថា“គុកពិសេសរបស់មន្ទីរស-២១” គឺអ្នកគ្រប់គ្រងកន្លែងហ្នឹងមានតែ បងហ៊ុយ ហើយស្រ៊ី ទេ ដែលជាប្រធានកង និងអនុកង ។ សូមអស់ ។

**ស៖** ហើយរហូតដល់ពេលណាទើបលោក បានចាកចេញពីមន្ទីរស-២១? លោកនៅចងចាំដែរឬទេ?

**ឆ៖** បាទ, លោក! ចុងឆ្នាំ៧៨ នេះ គឺថា ខ្ញុំអង្គការបានដកខ្ញុំឱ្យទៅនៅព្រៃស ។ ដកបានប្រហែលជាងមួយខែ គឺថាវៀតណាមចូល ។ សូមអស់ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីសួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញលោកចៅក្រម យ៉ា សុខន ។

**សួរដោយចៅក្រម យ៉ា សុខន៖**

សូមអរគុណលោកប្រធាន ។

**ស៖** នៅពេលលោកយាមនៅគុកដាំផេង លោកគេប្រគល់ភារកិច្ចអ្វីឱ្យលោកធ្វើនៅទីនោះ?

**ឆ៖** បាទ, លោក! ខ្ញុំនៅកន្លែងហ្នឹងគឺថានៅជាកុមារទេ ប៉ុន្តែគេឱ្យយាមអ្នកទោស ។ សូមអស់។

**ស៖** អ្នកទោសទាំងអស់នោះ គេដាក់នៅកន្លែងណា?

**ឆ៖** អ្នកទោសទាំងអស់ហ្នឹង គឺថាគេដាក់នៅតាមផ្ទះទាមនៅនឹងដីទេ ។ សូមអស់ ។

**ស៖** អ្នកទោសទាំងអស់នោះមានគេដាក់ខ្នោះទេ នៅពេលដែលគេឃុំខ្លួននៅតាមផ្ទះទាមនោះ?

**ឆ៖** បាទ,លោកធម្មតា អ្នកទោស គឺថាគេដាក់ខ្នោះទាំងអស់គ្នាហ្នឹង ។ ដាក់ជាប់គ្នាតាមបន្ទប់មួយៗៗរហូត ។

[១៤:៣០:០០]

**ស៖** តើគេដាក់ខ្នោះជើង ឬខ្នោះដៃនៅតាមបន្ទប់ ដែលគេឃុំហ្នឹងលោក?

**ឆ៖** បាទ, គេដាក់ខ្នោះជើងទេ ។

**ស៖** លោកមានកត់សម្គាល់ទេថា នៅពេលឃើញអ្នកទោសគេដាក់ខ្នោះនៅឃុំនឹងផ្ទះនោះ តើមានឃើញអ្នកទោសជាស្ត្រី និងកុមារទេ នៅហ្នឹងគុកដាំផេងហ្នឹង?

**ឆ៖** បាទលោក! ពេលហ្នឹង គឺថាខ្ញុំមិនទាន់បានចំណាំបានទាំងអស់ទេ គឺថាពេលដាក់ដំបូងហ្នឹង គឺថានៅថ្មីថ្មោងទេ វាមិនទាន់បានឃើញក្មេង ឬមួយស្ត្រីទេ ឃើញច្រើនតែមនុស្សស្រករៗខ្ញុំហ្នឹង បាទ ។

**ស៖** តើអ្នកទោសឃុំនៅទីនោះ គឺជាទាហានរបស់លោក លន់ នល់ ឬអ្នករដ្ឋការ លន់ នល់ ឬក៏ជាយុទ្ធជនបដិវត្តន៍?

**ឆ៖** បាទ, ពេលហ្នឹង ខ្ញុំអត់បានដឹងដែរ គ្រាន់តែឃើញអ្នកទោសនៅទីនោះ ។

**ស៖** នៅក្នុងអំឡុងពេលលោកនៅទីនោះ មានឃើញគេដឹកអ្នកទោសចូលចំនួនប្រហែលប៉ុន្មានដង? តាមមធ្យោបាយអីដែរ?

**ឆ៖** ខ្ញុំមុនដំបូង គឺថាខ្ញុំអត់ដឹង ដឹងចូលប៉ុន្មានដងៗ ខ្ញុំមកដល់ឃើញអ្នកទោសហ្នឹងនៅតាមផ្ទះហ្នឹងដែរ ។

**ស៖** តើលោកមានដែលឃើញគេដឹកអ្នកទោសហ្នឹង ចេញពីគុក *ប៉េហ្ស៊ី* ទេ នៅពេលលោកយាមនោះ?

**ឆ៖** ឃើញៗដែលគេបណ្តើរអ្នកទោសយកទៅសួរចម្លើយ ប៉ុន្តែ មិនដឹងសួរកន្លែងណា ខ្ញុំអត់បានដឹង។

**ស៖** អ្នកណាគេប្រាប់លោកថា អ្នកនោះត្រូវនាំយកទៅសួរចម្លើយ អ្នកណាគេប្រាប់លោក?

**ឆ៖** ពីព្រោះប្រធានក្រុមខ្ញុំ ស្រ៊ី គឺថា គេឃើញអ្នកសួរចម្លើយយកទៅសួរ ។

[១៤:៣២:៤៩]

**ស៖** យកទៅសួរចម្លើយហ្នឹង តើគេដឹកតាមឡានយកទៅសួរ ឬក៏គេបណ្តើរយកទៅសួរ?

**ឆ៖** ដូច្នេះគេដាក់ខ្នោះដៃថយក្រោយ ហើយគេយកក្រមាឃ្លុំមុខ និងចងមុខ គេបណ្តើរទៅ ។

**ស៖** តើអ្នកទោសហ្នឹងឃើញគេដឹកត្រឡប់មកវិញទេ?

**ឆ៖** ពេលហ្នឹងគេសួរចម្លើយហើយ គេដឹកយកមកវិញ ។

**ស៖** នៅពេលដែលអ្នកទោសគេដឹកមកវិញ តើលោកមានបានពិនិត្យមើលលើដងខ្លួនអ្នកទោសហ្នឹងទេ? តើឃើញមានស្នាមអ្វីនៅលើអ្នកទោសហ្នឹងទេ?

**ឆ៖** បាទលោកពេលហ្នឹង គឺថាអត់ចាំមុខសញ្ញាខ្ញុំទេ គឺថាចំមុខសញ្ញាអ្នកយាមផ្សេង ។

**ស៖** នៅពេលនោះលោកដឹងថា លោក ឌុច មានតួនាទីជាអ្វីទៅ *ប៉េហ្ស៊ី* នៅគុកដាំផេង ហ្នឹង?

**ឆ៖** បាទលោក! ពេលហ្នឹងគឺថាខ្ញុំអត់ដឹងនាទីគាត់ជាអ្វីទេ ប៉ុន្តែឃើញតែគាត់ទៅហ្នឹងទៅមកៗ។

**ស៖** តើមានបានដឹងទេថា ការតែងតាំងលោក ឌុច ជាប្រធានស-២១ ហ្នឹង តើគេតែងតាំងគាត់នៅទីតាំង *ប៉េហ្ស៊ី* ឬក៏តែងតាំងគាត់នៅគុកទួលស្លែងស-២១?

**ឆ៖** ពេលនោះគឺថា គុកកន្លែងដាំផេង គឺថាខ្ញុំអត់បានដឹងដែរ ប៉ុន្តែគ្រាន់ថាមកដល់មន្ទីរស-២១ នេះគឺឃើញគាត់នៅកន្លែងហ្នឹងដែរ ។ មិនដឹងគាត់ជាប្រធាន ឬមួយជាអនុប្រធាន ក៏ខ្ញុំអត់បានដឹងដែរ

ព្រោះអីខ្ញុំមិនសូវទំនាក់ទំនង មិនមែនមិនសូវទេ អត់ទំនាក់ទំនងជាមួយគាត់ផង ម៉េចបានដឹង ។

**ស៖** លោកនៅធ្វើការនៅគុក *ប៉េហ្សុី* ដាំផេង ហ្នឹងមានរយៈពេលប៉ុន្មានដែរ?

**ឆ៖** នៅកន្លែងហ្នឹងលោកអត់បានមួយឆ្នាំទេ ព្រោះខ្ញុំអត់ដឹងខែថ្ងៃអីដែរ ។

**ស៖** តើលោកចាំទេនៅពេលណាគេផ្លាស់ទីតាំងគុកដាំផេងហ្នឹងមកគុកទួលស្លែងស-២១ ហ្នឹង?

**ឆ៖** បាទលោក! ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង តាំងពីឆ្នាំ១៩៧៧ មកដល់៧៨ ថ្ងៃខែខ្ញុំអត់បានដឹងដែរ ។

**ស៖** លោកច្បាស់ឬទេថា ពេលគេផ្លាស់មកគុកទួលស្លែងនេះនៅឆ្នាំ១៩៧៧? មានអ្នកណាគេប្រាប់លោកថានៅឆ្នាំនោះ?

**ឆ៖** ពេលនោះថា ដែលអ្នកនៅអង្គភាពនីរសារជាមួយគ្នាហ្នឹង គេថាយើងផ្លាស់ទៅនៅកន្លែងថ្មីហើយ ។ នៅក្នុងឆ្នាំ១៩៧៧-៧៨ ហ្នឹង គ្រាន់តែបានដឹងតែប៉ុណ្ណឹងទេ ។

[១៤:៣៧:២៥]

**ស៖** លោកមានចាំឈ្មោះនីរសារ ដែលគេប្រាប់លោកនោះទេ?

**ឆ៖** ព្រោះអីខ្ញុំអត់បានចាំដែរ ព្រោះអីនៅក្នុងរយៈពេលហ្នឹង ដូចថាមានប្រធានក្រុមអ៊ីចឹង ដូចស្រ៊ី ដូចបង ហ៊ុយ អ៊ីចឹង គេដឹង គេប្រាប់ថាយើងដូរកន្លែង ប៉ុន្តែមិនដឹងថាដូរទៅកន្លែង ។ ដល់ខ្ញុំមកដល់ឃើញបានដឹងថា កន្លែងហ្នឹង គេថាមន្ទីរស-២១ ទួលស្លែង ។

**ស៖** តើអ្នកទោសទាំងអស់នៅគុកដាំផេងហ្នឹង នៅពេលដែលផ្លាស់ តើគេបញ្ជូនទៅណាដែរអ្នកទោសទាំងអស់នោះ?

**ឆ៖** បាទលោក! ពេលហ្នឹង ខ្ញុំអត់បានដឹងដែរ ។

**ស៖** គណៈដឹកនាំស-២១ ទីតាំងនៅគុកទួលស្លែង លោកមានដឹងថាអ្នកណាខ្លះ គណៈដឹកនាំនោះ?

**ឆ៖** បាទលោក! បើនិយាយតាំងពីដើមមករហូតដល់ត្រឹមប្រធានក្រុម គឺថាខ្ញុំ តាមខ្ញុំសម្គាល់មើលនៅមន្ទីរស-២១ មាន បង ឌុច, បង ហ៊ី, ចាន់, ប៉ុន ដូច ហ៊ុយ, ស្រ៊ី ប្រធានក្រុមអី ដូច អាចំរើន អ៊ីចឹងវាបន្តបន្ទាប់គ្នារហូតមក ។ តាមខ្ញុំសម្គាល់មើលឃើញជាក់ស្តែង ។

**ស៖** ហ៊ុយ ហ្នឹង ហ៊ឹម ហ៊ុយ ឬក៏ នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ?

**ឆ៖** ហ៊ឹម ហ៊ុយ លោក ។

**ស៖** មានដឹងមានតួនាទីរបស់លោក ឌុច នៅពេលនោះគាត់ធ្វើអ្វីខ្លះ នៅ ស-២១ នោះ?

**ឆ៖** បាទលោក ខ្ញុំអត់បានដឹងរឿងគាត់ធ្វើអីដែរ ប៉ុន្តែគ្រាន់តែឃើញគាត់នៅកន្លែងហ្នឹងដែរ ជាអ្នកទទួលខុសត្រូវនៅមន្ទីរ ស-២១ ហ្នឹង ។

**ស៖** ចុះ ហ៊ី គាត់មានភារកិច្ចធ្វើអីដែរនៅស-២១ នោះ?

**ឆ៖** ហ៊ី ដែលគាត់នៅហ្នឹង គឺថាគាត់ដូច ឌុច ដែរ គ្រាន់តែជាមើលការខុសត្រូវនៅក្នុងគុកហ្នឹងដែរ ។

**ស៖** លោកស្គាល់ នុន ហ៊ុយ ទេ?

**ឆ៖** បាទលោក ស្គាល់ ។

**ស៖** គាត់មានតួនាទីធ្វើស្អីនៅ ស-២១ ?

[១៤:៤០:០០]

**ឆ៖** កាលហ្នឹងខ្ញុំស្គាល់ដែរ គាត់នៅទទួលខុសត្រូវខាង ២៤ ខាងព្រៃស ។

**ស៖** តើលោកដឹងថានៅស-២១ ហ្នឹងគេចែកចេញជាប៉ុន្មានអង្គភាព ក្នុងដំណើរការស-២១ហ្នឹង?

**ឆ៖** ក្នុងស-២១ គឺថាខ្ញុំចាំមិនបានអស់ដែរ គឺថាមានផ្នែកខាងកងសួរចម្លើយ មានផ្នែកខាងកងការពារ ផ្នែកខាងរឿងយកអ្នកទោសទៅណាៗ ក៏ខ្ញុំអត់បានដឹង ។

**ស៖** តើផ្នែកខាងសួរចម្លើយហ្នឹង អ្នកណាអ្នកគ្រប់គ្រងផ្នែកខាងហ្នឹង?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ព្រោះអីភារកិច្ចខុសគ្នាអ៊ីចឹង គេអត់ឲ្យទាក់ទងសួរគ្នាផងពេលហ្នឹង ។

**ស៖** តើលោកត្រូវគេឲ្យនៅក្នុងអង្គភាពណានៅពេលដែលគេធ្វើ-- នៅពេលដែលមន្ទីរស-២១ នោះផ្លាស់ទៅទួលស្លែង?

**ឆ៖** បាទលោក! ខ្ញុំគេឲ្យខ្ញុំនៅខាងផ្នែកយាមអ្នកទោសខាងក្រៅអគារតាមផ្ទះថ្ម កន្លែងហ្នឹងគេហៅថា គុកពិសេសរបស់ស-២១ ។

**ស៖** ក្នុងក្រុមណា? ហើយប្រធានក្រុមរបស់លោកឈ្មោះអី? ហើយក្នុងក្រុមរបស់លោកមានគ្នាប៉ុន្មាននាក់ដែរ?

**ឆ៖** តាមខ្ញុំដឹង គឺថាមានតែជាងពីរក្រុមទេកន្លែងហ្នឹង គឺប្រធានកងហ្នឹងមាន បងហ៊ុយ, ស្រ៊ុមកប្រធានក្រុមហ្នឹង គឺថាមាន ចំរើន ប៉ុន្តែក្រៅពីហ្នឹង ខ្ញុំភ្លេចហើយ យូរដែរហើយ ។

**ស៖** ក្នុងក្រុមរបស់លោកហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ?

**ឆ៖** ទាំងអស់ គឺថាមានជាងម្ភៃនាក់ ដែលការពារអ្នកទោសកន្លែងហ្នឹង ដូរគ្នាទៅវិញទៅមក ។

**ស៖** ក្នុងចំណោមម្ភៃនាក់ហ្នឹង តើលោកមានចាំឈ្មោះអ្នកណា ដែលជិតស្និត ដែលលោកអាចចាំឈ្មោះបានហ្នឹង? មានស្គាល់ នៅចាំបានទេ?

**ឆ៖** បាទ, លោក ពេលដែលខ្ញុំនៅដែលជិតស្និតជាមួយនឹង គឺថាដូច ហ៊ុយ, ស្រ៊ី, ចំរើន, បងថន ហើយនិង ទ្រា តែប៉ុណ្ណឹងទេ ដែលអាចនៅចាំ ។

**ស៖** តើក្រុមរបស់ហ្នឹង គេឲ្យសម្រាកនៅកន្លែងណា?

**ឆ៖** បាទ, កន្លែងសម្រាកហ្នឹង គឺថានៅក្នុងរបងគុកដែរ ប៉ុន្តែនៅជិតដែលដាក់អ្នកទោសដែរ គ្រាន់តែផ្ទះរំលងគ្នាមួយទេ ។

**ស៖** តើរោងបាយរួមរបស់ ស-២១ មានប៉ុន្មានកន្លែង? ហើយនៅកន្លែងណាខ្លះ?

**ឆ៖** បាទ, លោក តាមខ្ញុំដឹង គឺថាមានតែមួយកន្លែងទេ នៅកន្លែងជិតកន្លែងឡានទឹក ។

**ស៖**ពេលហូបបាយម្តងៗអ្នកទាំងអស់គ្នាហូបរួមជុំគ្នាតែមួយពេលនៅទីនោះ ឬក៏មានបែងចែកជាវេនគ្នា?

**ឆ៖** បាទ,លោក! ពេលហ្នឹង គឺថាមិនបានជុំគ្នាទាំងអស់ទេ គឺថាពេលដែលគេដូរខ្ញុំយាមទៅ ខ្ញុំមកហូបបាយទៅ ។ ពេលដែលខ្ញុំដូរគេយាមទៅ គឺគេមកហូបបាយ ។ ដូរគ្នាទៅវិញទៅមកទេពេលហ្នឹង ។

**ស៖** ពេលវេនលោកទៅហូបបាយហ្នឹង លោកឃើញមានមនុស្សដែលទៅហូបបាយហ្នឹង មានប៉ុន្មាននាក់ដែរ? ប្រហែលចំនួនប៉ុន្មាន?

**ឆ៖** បាទ, លោក ពេលដែលទៅហូបបាយ គឺថាដូចតែពេលពួកខ្ញុំ ក្រុមខ្ញុំទៅហ្នឹង គឺថាមានតែចំនួនតែម្ភៃនាក់ទេ ឬមួយ១៥នាក់ តែប៉ុណ្ណឹងទេ ។ ខាងគេផ្សេងមិនដឹងគេ គេមានពេលគេហូប ។

**ស៖** លោកប្រាកដច្បាស់ទេថា ស-២១ មានផ្ទះបាយរួមតែមួយ មិនមានពីរ? លោកដឹងពីចំនួននេះយ៉ាងដូចម្តេច? តាមរយៈអ្នកណា? ឬក៏លោកអង្កេតផ្ទាល់ខ្លួន?

**ឆ៖** បាទ, លោក! ជាក់ស្តែង គឺថា ខ្ញុំទៅផ្ទាល់តែម្តង ។

**ស៖** តើអ្នកយាមខាងក្រៅ គេហូបបាយរោងបាយផ្សេង ឬក៏មកហូបនៅទីហ្នឹងដែរ?

**ឆ៖** គឺដែលហូបហ្នឹង គឺហូបជាមួយគ្នាទេ តែរោងបាយមួយហ្នឹងទេ ។ ត្រង់មានផ្សេងទៀត ខ្ញុំអត់បានដឹងដែរពេលហ្នឹង ។

**ស៖** របបហូបចុករបស់បុគ្គលិកស-២១ នោះ មួយថ្ងៃគេឲ្យប៉ុន្មានពេល? បបរ ឬបាយ?

**ឆ៖** បាទ, លោក! ពេលហ្នឹង អត់ទៀងទេ ។ ចួនកាលបីពេល ចួនកាលពីរពេល ។ បបរព្រឹក បាយថ្ងៃ បាយល្ងាច ។

**ស៖** គ្រប់គ្រាន់ឬទេ ឬក៏ខ្វះខាត?

**ឆ៖** គឺពេលដែលហូបហ្នឹង គឺថាក៏អត់ទៀងដែរ ចួនកាលហ្នឹង វាមានការវាលើបាយដែរ ។ ចួនកាលមួយចានម្នាក់អ៊ីចឹងទៅ គឺថាពាក្យដែលថា សន្សំសំចៃ ។

សូមអស់ ។

**ស៖** រោងបាយរួមហ្នឹង បើសិនជាមនុស្សចូលទាំងអស់គ្នាតែមួយពេល ប្រហែលដាក់មនុស្សបានប៉ុន្មាននាក់ទៅ?

[១៤:៤៩:០៧]

**ឆ៖** តាមខ្ញុំស្មាន គឺថាបានតែចំនួនហាសិបនាក់ទេ ។

**ស៖** តើលោកដែលឃើញជនជាប់ចោទ គាត់ទៅហូបបាយនៅរោងបាយរួមនោះទេ?

**ឆ៖** បាទ, លោក! អត់ដែលឃើញទេ ។

**ស៖** លោកដឹងទីតាំងស-២១ នេះច្បាស់ តើអគារទាំងអស់ហ្នឹង មានប៉ុន្មានអគារ?

**ឆ៖** បាទ, លោក! ពីមុនគឺថាខ្ញុំអត់បានដែលចូលទៅក្នុងអគារហ្នឹងទេ ដល់ចុងក្រោយទេ ខ្ញុំបានចូលទៅខ្ញុំដឹងឃើញតែអគារបួនល្វែង ។

**ស៖** តើគុកពិសេសហ្នឹង វាស្ថិតនៅត្រង់ណា? នៅខាងណា នៃអគារទាំងបួននោះ?

**ឆ៖** បាទ,លោក! គុកពិសេសហ្នឹងគឺថានៅខាងត្បូងអគារ បណ្ដោយផ្លូវខាងលិចកើត ។ នៅក្នុងរបងទីមួយ ។ សូមអស់ ។

**ស៖** តើគុកពិសេសធ្វើអំពីអី? ធ្វើពីថ្មះថ្ម? ធ្វើពីឈើ? ហើយទំហំប៉ុនណា? ហើយវាមានប៉ុន្មានជាន់ទៅ?

**ឆ៖** បាទ, លោក! កន្លែងគុកពិសេសហ្នឹង គឺថាអត់ទៀងទេ ។ វាមានផ្ទះឈើផង ផ្ទះថ្មផង ហើយនិងផ្ទះទាមផង ។ កន្លែងខ្លះមានមួយជាន់ កន្លែងខ្លះពីរជាន់ កន្លែងខ្លះមានបីជាន់ ។ អ៊ីចឹង កន្លែងហ្នឹង អត់ទៀងទេ ។ បើកន្លែងហ្នឹង ឥឡូវហ្នឹងខ្ញុំក៏ប្លែកដែរ អត់ដែរបានទៅផង មិនដឹងគេរើរុះទៅណាអីមកណាក៏ខ្ញុំអត់បានដឹងដែរឥឡូវហ្នឹង ។ សូមអស់ ។

**ស៖** តើគុកពិសេសហ្នឹងមានប៉ុន្មានផ្ទះ?

**ឆ៖** បាទ,លោក! តាមខ្ញុំចាំ គឺថា បួនផ្ទះ ។ មានផ្ទះឈើមួយ ផ្ទះថ្មបីជាន់ហ្នឹងមួយ និងផ្ទះទាមនៅជិតផ្ទះឈើហ្នឹងមួយ ហើយមានបន្ទប់ជាប់ៗគ្នាខ្លះទៀត ។

**ស៖** ក្នុងផ្ទះនីមួយៗហ្នឹង មានប៉ុន្មានបន្ទប់ដែរ?

**ឆ៖** ពេលហ្នឹងខ្ញុំចាំមិនបានអស់ទេ ។ ដូចផ្ទះថ្មជាន់ទីបីហ្នឹង វាមានមួយជាន់នោះ វាមានពីរបន្ទប់ ។ ពីរជាន់វាមានបីបន្ទប់ មួយជាន់នោះវាមានមួយបន្ទប់ ។ អាហ្នឹងតាមខ្ញុំចំណាំ ផ្ទះថ្មដែលបីជាន់ហ្នឹង ។ ក្រៅពីហ្នឹង ខ្ញុំក៏អត់បានចាំអស់ដែរទេ ។

**ស៖** តើលោកអាចស្មានបានទេ បន្ទប់នីមួយៗហ្នឹង មានទំហំប្រហែលប៉ុនណាដែរ?

[១៤:៥៣:១៨]

**ឆ៖** តាមខ្ញុំស្មាន គឺថាមានតែបីម៉ែត្របួនជ្រុងទេ មួយបន្ទប់ ។

**ស៖** តើពេលនោះ អ្នកទោសមាននៅគ្រប់បន្ទប់ដែលលោកបានបញ្ជាក់អ៊ីចឹងមែនទេ?

**ឆ៖** បាទ,លោក! គឺថាបន្ទប់អ្នកទោស គឺថាអត់ទៀងទេ ។ ចួនកាលគ្រប់ទៅ ចួនកាលខ្វះទៅក៏មានដែរ ។

**ស៖** គុកពិសេសហ្នឹងសម្រាប់ដាក់អ្នកណាគេ? អ្នកទោសឋានៈរបៀបណា? កម្រិតណា?

**ឆ៖** បាទ, តាមខ្ញុំស្មានមើលគឺថា ប្រភេទសុទ្ធតែកម្មាភិបាលធំៗ ។ វរសេនាតូច វរសេនាធំ កងពល ឬគណៈតំបន់ ភូមិភាគ ។ នេះតាមខ្ញុំស្មានមើលឃើញទេ ។ សូមអស់ ។

**ស៖** តើកាលលោកស្មាន លោកផ្អែកលើមូលដ្ឋានអ្វីដែលលោកគិតថា អ្នកនោះជាមនុស្សសំខាន់ដែលគេយកមកដាក់ឃុំនៅទីនោះ?

**ឆ៖** តាមខ្ញុំយល់គឺថា គឺអ្នកទោសសំខាន់ៗគឺគេមិនអាចដាក់ជាប់គ្នាទេ គឺគេដាក់បន្ទប់មួយម្តងៗ ក្នុងមួយបន្ទប់អ្នកទោសម្នាក់ មួយបន្ទប់អ្នកទោសម្នាក់ ។ អ៊ីចឹង គឺថាអ្នកយាមក៏ម្នាក់ដែរ ។ អត់មានអ្នកទោសហ្នឹង បីនាក់យាមម្នាក់ អត់មានទេ ។ បាទ, តាមខ្ញុំសម្គាល់អ៊ីចឹងទេ ។ សូមអស់ ។

**ស៖** លើផ្អែកលើរូបរាងអ្នកទោសនោះ តើអ្នកទោសដែលគេយកមកឃុំហ្នឹងមានសាច់ មានឈាម ឬក៏ស្គមស្គាំង នៅពេលដែលយកមកឃុំដំបូង?

**ឆ៖** បាទ, លោក! ពេលដែលគេយកអ្នកទោសមកឃុំឃាំងហ្នឹង គឺថា គឺច្រើនតែអ្នកធាត់ ហើយសម្បុរហ្នឹងក៏ បើតាមខ្ញុំពិនិត្យ ខ្ញុំមើល សក៏មាន ខ្មៅក៏មាន មាឌដំបងក៏មាន ។ នេះគ្រាន់ខ្ញុំស្មានមើល

ឃើញទេ រឿងឲ្យខ្ញុំស្គាល់ឈ្មោះអ្នកទោស គឺថាគេមិនឲ្យខ្ញុំស្គាល់ទេ ។ សូម្បីនិយាយជាមួយអ្នកទោស គេអត់ឲ្យខ្ញុំនិយាយផង ។ សូមអស់យោបល់ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីដប់ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការនីតិវិធីសវនាការ ។

មន្ត្រីតុលាការក្នុងរយៈពេលនៃការសម្រាក សូមលោករៀបចំរកកន្លែងសម្រាកសមរម្យដល់សាក្សីរូបនេះ ហើយឲ្យអញ្ជើញគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងបីដប់ប្រាំនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៤:៥៨នាទី ដល់ម៉ោង ១៥:១៧នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាស់បន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តនេះប្រគល់ភារៈជូនទៅលោកចៅក្រម យ៉ា សុខន ដើម្បីបន្តតាំងសំណួរដល់សាក្សីរូបនេះ ។ សូមអញ្ជើញលោកចៅក្រម ។ ឈប់ៗ ។

**សួរដោយចៅក្រម យ៉ា សុខន៖**

សូមអរគុណលោកប្រធាន ។

**ស៖** តើលោកត្រូវគេឲ្យយាមនៅកន្លែងណា? នៅគុកពិសេសនោះ?

**ឆ៖** បាទលោក ពេលហ្នឹងអត់ទៀងទេ ចួនកាលនៅផ្ទះថ្មពីរជាន់ ចួនកាលផ្ទះឈើ ។ អ៊ីចឹងគឺថាកន្លែងយើងអត់ទៀងទេ ។ អរគុណ ។

**ស៖** លោកត្រូវគេឲ្យយាមដើរ ឬយាមនៅមួយកន្លែង?

**ឆ៖** បាទ លោក គឺថា ពេលយាមហ្នឹងគឺថាគេអត់ឲ្យដើរទេ គេឲ្យឈរមួយកន្លែង ។ អង្គុយគេអត់ឲ្យអង្គុយទេ ពីព្រោះអង្គុយទៅខ្លាចងក់ងុយទៅនាំតែពិបាកដល់អ្នកទោសធ្វើសកម្មភាព។ សូមអស់។

**ស៖** យាមនៅក្នុងបន្ទប់ឃុំអ្នកទោស ឬក៏យាមនៅមាត់ទ្វារបន្ទប់ឃុំអ្នកទោស?

**ឆ៖** បាទ, លោកគឺទៅយាមនៅក្នុងមាត់ទ្វារអ្នកទោស បន្ទប់ ។

**ស៖** ពេលយាមនោះ គេឲ្យលោកកាន់អាវុធដែរឬទេ?

**ឆ៖** ពេលនោះ គឺថាអត់មានទេ ។

**ស៖** លោកដឹងឬទេថា តើក្រុមណាជាអ្នកបណ្តើរអ្នកទោសមកឃុំនៅតាមបន្ទប់នោះ?

**ឆ៖** បាទ, គឺថាពេលនោះ គឺថាមានដូច ស្រ៊ី អ៊ីចឹង ចួនកាល ហ៊ុយ អ៊ីចឹង អត់ទៀងទេ ។ ប៉ុន្តែសំខាន់អ្នកទទួលខុសត្រូវនៅកន្លែងក្នុងក្រុមហ្នឹង ដូច ហ៊ុយ ដូច ស្រ៊ី អ៊ីចឹង ។ សូមអស់ ។

**ស៖** នៅពេលគេបណ្តើរអ្នកទោសមកឃុំ តើលោកសង្កេតឃើញអ្នកទោសមានសភាពដូចម្តេច? ហើយអ្នកបណ្តើរអ្នកទោសមកហ្នឹងមានចំនួនប៉ុន្មាននាក់អមជាមួយអ្នកទោសនោះ?

[១៥:២០:២៨]

**ឆ៖** បាទ,លោក! ពេលគឺថាគេបណ្តើរអ្នកទោសមកហើយ គឺថាអ្នកទោសហ្នឹងអត់មានខោជើងវែងទេ អាវទេ មានតែខោខ្លី ។ ខ្នោះដាក់ដៃថយក្រោយ យកកំណាត់ចងមុខ ឃ្លុំក្រមា ដើរចូល ។ គឺថាចួនកាលមានដូច បងហ៊ី អ៊ីក្តី គឺថាគាត់ដើរមកតាមក្រោយ ។ សូមអស់ ។

**ស៖** នៅពេលដែលគេយកអ្នកទោសមកឃុំក្នុងបន្ទប់ តើគេមានដាក់ខ្នោះអ្នកទោសឬទេ?ហើយការដាក់ខ្នោះរបៀបដូចម្តេចចំពោះអ្នកទោសមកថ្មី និងអ្នកនៅចាស់?

**ឆ៖** បាទ, គឺថាពេលដែលគេយកអ្នកទោសមកដាក់ខ្នោះហ្នឹង គឺថាគេដាក់ខ្នោះជើងហើយ គឺថាដាក់ទាំងពីរ គេដោះខ្នោះដៃចេញ ។

**ស៖** តើគេមានបានគិតថាអ្នកទោសមកថ្មី គេដាក់ខ្នោះរបៀបម៉េច? ហើយអ្នកទោសដែលនៅចាស់ហ្នឹង គេដាក់ខ្នោះរបៀបម៉េចទេ?

**ឆ៖** បាទ, លោក! គឺថាពេលហ្នឹងគេថាក្នុងពេលដែលដូចអ្នកទទួលខុសត្រូវ ដូចបងហ៊ុយ ដូច ស្រ៊ី ហ្នឹង គេមើលសកម្មភាពអ្នកទោសដែរ បើអ្នកទោសណាស្លូតទៅ គេថាដាក់តែខ្នោះជើងទេ ដៃអត់ដាក់ទេ បើអ្នកទោសណាដែរ គឺថាខ្លាំងទៅ គឺថាគេដាក់ខ្នោះដៃដែរ ។ អាហ្នឹងអត់ទៀងទេ បើថាអ្នកទោសចាស់ គឺថាដឹងតែដាក់តែខ្នោះជើងទេ ។

**ស៖** តើខ្នោះហ្នឹងមានភ្ជាប់ទៅទីកន្លែងណា ចុងខ្នោះ?

**ឆ៖** បាទ,លោក! ពេលដែលគេដាក់ខ្នោះជើងហ្នឹង គឺថាមានកងហ្នឹងពីរ ហើយដែកថ្នាំងអំពៅហ្នឹងប្រហែលជាប្រាំពីរប្រាំបីតឹកហ្នឹង ហើយគេស៊កដាក់ ចួនកាលគេចងនៅជាប់ហ្នឹងមាត់បង្អួច ។

**ស៖** លោកមានបានពិនិត្យមើលទេ នៅក្នុងបន្ទប់ឃុំអ្នកទោសមានសំភារៈអ្វីខ្លះ? ហើយគេសម្រាប់ធ្វើអ្វី?

**ឆ៖** បាទ, លោក! គឺថាក្នុងបន្ទប់អ្នកទោស គឺថាគ្មានអ្វីហួសពីខ្នោះហ្នឹងទេ ហើយនឹងមានដូចជាមុង-- អំ!មុងដូចជាអត់មានទេ មានតែកន្ទេល ហើយនិងខ្នើយចាស់អីហ្នឹងមួយហ្នឹង មានកន្ថោរមានអីហ្នឹងគ្រាន់ដាក់ឲ្យអ្នកទោសហ្នឹង បត់ដៃបត់ជើងអីហ្នឹង គឺសម្ភារដែលធ្វើទារុណកម្ម គឺថាអត់មានទេ ។

**ស៖** តើលោកត្រូវគេឲ្យយាមប៉ុន្មានបន្ទប់ក្នុងគុកពិសេសហ្នឹង?

**ឆ៖** បាទ, លោក! ដូចខ្ញុំជម្រាបខាងលើកអីចឹង គឺក្នុងអ្នកទោសម្នាក់ដាក់មួយបន្ទប់ អ្នកយាមមួយ ។

**ស៖** តើលោកមានភារកិច្ចធ្វើអ្វីនៅក្នុងបន្ទប់ឃុំអ្នកទោសនោះ?

**ឆ៖** បាទ, លោក! គឺថាភារកិច្ចខ្ញុំគ្មានអីហួសពីយាមអ្នកទោសទេ ។

**ស៖** ចុះការជញ្ជូនសំណល់ចេញពីបន្ទប់ តើជាភារកិច្ចរបស់អ្នកណា?

**ឆ៖** គឺដែលជញ្ជូនអ្នកទោសចេញហ្នឹង គឺថាភារកិច្ចហ្នឹង ភារកិច្ចទៅលើ ហ៊ុយ ហើយ ស្រ៊ុ ដែលគេអ្នកទទួលខុសត្រូវកន្លែងហ្នឹង ។ ដូចខ្ញុំ ខ្ញុំអត់មានភារកិច្ចអីត្រូវទៅចាក់សោចេញចូលអីអត់មានទេ ។ សូមអស់ ។

**ស៖** តុលាការចង់សួរថា អ្នកមានភារកិច្ចជញ្ជូនសំណល់ៗដែលអ្នកទោសបន្ទោបង់នៅក្នុងបន្ទប់ តើអ្នកណាជាអ្នកមានភារកិច្ចជញ្ជូនចេញ?

**ឆ៖** បាទ, លោក! ពេលហ្នឹងគឺថា ដូចខ្ញុំជម្រាបថាមានតែ ហ៊ុយ ហើយនិង ស្រ៊ុ ទេ ដែលគេអ្នកទទួលខុសត្រូវអាហ្នឹង ។

**ស៖** បន្ទប់ឃុំអ្នកទោសមានចាក់សោទេ?

**ឆ៖** បាទ, ចាក់ ។

**ស៖** បើបន្ទប់នោះចាក់សោលោកអាចមើលឃើញអ្នកទោសខាងក្នុងមានធ្វើសកម្មភាពអ្វីឃើញទេ?

**ឆ៖** បាទ លោក ខ្ញុំសូមទោសពេលកន្លែងនេះខ្ញុំអត់សួរយល់ ។ ដូច្នេះ ថាពេលដែលខ្ញុំនិយាយអំមិញហ្នឹង មានការជ្រុលជ្រួសបន្តិចហើយ គឺថាខាងក្រៅអត់មានចាក់សោទេ គឺថាអ្នកយាម គឺថា

យាមខាងក្រៅ នៅមាត់ទ្វារហ្នឹង ។

**ស៖** តើអ្នកទោសគេតម្រូវឱ្យតែដេក ឬបើចង់អង្គុយ ឈរ ត្រូវសុំអ្នកយាមមែនទេ?

**ឆ៖** បាទ, លោកត្រឹមត្រូវមែន ។

**ស៖** តើរបបហូបចុកសម្រាប់អ្នកទោសសំខាន់ គេផ្តល់ឱ្យដូចម្តេច? ប៉ុន្មានពេលក្នុងមួយថ្ងៃ? បាយ ឬបបរ? មានសម្លទេ?

**ឆ៖** បាទ, លោក! គឺថាពេលដែលអ្នកទោសនៅទីនោះ គឺថាបាយមានតែពីរពេលទេ ព្រឹក និងល្ងាច ។ គឺថាបាយមួយចាន សម្លមួយចាន ។ សម្លហ្នឹងគឺថាអត់មានត្រីទេ មានតែបន្លែដូចជាត្រកួន ព្រលឹតអីចឹង ។ គឺថាគ្រប់គ្រាន់ មិនបានគ្រប់គ្រាន់ទេ ។ សូមអស់ ។

[១៥:២៧:៣១]

**ស៖** តើចំនួនប៉ុន្មានថ្ងៃ គេឱ្យអ្នកទោសងូតទឹកម្តង? ហើយការងូតទឹក មុជរបៀបម៉េចដែរ? គេផ្តល់ដូចម្តេច? ហើយមានសម្លៀកបំពាក់ផ្លាស់ឱ្យទេ?

**ឆ៖** បាទ, លោក! គឺថាពេលដែលអ្នកទោសត្រូវទៅងូតទឹកនោះ គឺថាអត់ទៀងទេ ។ ចួនកាលបីថ្ងៃ ចួនកាលមួយអាទិត្យអីចឹងទៅ ។ ពេលដែលសម្លៀកបំពាក់ហ្នឹង គឺថាអត់មានអីត្រូវផ្លាស់ទេ គឺថាស្រាតខោហ្នឹងយកទៅដាក់គងលើខ្នោះ ហើយដូចថាអ្នកយាមហ្នឹងដួសទឹកមួយធុងទៅ ផ្តិលមួយទៅឱ្យងូតធម្មតា ។ ងូតហើយ ទើបនឹងស្លៀកខោវិញ អត់មានចាក់ខ្នោះអីយកទៅងូតទឹកតាមអំពើចិត្តអ្នកយាមទេ អត់មានទេ ។ សូមអស់ ។

**ស៖** បើអ្នកទោសចង់បន្ទោបង់ គេឱ្យបន្ទោបង់របៀបម៉េចទៅ?

**ឆ៖** បាទ, លោក! អត់យល់បាទ ។

**ស៖** ពេលអ្នកទោសចង់បន្ទោបង់ បត់ជើងបត់ដៃ តើគេឱ្យបត់ជើងបត់ដៃនៅកន្លែងណា?

**ឆ៖** បាទ, លោក! គឺថាអ្នកទោសត្រូវតែបត់ដៃបត់ជើង គឺថាបត់នៅកន្លែងហ្នឹងដដែល គឺថាដូចថាអ្នកយាមហ្នឹងមានកន្ត្ថោរស្រក្បូរ គឺថាអ្នកទោសចង់បត់ដៃបត់ជើង គឺសុំទៅអ្នកយាមហ្នឹង ឱ្យកន្តោរបត់ជើងទៅ ហើយបត់ហ្នឹងធម្មតាដូចងូតទឹកអីដែរ ដូចតែគ្នា ។

**ស៖** តើគេសួរចម្លើយអ្នកទោសសំខាន់នៅកន្លែងណា?

**ឆ៖** គឺថាអ្នកទោសដែលគេយកសួរចម្លើយហ្នឹង គឺថាអត់ទៀងទេ សំខាន់គេយកចេញទៅក្រៅបើខាងក្នុងគឺថាគេអត់សួរទេ ។ មូលហេតុដែលគេមិនសួរដោយសារអ្នកទោសដាក់ជាប់គ្នា ។ ដល់

អ៊ីចឹងគេអត់សួរទេ អ៊ីចឹងគេរំលែកអ្នកទោសម្នាក់អ៊ីចឹង គេយកទៅសួរខាងក្រៅទេ ។

[១៥:៣០:១៥]

**ស៖** តាមការបញ្ជាក់ចម្លើយរបស់លោកនៅសហចៅក្រមស៊ើបសួរ លោកបានបញ្ជាក់ថា មានពេលដែលគេសួរចម្លើយអ្នកទោសនោះនៅក្នុងបន្ទប់ឃុំតែម្តង មានពេលខ្លះតែប៉ុណ្ណោះដែលយកអ្នកទោសនោះទៅសួរនៅខាងក្រៅ តើដូច្នេះមែនទេ?

**ឆ៖** បាទ, លោក! ពិត ។

**ស៖** អ៊ីចឹងមានការសួរយកចម្លើយអ្នកទោស មានសួរនៅក្នុងបន្ទប់ឃុំឃាំងផ្ទាល់អ្នកទោសតែម្តងមែនទេ?

**ឆ៖** មែនលោក ។

**ស៖** តើលោកដឹងថា ក្រុមណាជាអ្នកសួរចម្លើយអ្នកទោសសំខាន់នោះ មានប៉ុន្មាននាក់? លោកចាំឈ្មោះបានទេ?

**ឆ៖** បាទ,លោក! តាមដែលខ្ញុំចាំនៅក្នុងពិសេសនោះ គឺថាមានតែឈ្មោះ ទុយ, ទិត, អាណាន, អាឈិន, អាអុន គឺថាគេអ្នកសួរនៅកន្លែងពិសេសហ្នឹងហើយ ច្រើនគេមកដឹកយកចេញយកទៅសួរខាងក្រៅ ។

**ស៖** ចុះអ្នកណាអ្នកសួរអ្នកទោសនៅក្នុងបន្ទប់ឃុំអ្នកទោសតែម្តងហ្នឹង?

**ឆ៖** បាទ, លោក! ទុយ ។

**ស៖** នៅពេលដែលអ្នកសួរចម្លើយចូលសួរអ្នកទោសនៅក្នុងបន្ទប់ឃុំឃាំង នៅពេលនោះគឺលោកគេឱ្យយាមនៅត្រង់ណា?

**ឆ៖** បាទ,លោក! គឺថាថ្ងៃមួយ គឺថាវាមានចន្លោះ គឺថាគេដកអ្នកទោសម្នាក់ចេញទៅ គឺថាមានចន្លោះកន្លែងហ្នឹង គឺថាមានតែ ទុយ ឡើងមកដល់គេចូលក្នុងបន្ទប់អ្នកទោស គឺគេបិទទ្វារជិត គេឱ្យខ្ញុំចេញមកខាងក្រៅ ។ ដូច្នេះ ខ្ញុំលួចមើលឃើញតាមបង្អួច ឃើញ ទុយ កំពុងតែសួរអ្នកទោស ថាម៉េចយើងឆ្លើយមិនឆ្លើយ និយាយមិននិយាយ និយាយឱ្យអស់មើល រាយការណ៍ជូនបក្សឱ្យអស់ទៅ លាក់អីទៀត ។ ដល់អ៊ីចឹងទៅ អ្នកទោសក៏ឆ្លើយថា ខ្ញុំរាយការណ៍ជូនបក្ស ជូនអង្គការអស់ហើយ ហើយ បងនៅធ្វើទារុណកម្មខ្ញុំទៀត ខ្ញុំមិនដឹងមានពាក្យអីឆ្លើយទៀតទេ។ ដូច្នេះ អាទុយ ក៏វានឹកឃើញថា អ្នកទោសឆ្លើយអ៊ីចឹងមក អាទុយ ទាញរំពាត់ផ្តៅវាយអ្នកទោស ខ្វិច ខ្វាច់ ៗ គឺថា ខ្នងអ្នកទោសហ្នឹង ខ្ញុំលួច

មើលឃើញថា បែបឈាមហូររហាម ។ បានមួយសន្ទុះ ទុយ ហ្នឹងក៏គេទាញអាដែងក្ដគោមកប្រហែលប្រវែងបីតឹកនេះ ជាកៅស៊ូទេ ប៉ុនកដៃវាយអ្នកទោសទៀតទៅ ខ្មៀកយក១ អ្នកទោសក៏ ស្រែកក៏ស្រែកមិនរួចទេ គឺថាអួលដើមកទាំងអស់ ។ បានមួយសន្ទុះ ទុយ ទាញខ្សែភ្លើងមកទៀត យកខ្សែភ្លើងមកចងមេជើងអ្នកទោស ហើយយកឫស្សីមួយកំណាត់ប្រហែលជាមួយម៉ែត្រជាងហ្នឹង គេយកតជាមួយខ្សែភ្លើងយករុកត្រចៀកអ្នកទោស ។ ដូច្នេះ អ្នកទោសហ្នឹង គឺថាដួលសន្លប់នៅនឹងឥដ្ឋហ្នឹងទៅ ។ ប្រហែលប្រាំនាទី អ្នកទោសក្រឡើងពេក ទុយ ក៏ស្រាយខ្សែភ្លើងចេញអ្នកទោស ដើរចុះ ដើរឡើងក្នុងបន្ទប់ហ្នឹងដល់អ្នកទោសបានប្រហែលជាដប់នាទីទៀត អ្នកទោសដឹងខ្លួន ទុយ ក្រឫចសក់ក្បាលឡើងអង្គុយប្រាប់អ្នកទោសថា នឹកឲ្យឃើញ ចាំឲ្យបាន ស្អែកចាំជួបគ្នាទៀត ។ នេះតាមខ្ញុំដឹងការពិតរបស់ខ្ញុំ ។ ដូច្នេះ អាទុយ ចេញមកហើយ ប្រាប់ខ្ញុំថា មិត្តឯងការពារខ្មាំង ប្រយ័ត្នខ្មាំងធ្វើសកម្មភាពងាប់ មិត្តឯងទទួលខុសត្រូវ ចាប់មិត្តឯងដាក់គុកហើយ ។ ដូច្នេះ អាទុយ ក៏ចុះទៅៗ ដល់ម៉ោង១១ បានអ្នកយាមគេឡើងមកដូរខ្ញុំឲ្យទៅហូបបាយ ។ មកដល់គេឆែកអ្នកទោស រលាស់ ពិនិត្យមើលសោ ខ្នាចក្រែងលោសោហ្នឹងរបើក ពិនិត្យមើលកន្លែងអ្នកទោសខ្លាចក្រែងលោមានដែកគោល ឬមួយម្ជុលអីទៅ អ្នកទោសហ្នឹង លេបទៅងាប់ទៅ គឺថាដើម្បីបំបិទភស្តុតាងហ្នឹង ។ ដល់គេពិនិត្យហើយទៅ គេថាបាន ហើយខ្ញុំក៏ចុះទៅហូបបាយ ។ ដល់ខ្ញុំហូបបាយហើយ ខ្ញុំវិលត្រឡប់មកវិញ ខ្ញុំទទួលឃើញបង ឌុច កំពុងតែសួរអ្នកទោសនៅកន្លែងផ្ទះថ្មតៀមជិតផ្ទះឈើហ្នឹង ។ ឃើញកាន់រំពាត់ផ្ដៅហ្នឹង ហើយអ្នកយាមហ្នឹង យាមមាត់ច្រកខ្លោងទ្វារ ។ រឿងនេះខ្ញុំឃើញហើយ បានខ្ញុំថា បើថាមិនឃើញ ខ្ញុំអត់ថាទេ ។ សូមអស់យោបល់ ។

**ស៖** លោកឃើញលោក ឌុច ហ្នឹងវាយទៅលើអ្នកទោសត្រង់កន្លែងណាខ្លះ?

**ឆ៖** គឺថាមានតែរំពាត់ផ្ដៅទេ វាយហ្នឹងក៏មិនវាយប៉ុន្មានដែរទេ ហើយបានខ្ញុំដើរមកសម្រាកកន្លែងខ្ញុំមក ។

**ស៖** លោកឃើញ ប៉ុន្តែលោកឃើញថាវាយត្រង់កន្លែងណាខ្លះលើអ្នកទោសហ្នឹង?

**ឆ៖** វាយហ្នឹង វាយខ្នងនេះលោក ។

**ស៖** លោកបានបញ្ជាក់អម្បាញ់មិញថា ទុយ ចូលទៅសួរចម្លើយអ្នកទោសនៅកន្លែងឃុំ ហើយវាយអ្នកទោស អ៊ីចឹងបានសេចក្តីថា នៅពេលដែល ទុយ ចូលទៅបន្ទប់ឃុំអ្នកទោសនោះយកឧបករណ៍សម្រាប់ធ្វើអំពើហិង្សាទៅជាមួយតែម្ដង ឬក៏នៅក្នុងបន្ទប់នោះមានប្រចាំនៅទីនោះហើយ?

[១៥:៣៧:២៧]

**ឆ៖** បាទ,លោក! ពេលហ្នឹងគឺថា អត់មានឧបករណ៍នៅក្នុងកន្លែងអ្នកយាមទេ គឺថាឧបករណ៍ហ្នឹង ទុយកាន់មកតែម្តង ។

**ស៖** អំពើហិង្សាលើអ្នកទោសក្រៅពីវាយ និងឆក់ លោកមានដែលឃើញគេប្រើអំពើហឹង្សាក្រៅពីនោះទៀតទេដូចជា យកស្បោងច្រក យកក្បាលច្រកស្បោងកៅស៊ូ សម្រក់ទឹកចូលក្នុងច្រមុះ ដកក្រចក ចាក់ក្រចក ហើយជ្រមុជអ្នកទោសទៅក្នុងធុងទឹកឲ្យឈ្លក់ តើមានឃើញរបៀបអំពើហិង្សា បែបនេះទេ?

**ឆ៖** បាទ, លោក! គឺថាពេលនុ៎ង ខ្ញុំអត់បានឃើញទេ ។ ព្រោះអីគេយកទៅសួរខាងក្រៅ ខ្ញុំអត់បានទៅពិនិត្យមើលទេ ។ សូមអស់ ។

**ស៖** ត្រឡប់ទៅក្រោយវិញបន្តិច លោកបានឃើញផ្ទាល់ទេ ថាអ្នកទោសដែលលោក ឌុច គាត់វាយទៅលើនោះ តើអ្នកទោសនោះភេទស្រី ឬប្រុស?

**ឆ៖** បាទ, លោក គឺថាខ្ញុំក្រឡេកមើលឃើញមួយភ្លែតហ្នឹង គឺថាមិនមែនស្រីទេ អ្នកទោសកន្លែង ហ្នឹង គឺប្រុសទេ ។

**ស៖** តើលោកធ្លាប់ឃើញអ្នកទោសមានរបួសត្រង់ណាខ្លះ បន្ទាប់ពីគេបានសួរចម្លើយហើយ?

**ឆ៖** បាទ,លោក! គឺថាពេលកន្លែងដែលខ្ញុំយាមបន្ទប់របស់ខ្ញុំហ្នឹង គឺថា គេយកទៅសួរចម្លើយខាងក្រៅហ្នឹង គឺថា គេយកទៅហ្នឹង គឺថាគេធ្វើទារុណកម្ម គឺថា ឃើញខ្នងហ្នឹងក៏បែកឈាម ឃើញក្រចកហ្នឹងក៏ស្នាមឃើញគេដក ។ ដូច្នេះ មកវិញហ្នឹងឃើញគេមានថ្នាំក្រហមអីហ្នឹង គេលាបខ្នងទៅលាបក្រចកអីទៅ គេបណ្តើរយកមកទុកវិញ គឺថាសោរនៅលើគេ អីលើគេ គេចាក់ខ្លួនគេៗ ខ្ញុំគ្រាន់នាទីមួយនឹងយាមទេ ។ សូមអស់ ។

**ស៖** នៅគុកពិសេសនោះលោកធ្លាប់ឃើញលោក ឌុច គាត់ចុះទៅពិនិត្យញឹកញាប់ទេនៅទីនោះ?

**ឆ៖** បាទ,លោក! គឺថាពេលនុ៎ងគឺថាដែលខ្ញុំនិយាយពីមុនមក គឺថាសឹងរាល់ថ្ងៃ គឺថាអានេះគឺថាជាការជ្រុលជ្រួសរបស់ខ្ញុំ គឺថាខ្ញុំសូមទោស ។ ដូច្នេះ គឺថា ពេលកន្លែងគុកពិសេសនេះ គឺថាចៀសមិនរួចទេ ដែលគាត់ត្រូវតែមក ព្រោះអីកន្លែងជាសំខាន់ គឺថាមកហើយ យូរៗគាត់មកម្តង គាត់ចូលតាមបន្ទប់អ្នកទោសហ្នឹង មើលមួយភ្លែតៗគាត់ដើរទៅវិញទៅ ។

**ស៖** លោកធ្លាប់ឃើញគាត់មកផ្ទាល់ភ្នែកទេ ហើយអាកន្លែងដែលលោកយាមហ្នឹង គាត់មានដែលមកដល់កន្លែងហ្នឹងទេ?

**ឆ៖** បាទ,លោក! គឺថាពេលនុ៎ង គឺថាខ្ញុំមើលឃើញផ្ទាល់នឹងភ្នែក ពីព្រោះអី ខ្ញុំយាមអ្នកទោស ហ្នឹងគឺថាផ្ទះជាន់ទីពីរឯណោះ ខ្ញុំមើលពីលើមក ខ្ញុំឃើញ ។ រឿងពិតហើយបានខ្ញុំនិយាយ បើមិនពិតខ្ញុំ អត់និយាយទេ ។

**ស៖** ក្រៅពីលោករៀបរាប់អម្បាញ់ពីអ្នកទោសម្នាក់ដែល ឌុច បានវាយ តើក្រៅពីផ្សេងពីហ្នឹង ទៀត មានដែលឃើញគាត់ធ្វើអំពើហិង្សាលើអ្នកទោសផ្សេងទៀតទេ?

**ឆ៖** បាទ,លោក! គឺថាអត់ដែលឃើញទេ ។

**ស៖** នៅគុកពិសេសនុ៎ង មានឃុំអ្នកទោសស្រីទេ? ហើយលោកដែលឃើញគេសួរចម្លើយអ្នក ទោសស្រីនោះមានប្រើអំពើហិង្សាទេ?

**ឆ៖** បាទ,លោក! គឺថាពេលដែលខ្ញុំយាមហ្នឹង គឺថា ខ្ញុំអត់ដែលឃើញទេ អ្នកទោសស្រី ដូច កន្លែងខ្ញុំក្តី គឺថាអត់មាន ។ តាមខ្ញុំពិនិត្យមើល គឺថាកន្លែងគេផ្សេង គឺមាន ។ ហើយអំពើហិង្សាក៏ខ្ញុំអត់ ដែល ឃើញគេធ្វើទារុណកម្មអ្នកទោសស្រីដែរ ក៏អត់ដែលឃើញដែរ ។

**ស៖** នៅកន្លែងគុកពិសេសហ្នឹង តើមានគេឃុំអ្នកទោសបស្ចិមប្រទេស ស្បែកស សក់លឿង ឈ្លើយសឹករៀតណាម ឬបុគ្គលិកស-២១ ដែលជាអ្នកទោសឬទេ?

**ឆ៖** បាទ, លោក! គឺថាពេលនុ៎ង គឺថា ខ្ញុំឃើញៗតែវៀតណាមទេ ដែលគេដាក់លើផ្ទះឈើ ហ្នឹងមានចំនួនប្រហែលជាបួននាក់ ពេលនុ៎ងគឺថា ខ្ញុំក៏អត់បានយាមកន្លែងហ្នឹងដែរ ប៉ុន្តែ ខ្ញុំដើរទៅបត់ ជើងហ្នឹង អ្នកយាមហ្នឹង គឺថាគេហៅខ្ញុំឲ្យទៅដូរគេបត់ជើងទេ មួយភ្លែតទេ ពេលនុ៎ងខ្ញុំឃើញ ហើយ ក្រៅពីហ្នឹងខ្ញុំអត់មានបានឃើញអីទៀតទេ ។

**ស៖** លោកមានដែលឃើញកុមារ ដែលមកជាមួយឪពុកម្តាយ ឃុំនៅទីនោះទេ?

**ឆ៖** បាទ,លោក! គឺកន្លែងហ្នឹង អត់មានទេ អត់មានដែលឃើញមានកុមារទេ ។

**ស៖** អ្នកទោសសំខាន់នោះ បន្ទាប់ពីគេសួរចម្លើយចប់ហើយ ហើយតើគេបញ្ជូនទៅទីណា?

**ឆ៖** បាទ,លោក! គឺថាពេលហ្នឹងដែលគេសួរចម្លើយហើយ ចួនកាលហ្នឹងបានមួយខែ ចួនកាល ម្ភៃថ្ងៃ អ៊ីចឹងដល់ពេលគេបញ្ចេញយកទៅគឺថាអត់ទៀងពេលទេ ចួនកាលគេទៅពេលល្ងាច ចួនកាលគេ យកទៅថ្ងៃ ។ ហើយអ្នកបញ្ចេញទៅមានតែដូច ស្រ៊ុ ដូចបង ហ៊ុយ អ៊ីចឹងភារកិច្ចរបស់គេ ។ ជាពិសេស ដូចបងធី គាត់ គឺថាគាត់អ្នកកាន់បញ្ជីចេញចូល គឺថាចួនកាលគាត់បណ្តើរយកចេញ ។ ហើយចេញហ្នឹង គឺថាមិនដឹងយកទៅឯណាទេក៏ខ្ញុំអត់បានដឹងដែរ មិនដឹងគេយកទុកខាងអគារក្នុងមិនដឹង ឬមួយគេយក

ទៅដល់ទីណាក៏ខ្ញុំអត់បានដឹងដែរ ។

**ស៖** នៅពេលដែលគេយកអ្នកទោសចេញ តើគេធ្វើយ៉ាងដូចម្ដេចលើអ្នកទោសបណ្ដើរចេញមក?

**ឆ៖** បាទ, លោក! គឺថាពេលដែលគេយកអ្នកទោសបណ្ដើរចេញមក គឺថាគេយកខ្នោះដៃ គេដាក់ដៃថយក្រោយ ហើយគេយកក្រណាត់ចងមុខ ក្រមាឃ្លុំបានគេយកសោរអីមកចាក់ខ្នោះជើងចេញបានគេបណ្ដើរយកចេញទៅ ។

**ស៖** តើលោកធ្លាប់ឃើញអ្នកទោសដែលគេយកចេញហើយយកត្រឡប់មកវិញទេ?

**ឆ៖** បាទ, លោក! នៅពេលនោះអត់មានយកចូលមកវិញទេ តែយកចេញផុតៗហើយ ។

**ស៖** លោកធ្លាប់ឃើញអ្នកទោសធ្វើអត្តឃាដ? តាមលោកកត់សម្គាល់ប្រហែលមានចំនួនប៉ុន្មាននាក់ដែរអ្នកទោសដែលធ្វើអត្តឃាដខ្លួនឯង?

**ឆ៖** បាទ, លោក! គឺថាពេលនុ៎ង ខ្ញុំបានឃើញម្នាក់ដែរ ពេលដែលគេយកអ្នកទោសចេញកន្លែងខ្ញុំយាមទៅ គឺថាមានឈ្មោះម្នាក់នៅយាមផ្ទះថ្មជាន់ទីបីនៅលើ ដូច្នេះ គេហៅខ្ញុំទៅឲ្យដូរគេបត់ជើង ។ ដល់ ហើយខ្ញុំឡើងទៅទទួលនិយាយប្រាប់ខ្ញុំ ឈ្មោះ ធុច ហ្នឹងគេប្រាប់ខ្ញុំថា ហ៊ឹស! ហ្អែងវីសអ្នកទោសយកក្រមាប្រុងចងក ឃើញចងហើយតែមិនទាន់បានចងបង្ហួចផង ធុច ហ្នឹងភ្ញាក់ដឹងហ្នឹង ធុច ហ្នឹងងោក ។ ហើយខ្ញុំក៏ខ្ញុំអត់ ខ្ញុំដឹងហើយខ្ញុំក៏អត់មាត់ដែរ ខ្ញុំអត់រាយការណ៍ នឹកឃើញថាតែរាយការណ៍និយាយទៅ ច្បាស់ជា ធុច ហ្នឹងច្បាស់ជាងាប់ហើយ គ្មាននៅទេ ឃើញសកម្មភាពប៉ុណ្ណេះហើយ ។ បាទខ្ញុំឃើញ តែម្នាក់ហ្នឹងទេនៅលើនោះ ជាន់ទីបីនោះ ។

[១៥:៤៨:០៣]

**ស៖** អ្នកទោសនោះស្រី ឬប្រុសដែរ?

**ឆ៖** បាទ, ប្រុសទេ ។

**ស៖** លោកមានដឹងពីជោគវាសនាអ្នកទោសសំខាន់ៗនោះយ៉ាងដូចម្ដេចដែរ?

**ឆ៖** បាទ,លោក! ខ្ញុំអត់យល់ទេកន្លែងហ្នឹង សូមបញ្ជាក់ម្ដងទៀត ។

**ស៖** តើលោកមានដឹងថា ជោគវាសនាអ្នកទោសសំខាន់ៗដែលគេយកចេញហ្នឹង តើមានជីវិតនៅរស់ឬទេ?

**ឆ៖** បាទ លោកតាមខ្ញុំចំណាំសម្គាល់មើល គឺថាអត់មាននៅទេ ។

**ស៖** លោកដែលដឹង ដែលឮគេថាយកអ្នកទោសសំខាន់ៗយកទៅសម្លាប់នៅហ្នឹងមន្ទីរស-២១ ឬ ក៏នៅជើងឯក?

**ឆ៖** បាទ,លោក! គឺថាពេលនោះដែលគេយកចេញហ្នឹងគេអត់ប្រាប់យើងទេ អត់ប្រាប់ថាឥឡូវយកទៅកម្ទេចនៅណោះ នៅនោះ ឬមួយបឹងជើងឯកគឺថាអត់មានប្រាប់អ្នកយាមទេ គឺថាគេដឹងតែយកចេញទៅ ។

**ស៖** ក្នុងអំឡុងពេលលោកធ្វើការជាអ្នកយាមនៅគុកពិសេសនោះ តើលោកអាចប៉ាន់ប្រមាណបានទេថាប្រហែលជាអ្នកទោសសំខាន់ដែលត្រូវគេយកចេញមានចំនួនប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ,លោក! គឺថាពេលនុ៎ង គឺថាខ្ញុំក៏ក្តាប់មិនបានដែរទេ ព្រោះអីវាមានជាការញ៉ើកញ៉ាប់ ។ អ៊ីចឹងដល់ពេលឲ្យខ្ញុំស្មានក៏ស្មានក៏មិនត្រូវដែរ ។

**ស៖** គ្រាន់តែជាចំនួនប្រហាក់ប្រហែលដែលលោកប៉ាន់ស្មានមើល?

**ឆ៖** បាទ, លោក! បើតាមខ្ញុំស្មានវិញ គឺថា មានតែត្រឹមមួយរយ ។

**ស៖** ពេលគេបញ្ជូនលោកទៅព្រៃស មានអ្នកណាខ្លះទៅជាមួយលោកដែរ?

**ឆ៖** បាទ, លោក! គឺថានៅពេលដែលគេបញ្ជូនខ្ញុំទៅព្រៃសហ្នឹង គឺថាមានចំពោះរូបខ្ញុំមួយ ហើយនិង ហ៊ាន ហ្នឹងពីរ ស្រ៊ីម នេះបី ម្នាក់ទៀតខ្ញុំអត់បានស្គាល់ទេ បញ្ជូននៅក្នុងចុងឆ្នាំ១៩៧៨ ។

**ស៖** ការបញ្ជូនទៅព្រៃសនេះជាទណ្ឌកម្ម ឬក៏ជាការដល់វេនធ្វើស្រែសម្រាប់ស-២១?

**ឆ៖** ពេលនោះគឺថា ខ្ញុំវាអត់បានដឹងថាដំណើរការហ្នឹងយ៉ាងម៉េចទេ ប៉ុន្តែ ដល់ហើយគេបញ្ជូនទៅគេថា ខ្ញុំសួរថា ចុះម៉េចជូនអ្នកទោសមកកន្លែងហ្នឹង? ខ្ញុំសួរ ស្រ៊ី អ៊ីចឹង? ផល ហើយនិង ហ្នឹងហើយបងផល ដល់ខ្ញុំសួរអ៊ីចឹងទៅគាត់ថាអ្នកទោសនៅសល់ប៉ុន្មានគេយកទៅទុកនៅអគារក្នុងអស់ហើយ ។ ឥឡូវមិត្តឯង រៀបចំសម្ភារៈខោអាវបាឡូអីយកទៅនៅព្រៃសទៅ។ ខ្ញុំក៏រៀបចំសម្ភារៈទៅនៅព្រៃសទៅ។

**ស៖** នៅព្រៃសនោះ ពេលលោកទៅដល់គេឲ្យលោកធ្វើអី? ហើយប្រធានព្រៃសនោះឈ្មោះអី?

**ឆ៖** បាទ, លោក! ពេលទៅហ្នឹង គឺថា គេឲ្យយើងទៅជីកប្រឡាយ ទប់ទំនប់ អ៊ីវ៉ាន់អ៊ីចឹង ។

**ស៖** អ្នកដែលធ្វើការជាមួយលោកនៅទីនោះជាអ្នកទោស ឬក៏ជាបុគ្គលិកដែលគេបញ្ជូនទៅឲ្យគ្រាន់ធ្វើស្រែសម្រាប់ស-២១?

**ឆ៖** បាទ, លោក! គឺថាពេលនុ៎ងខ្ញុំអត់បានដឹងពីរឿងបញ្ហាដែលខ្ញុំជាប់ពាក់ព័ន្ធជាមួយបង ឬមួយមិនដឹងជាយ៉ាងម៉េចដែរ ខ្ញុំអត់បានដឹងដែរ ។

**ស៖** ចុះមានបានសួរនាំអ្នកដែលធ្វើការជាមួយលោកនៅព្រៃសហ្នឹងទេ? តើគេជាអ្នកទោស ឬក៏គេជាបុគ្គលិកធម្មតាសម្រាប់ធ្វើស្រែដើម្បីបំប៉នដល់អង្គភាព?

**ឆ៖** បាទ, គឺថាពេលនុ៎ងដែលខ្ញុំធ្លាប់រួមរស់នៅជាមួយគេហ្នឹងបានជាងមួយខែហ្នឹង គឺថាសុទ្ធតែអ្នកពាក់ព័ន្ធចំពោះដូចថា មានប្រវត្តិរូបអីមិនល្អ ឬមួយមានសីលធម៍ ដូចថាសមាសភាពមិនមានបុគ្គលិកនៅក្នុងហ្នឹងដែរទេ ។

**ស៖** តើលោកធ្លាប់ដែរឃើញគេយកអ្នកទាំងអស់នោះចេញពីព្រៃសទេ តាមមធ្យោបាយអី?

**ឆ៖** បាទ, លោក! គឺថាពេលនុ៎ង ដែលខ្ញុំនៅព្រៃសហ្នឹងគឺថា ចៀសមិនរួចទេ ពីមើលឃើញដូចជា ឡានៗចិនអីចឹង គឺថាឃើញចេញចូលតែមិនដឹងគេយកអ្នកទោស ឬមួយគេយក អ្នកយ៉ាងម៉េចដែរ ខ្ញុំអត់បានដឹង ឃើញឡាននោះចេញចូលៗ ។

**ស៖** លោកមានបានកត់សម្គាល់ថា អ្នកធ្វើការជាមួយលោកនោះ មានបាត់មុខពីកន្លែងធ្វើការនោះ ហើយឡាននោះដឹកអ្នកទោស ឬក៏ដឹករបស់?

**ឆ៖** គឺទៅដល់កន្លែងហ្នឹងគឺថា តាមខ្ញុំសម្គាល់មើលគឺថា ច្រើនតែដឹកអ្នកសមាសភាពមិនល្អដែរ ដូចថាមានការពាក់ព័ន្ធ បើនិយាយរួមថាខ្ញុំមិនទាន់ដល់ដំណាក់កាលហ្នឹងដែរ ។ ហើយអ្នកធ្វើការជាមួយគ្នាហ្នឹងវាមានការបាត់ហើយ ប៉ុន្តែមិនដឹងជាគេយកទៅផ្លាស់ប្តូរទៅអង្គភាពណា ឬមួយទៅកន្លែងណាក៏ខ្ញុំអត់បានដឹងដែរ ។

**ស៖** ក្នុងរយៈពេលជាងមួយខែដែលលោកបានបញ្ជាក់អម្បាញ់មិញ តើលោកមានបានកត់សម្គាល់ថាមានប៉ុន្មានឡានដែលដឹកអ្នកនៅទីនោះចេញទៅក្រៅ?

**ឆ៖** នេះតាមខ្ញុំស្មានទេគឺថា រឿងឡាននោះវាមិនទៀង ចួនកាលចេញយប់ចេញថ្ងៃ ហើយបើតាម ខ្ញុំស្មានវាចួនកាលក្នុងមួយថ្ងៃហ្នឹងចេញមានមួយឡានក៏មាន ពីរឡានក៏មាន អាហ្នឹងថ្ងៃ ។ ហើយបើយប់វិញគឺថា ឃើញតែភ្លើងឡានចេញតែមិនដឹងដាក់ស្អីខ្ញុំអត់បានដឹង ឃើញឡានថាឡានចិនទាំងអស់ អាហ្សីន អាកាត់សង់កាត់ ពណ៌អាចម៍សេះ ។

**ស៖** លោកមានស្គាល់ជើងឯកទេ?

**ឆ៖** បាទ, លោកខ្ញុំអត់ដែលស្គាល់ទេ អត់ដែលទៅផង ។

**ស៖** ក្នុងអំឡុងពេលលោកធ្វើការនៅទីនោះ លោកមានដែលឮសួរថា អ្នកទោសហ្នឹងគេយកទៅសម្លាប់ហ្នឹងជើងឯកទេ?

**ឆ៖** បាទ,លោក! គឺថាពេលនុ៎ង ខ្ញុំអត់បានដឹង បានឃើញដែរព្រោះអីខ្ញុំកាលហ្នឹងខ្ញុំនៅ ចួនកាលខ្ញុំ នៅឃាមនៅទីនេះ គេមិនដឹងថា គេយកអ្នកទោសទៅបឹងជើងឯក ឬមួយគេយកទៅកន្លែងណា? ក៏ខ្ញុំអត់បានដឹងដែរ ។

**ចៅក្រម យ៉ា សុខនៈ**

ខ្ញុំសូមអស់សំណួរលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីសួរដល់--

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សួស្តី លោកសោម ម៉េត! ខ្ញុំឈ្មោះចៅក្រម ឡាវែន៍ ។ ខ្ញុំមានសំណួរមួយចំនួនតូចសម្រាប់លោក។ អ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតបានសម្ភាសលោក ។ ហើយឯកសារសម្ភាសន៍នោះគឺ D28/3 នៅក្នុងឯកសារសំណុំរឿង ។ ក្នុងចំណោមចំណុចទាំងឡាយ លោកបានលើកឡើងចំណុចនេះថា ឆ្លើយតបទៅនឹងសំណួរដែលសួរលោក ថាតើប្រភេទទារុណកម្មអ្វីដែលអ្នកសួរចម្លើយបានធ្វើទៅលើអ្នកទោសនោះ ។ លោកបាននិយាយថា ពួកគេវាយអ្នកទោសដើម្បីឲ្យពួកគេឆ្លើយ ហើយឆក់ទៅលើអ្នកទោស ដកក្រចក ដកក្រចកជើងផ្សេងៗ ហើយយកម្ជុលចាក់ក្រចកជើង ហើយយកស្បោងខ្ទប់មុខរបស់គេដើម្បីឲ្យថប់ខ្យល់ ។ ហើយពេលខ្លះគេដោះអាវអ្នកទោស ហើយគេយកឧបករណ៍ឆក់ទៅលើប្រដាប់ភេទ ។ ខ្ញុំមើលតាមបង្ហួចនៅពេលដែលខ្ញុំកំពុងតែឃាមនេះមានលើក ឡើងនៅក្នុងទំព័រ៤នៃឯកសារដែលខ្ញុំសំដៅទៅអម្បាញ់មិញនេះ ។ តើលោកនៅប្រកាន់ជំហរនូវអ្វីដែលខ្ញុំបានអានអម្បាញ់មិញនេះដែរឬទេ? នេះជាអ្វីដែលលោកបានឃើញដោយផ្ទាល់ខ្លួនលោកនៅពេលនោះ តើអ៊ីចឹងមែនទេ?

[១៦:00:00]

**ឆ៖** បាទ, លោកគឺរឿងពិតមែន ដូច្នេះខ្ញុំក៏អត់បានរៀបរាប់ដែរ ។

**ស៖** ចំពោះជនជាប់ចោទដែលមានវត្តមាននៅទីនេះក្នុងបន្ទប់សវនាការ តើលោកធ្លាប់បានឃើញគាត់ដែរឬទេ? ហើយអាចជម្រាបទេថា នេះជាបុគ្គលដែលលោកហៅថា ឌុច នោះ ក្នុងពេលដែលលោកបានឆ្លើយនៅក្នុងចម្លើយរបស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត?

**ឆ៖** បាទ,លោក! គឺថាពេលហ្នឹងដែលខ្ញុំនិយាយទាំងប៉ុន្មាន គឺថាពិតទាំងអស់ ។ ខ្ញុំអត់មានពន្លើសទេ កន្លែងណាដែលការពិតគឺថាខ្ញុំនិយាយហើយ មិនពិតខ្ញុំអត់និយាយទេ ។ សូមអស់ ។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេថាលោកបានស្គាល់ជនជាប់ចោទ ដែលនៅពេលនេះកំពុងតែអង្គុយនៅក្នុងសវនាការ គាត់ហ្នឹងជា ឌុច មែនដែរឬទេ?

**ឆ៖** បាទ,លោក! គឺថាខ្ញុំទទួលស្គាល់ថាគាត់ហ្នឹងឈ្មោះ ឌុច មែន ។

**ស៖** នៅក្នុងការសម្ភាសន៍របស់ចៅក្រម លោកក៏បានរៀបរាប់អំពីពេលដែលលោកឃើញ ឌុច ហើយតាមចម្លើយរបស់លោកនោះគឺ គាត់សួរចម្លើយ ហើយប្រើរំពាត់ផ្ដៅ ប៉ុន្តែ នៅពេលនេះខ្ញុំចង់លើកអំពីចំណុចមួយចំនួនដែលលោកបាននិយាយ ឯកសារបារាំងក៏មាន ប៉ុន្តែយ៉ាង-- មានបកប្រែ ហើយខ្ញុំចង់សួរថា តើលោកនៅពេលនោះធ្លាប់ឃើញ ឌុច ញឹកញាប់ដែរឬទេ? ហើយគាត់ទៅកន្លែងនោះញឹកញយដែរឬទេ ឬក៏លោកកម្រឃើញគាត់ណាស់?

**ឆ៖** បាទ, គឺថាពេលហ្នឹង ដែលខ្ញុំនៅកន្លែងហ្នឹងគឺថា ថាឲ្យគាត់ទៅរាល់ថ្ងៃគឺគ្មានទេ ប៉ុន្តែគ្រាន់តែថាយូរៗឃើញគាត់ម្ដង គឺថាគាត់ដើរតាម មើលតាមបន្ទប់អ៊ីចឹងទៅ ហើយបានគាត់វិលត្រឡប់ទៅវិញទេ រឿងឲ្យឃើញរាល់តែថ្ងៃគឺគ្មានទេ ។ សូមអស់ ។

**ស៖** នៅពេលដែលលោកនិយាយថា គាត់នោះទៅពិនិត្យបន្ទប់ផ្សេងៗ តើលោកមានន័យយ៉ាងម៉េច? គឺជាបន្ទប់ដែលគេឃុំអ្នកទោស ឬក៏វាសំដៅទៅលើបន្ទប់ដែលអ្នកសួរចម្លើយគេសួរអ្នកទោស? ថាតើគាត់ហ្នឹង ជនជាប់ចោទហ្នឹងគាត់ទៅពិនិត្យកន្លែងណា? កន្លែងដែលលោកសំដៅហ្នឹងគឺកន្លែងណាជាក់លាក់ដែរ?

[១៦:០៣:២៦]

**ឆ៖** បាទ,លោក! គឺថា ខ្ញុំដូចខ្ញុំនិយាយពីមុនអ៊ីចឹង ។ ខ្ញុំយាមអ្នកទោសនៅជាន់ទីពីរ ខ្ញុំមើលពីលើមកគឺថាឃើញគាត់ចូលពិនិត្យតាមផ្ទះថ្មតៀមតាំងពីកើតរហូតមកដល់លិច ហើយបានគាត់បកទៅវិញ ។ ខ្ញុំគិតថា អ្នកទោសកន្លែងដែលគាត់ធ្លាប់ចូល គឺថាគាត់ចូលមើល ។ សូមអស់ ។

**ស៖** តើលោកអាចជម្រាបអង្គសវនាការបានដែរឬទេថា លោកដឹងមូលហេតុអ្វីបានគេបញ្ជូនលោកទៅព្រៃស?

**ឆ៖** បាទ,លោក! គឺថាពេលហ្នឹង គឺថាខ្ញុំបានដឹងខ្លួនចំពោះរូបខ្ញុំ ដូច បងហ៊ុយ គាត់សួរខ្ញុំថា "ម៉េត! បងម៉េត ឯងមានឈ្មោះ សោម ម៉េង ទេ?" ថាខ្ញុំ "មែន" "ហើយមានដឹងនៅឯណាទេ?" ខ្ញុំថា

"អង្កាល់-- គឺថាបច្ចុប្បន្នខ្ញុំអត់ដឹងទេ គឺថាពីមុនខ្ញុំឮសូរថា គាត់ហ្នឹងនៅព្រលានយន្តហោះកំពង់ឆ្នាំង" ។ ដល់ខ្ញុំនិយាយប្រាប់ ហ៊ុយ អ៊ីចឹងមកគឺថា ហ៊ុយ ថា "ហ៊ឺ! គេចាប់យកមកហើយ ប៉ុន្តែកុំមាត់ណា៎ លាក់ការណ៍" ។ ខ្ញុំក៏នឹកឃើញថា ពេលហ្នឹងខ្ញុំក៏អត់មាត់អត់កទេ នឹកឃើញថា មិនដឹងធ្វើយ៉ាងម៉េចដើម្បីឲ្យរួចខ្លួន អ៊ីចឹងគឺថា ខំខាំមាត់សង្កត់ចិត្តថាមិនមាត់ទេ សុខចិត្តឲ្យស្លាប់ម្នាក់ចុះ ។ ឃើញ បងហ៊ុយ ក៏សុខចិត្តជួយលាក់ខ្ញុំដែរពេលហ្នឹង បានគេ-- ហើយណាមួយខ្ញុំយល់កន្លែងហ្នឹងហើយ បាននឹកឃើញថាគេបញ្ជូនខ្ញុំទៅព្រៃស ។ សូមអស់ ។

**ស៖** ដូច្នេះ អ្វីដែលលោកជម្រាបយើងខ្ញុំទាំងអស់គ្នានេះគឺថា គេបញ្ជូនលោកទៅព្រៃស ដោយ-សារតែបងប្រុសបង្កើតរបស់លោកត្រូវបានគេចាប់ ។ ថាតើគេបញ្ជូនបងរបស់លោកទៅស-២១ ដែរឬទេ? ហើយលោកបានពិនិត្យមើលដែរឬទេ ឬក៏ស្រាវជ្រាវដែរឬទេថាគេពិតជាបានបញ្ជូនបងរបស់លោកទៅស-២១ មែន?

**ឆ៖** បាទ,លោក! គឺថា បងហ៊ុយ ប្រាប់ខ្ញុំត្រង់ហើយ ។ ដូច្នេះ ដល់ពេលចាប់នេះខ្ញុំក៏មកកន្លែងទួលស្លែង ខ្ញុំស្រាវជ្រាវរកមើលឃើញរូបថតមែន ពិតជាបងខ្ញុំមែន គឺធម្មតាបងប្អូនតែងតែចំណាំឃើញហើយ ។ អ៊ីចឹងហើយជាក់ស្តែងមកនឹងទួលស្លែង ប៉ុន្តែមិនដឹងគេបញ្ជូនយកទៅឯណាទៀតក៏មិនដឹងដែរ។

**ស៖** លោកបាននិយាយអំពី ហ៊ុយ តើលោកកំពុងតែសំដៅទៅលើ ហ៊ឹម ហ៊ុយ ហ្នឹងមែនឬទេ? តើលោកចង់និយាយអំពី ហ៊ុយ មួយណា?

**ឆ៖** បាទ,លោក! គឺថាខ្ញុំចង់សំដៅទៅលើ ហ៊ឹម ហ៊ុយ ដែលអ្នកទទួលខុសត្រូវកន្លែងខ្ញុំហ្នឹង ។

[១៦:០៧:២១]

**ស៖** ថាតើ ហ៊ឹម ហ៊ុយ ហ្នឹងហើយដែលក្រោយមកបញ្ជូនលោកទៅព្រៃសហ្នឹងមែនឬទេ? ហើយគាត់បញ្ជូនលោកនៅពេលណាដែរ បញ្ជូនទៅព្រៃសហ្នឹង?

**ឆ៖** បាទលោក គឺថាហ៊ឹម ហ៊ុយ ហ្នឹងបញ្ជូនខ្ញុំហ្នឹងទៅថា នៅចុងឆ្នាំ១៩៧៨ ។

**ស៖** ដូច្នេះលោកបានជម្រាបថា នៅចុងឆ្នាំ១៩៧៨ ហ៊ឹម ហ៊ុយ ហ្នឹងគឺធ្វើការនៅស-២១ នៅឡើយទេ ហើយក្រោយមក តើលោកបានឃើញគាត់នៅព្រៃស ដែរឬទេ?

**ឆ៖** បាទ, ពេលហ្នឹងគឺថាខ្ញុំភ្លេចហើយ ខ្ញុំក្តាប់អត់បានទេ មិនដឹងគាត់បានទៅព្រៃស ឬមួយគាត់នៅក្នុងមន្ទីរស-២១ គឺខ្ញុំអត់បានចាំដែរ ។

**ស៖** តើលោកអាចជម្រាបអង្គសវនាការបានដែរឬទេ ថាតើមានអ្វីកើតឡើងនៅពេលដែលទ័ពវៀតណាមបានចូលមក? តើលោកបានធ្វើអ្វីខ្លះនៅទីនោះ?

**ឆ៖** បាទ,លោក! គឺថាពេលហ្នឹងដែលកងទ័ពវៀតណាមចូលមកដល់ទីក្រុងភ្នំពេញហ្នឹងគឺថា ខ្ញុំក៏នៅព្រៃសដែរ ។ ដូច្នេះ គឺថាពេលហ្នឹងគឺខាងពួក ខាងនៅទួលស្លែង ២១នេះ ក៏គេទៅពេលយប់ដែរ ។ ទៅបាននាំគ្នាតម្រង់ផ្លូវនាំគ្នាទៅខាងថ្នល់ជាតិលេខបីឯណោះ ពេលយប់ហ្នឹង ។

**ស៖** តើលោកបានទៅតាមអ្នកដែលមកពីស-២១ ហើយរត់គេចខ្លួនដែរឬទេ ឬក៏លោកបានទៅផ្ទះរបស់លោកវិញ? តើលោកនៅពេលនោះធ្វើអ្វីដែរ ហើយលោកបានឃើញ ឌុច ដែរឬទេ?

**ឆ៖** បាទ, ពេលហ្នឹង គឺថារត់ទៅដល់ឯលិចហ្នឹង ឆ្លងថ្នល់ជាតិលេខ៤ហើយ ប៉ុន្តែ ខ្ញុំអត់បានឃើញ បងឌុចទេ ឃើញតែសុទ្ធតែគ្នាឯង ដូច្នេះវៀតណាមចូលទៅដល់ តាមទៅដល់ហ្នឹង ខ្ញុំក៏នាំគ្នាបែកបែកគ្នាមកដល់ផ្ទះវិញមក នៅឆ្នាំមួយពាន់ប្រាំបួនរយ-- ក្នុង៧៩ ដដែល ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណច្រើនលោកសោម ម៉េត ខ្ញុំពុំមានសំណួរបន្ថែមទៀត ដើម្បីសួរសាក្សីនោះទេ ។ សូមអរគុណលោកប្រធាន ។

[១៦:១០:៣៩]

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រមមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ?

បើមិនមានទេគឺ ដោយសារពេលវេលានៅតិច បើប្រគល់ឲ្យទៅខាងតំណាងសហព្រះរាជអាជ្ញាក៏ពេលវេលាខ្លីដែរ ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា ដំណើរការសវនាការស្តាប់សាក្សីរូបនេះ ត្រូវផ្អាកត្រឹមនេះសិន ហើយសវនាការលើកទៅបន្តនៅព្រឹកថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹក ។

លោក ឈុន ផល (សោម ម៉េត) ដោយសារការដែលអង្គជំនុំជម្រះស្តាប់សក្ខីកម្មរបស់លោកពាក់ព័ន្ធជាមួយនឹងអង្គហេតុទាក់ទិនជាមួយនឹងមន្ទីរស-២១ ហើយនិងមន្ទីរស-២៤ ឬក៏ព្រៃស នេះមិនទាន់ចប់នៅឡើយទេ ។ ការស្តាប់សក្ខីកម្មនេះទើបតែចប់ផ្នែកខាងអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ ។ ដូច្នេះ គឺអង្គជំនុំជម្រះសូមអញ្ជើញលោកមកផ្តល់សក្ខីកម្មបន្តនៅព្រឹកថ្ងៃស្អែកទៀត ។

មន្ត្រីតុលាការសម្របសម្រួល ដើម្បីជូនគាត់ទៅជួបជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញដើម្បីឲ្យគាត់បានទទួលនូវកន្លែងសម្រាកសមរម្យ ហើយឲ្យនាំគាត់មកកាន់បន្ទប់សវនាការនៅព្រឹកថ្ងៃ

ស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ។ អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនាំគាត់មកកាន់សាលសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង ១៦:១៣នាទី]*